សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ

និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ម៉ន ម៉ារ៉ាឌី**

សាស្ត្រាចារ្យណែនាំ

លោក **អ៊ុន ម៉ារឌី**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១២

ឆ្នាំចូលរៀន ២០១៥

ឆ្នាំសរសេរសារណា ២០១៩

## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

# សារណាបញ្ចប់ការសិក្សា

# ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ម៉ន ម៉ារ៉ាឌី**

សាស្ត្រាចារ្យណែនាំ
លោក **អ៊ុន ម៉ារឌី**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ
ជំនាន់ទី ១២

ឆ្នាំចូលរៀន ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ ម៉ន ម៉ារ៉ាឌី ជានិស្សិតថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ជំនាន់ទី ១២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ឆ្នាំសិក្សា ២០១៨ - ២០១៩ បានធ្វើរបាយការណ៍សារណាបញ្ចប់ការសិក្សាស្រាវជ្រាវលើប្រធានបទ "ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា"។ ឆ្លៀតក្នុងឱកាសនេះខ្ញុំបាទ សូមធ្វើការបង្ហាញពីសេចក្ដីដឹងគុណ និងថ្លែងអំណរគុណដល់ជ្រាលជ្រៅដល់បុគ្គលសំខាន់ៗដូចខាងក្រោម៖

- ❖ លោកឪពុក អ្នកម្ដាយជាអ្នកមានគុណទាំងពីរជាទីស្រលាញ់ និងក្រុមគ្រួសារ ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា ផ្គត់ផ្គង់ ការអប់រំទូន្មាន ប្រៀនប្រដៅដោយយកចិត្តទុកដាក់ និងប្រកបដោយភាពកក់ក្ដៅ សេចក្ដីស្រលាញ់ តាមគន្លងធម៌ មេត្តា ករុណាយ៉ាងខ្លាំង។
- ❖ ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងព្រឹទ្ធបុរសរង ដែលបានផ្ដល់ឱកាសដល់ខ្ញុំបាទ និងមិត្តនិស្សិតដទៃទៀតក្នុងការសិក្សា ក៏ដូចជាផ្ដល់ឱកាសក្នុងការស្រាវជ្រាវបង្កើនចំណេះដឹងឲ្យកាន់តែស៊ីជម្រៅថែមទៀត។ បើគ្មានការផ្ដល់ឱកាសនេះទេ យើងខ្ញុំក៏ពុំមានឱកាសក្នុងការបកស្រាយកិច្ចស្រាវជ្រាវនេះដែរ។
- ❖ លោកសាស្ត្រាចារ្យ អ៊ុន ម៉ារឌី ដែលបានដឹកនាំខ្ញុំបាទ ដោយផ្ដល់ជាមតិយោបល់ និងផ្ដល់នូវគំនិតស្ថាបនាគ្រប់បែបយ៉ាង ហើយជួយកែលម្អ និងសម្រួលរាល់កំហុសឆ្គងដើម្បីធ្វើឲ្យរបាយការណ៍នេះកាន់តែមានភាពល្អប្រសើរឡើង។
- ❖ លោក និងលោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ជាពិសេស លោក និងលោកស្រីសាស្ត្រាចារ្យផ្នែកធនាគារ និងហិរញ្ញវត្ថុដែលបានចំណាយពេលវេលាបង្ហាត់បង្រៀនខ្ញុំបាទដោយខិតខំអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ចែករំលែកបទពិសោធន៍ល្អៗទាំងក្នុងការសិក្សា និងបទពិសោធន៍សង្គម។
- ❖ មិត្តនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផ្នែកធនាគារ និងហិរញ្ញវត្ថុជំនាន់ទី១២ទាំងអស់ និងរៀមច្បង ពិសេសក្រុមថ្នាក់ B4A1 ដែលបានផ្ដល់ជាកម្លាំងចិត្ត និងផ្ដល់ជាយោបល់ល្អៗក្នុងដំណើរការស្រាវជ្រាវនេះ។

ជាចុងបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរដល់បុគ្គលសំខាន់ៗដែលបានរៀបរាប់ខាងលើឲ្យមានសុខភាពល្អ ទទួលបានជោគជ័យទាំងក្នុងវិស័យការងារ និងក្រុមគ្រួសារ និងបានជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ខ្ញុំបាទជានិស្សិតជំនាន់ទី១២ ជំនាញធនាគារ និងហិរញ្ញវត្ថុនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យ វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ឆ្នាំសិក្សា ២០១៨-២០១៩ បានធ្វើការស្រាវជ្រាវ និងចងក្រងកិច្ចការស្រាវជ្រាវនេះឡើងក្នុងគោលបំណងដើម្បីពង្រីកនូវចំណេះដឹង និងព្រមទាំងមូលដ្ឋានគ្រឹះសំខាន់ៗ ទាក់ទងនឹងវិស័យហិរញ្ញវត្ថុ ជាពិសេស វិស័យមូលបត្រនៅក្នុងប្រទេសកម្ពុជា ទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែងដែលបានឆ្លងកាត់តាមរយៈការសិក្សានៅសាកលវិទ្យាល័យអស់រយៈពេលបួនឆ្នាំកន្លងមកនេះ។

ក្នុងការស្រាវជ្រាវនូវប្រធានបទស្តីពី "ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា" នេះគឺបានផ្តោតសំខាន់ទៅលើវិស័យមូលបត្រ ដែលពាក់ព័ន្ធទៅនឹងដំណើរការនៃការបោះផ្សាយលក់មូលបត្រ និងដំណើរការនៃការជួញដូរមូលបត្រនៅក្នុងប្រទេសកម្ពុជា។ ទោះបីប្រធានបទនេះថ្មីសម្រាប់រូបខ្ញុំបាទផ្ទាល់ ក៏ប៉ុន្តែខ្ញុំបានខិតខំប្រឹងប្រែងសម្រេចចេញជារូបរាងនូវសារណាបញ្ចប់ការសិក្សាមួយនេះឡើង សម្រាប់ជាគំនិតស្តួចស្តើងមួយ ដែលនឹងអាចជាទុនមួយសម្រាប់និស្សិតជំនាន់ក្រោយៗទុកជាគំរូឯកសារក្នុងការស្រាវជ្រាវបន្តទៀត។

ជាទីបញ្ចប់ខ្ញុំបាទនឹងខិតខំធ្វើការតាក់តែង ចងក្រងជាសៀវភៅឲ្យកាន់តែមានការរីកចម្រើន និង មាននូវគុណភាពដែលអាចទទួលស្គាល់បាន ប៉ុន្តែទោះជាមានការខិតខំប្រឹងប្រែងយ៉ាងណាក៏ដៀសមិនផុតពី ចំណុចខ្វះខាតមួយចំនួនដែរ។ ដូចនេះខ្ញុំបាទនឹងចាំទទួលនូវការរិះគន់គ្រប់ចំណុចខុសឆ្គងទាំងឡាយដោយសេចក្តីពេញចិត្ត ហើយធ្វើការកែប្រែអោយកាន់តែប្រសើរឡើង ។

# មាតិកា


បញ្ជីអក្សរកាត់ ..... vii

បញ្ជីតារាង ..... viii

បញ្ជីរូបភាព ..... ix

បញ្ជីឧបសម្ព័ន្ធ ..... x


# សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ២

៣. គោលបំណងនៃការស្រាវជ្រាវ ..... ៣

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ..... ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ៤

៦.១. ទិន្នន័យចម្បង ..... ៤

៦.២. ទិន្នន័យបន្ទាប់បន្សំ ..... ៥

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៥


# ជំពូកទី១

# រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងទីផ្សារមូលបត្រ


១.១. ទីផ្សារមូលបត្រ ..... ៦

១.១.១. ប្រវត្តិទីផ្សារមូលបត្រ ..... ៦

១.១.២. និយមន័យនៃផ្សារមូលបត្រ ..... ៧

១.២. ប្រភេទនៃទីផ្សារមូលបត្រ ..... ៧

១.២.១. ទីផ្សារដំបូង ..... ៧

១.២.២. ទីផ្សារបន្ទាប់ ..... ៨

១.២.៣. ទីផ្សាររូបិយបណ្ណ ..... ៨

១.២.៤.ទីផ្សារមូលធន ......................................................................................... ៩

១.៣. ប្រភេទនៃមូលបត្រ ......................................................................................... ៩

១.៣.១. មូលបត្រកម្មសិទ្ធិ......................................................................................... ៩

១.៣.២. មូលបត្របំណុល......................................................................................... ១១

១.៣.៣. ឧបករណ៍និស្សន្ទ......................................................................................... ១៣

១.៤. តួអង្គដែលចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា......................................................................................... ១៣

១.៤.១. រចនាសម្ព័ន្ធរបស់ប្រតិបត្តិករនៅក្នុងផ្សារមូលបត្រ......................................................................................... ១៣

១.៤.១.១. និយ័តករមូលបត្រ......................................................................................... ១៣

១.៤.១.២. ប្រតិបត្តិករទីផ្សារមូលបត្រ......................................................................................... ១៣

១.៤.១.៣. ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និង ទូទាត់មូលបត្រ ......................................................................................... ១៣

១.៤.១.៤. ប្រតិបត្តិកររក្សាទុកមូលបត្រ ......................................................................................... ១៤

១.៤.១.៦. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ......................................................................................... ១៥

១.៤.១.៧. វិនិយោគិនមូលបត្រ......................................................................................... ១៦

១.៤.២. តួអង្គដទៃទៀត......................................................................................... ១៦

១.៤.២.១. ភ្នាក់ងារទូទាត់ប្រាក់ទាក់ទងនឹងមូលបត្រ ......................................................................................... ១៦

១.៤.២.២. ភ្នាក់ងារបញ្ជិកាមូលបត្រ ......................................................................................... ១៦

១.៤.២.៣. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ......................................................................................... ១៦

១.៤.២.៤. ភ្នាក់ងារទូទាត់មូលបត្រ......................................................................................... ១៧

១.៤.២.៥. ក្រុមហ៊ុនគណនេយ្យករជំនាញផ្តល់សេវាក្នុងវិស័យមូលបត្រ និងសវនករឯករាជ្យ ......................................................................................... ១៧

១.៤.២.៦. ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យមូលបត្រ ......................................................................................... ១៨

១.៤.២.៧. ភ្នាក់ងារដាក់ពិន្ទុឥណទាន ......................................................................................... ១៨

# ជំពូកទី២
# គណៈកម្មការមូលបត្រកម្ពុជា


២.១. រូបសញ្ញា និង អត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា.............................២០

២.១.១. រូបសញ្ញា ........................................................................................................២០

២.១.២. អត្ថន័យនៃរូបសញ្ញា ......................................................................................... ២១

២.១.៣. ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា.................................................................. ២២

២.២. ប្រវត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា.................................................................. ២២

២.៣. គោលដៅ និង គោលបំណងរបស់គណៈកម្មការមូលបត្រកម្ពុជា ..................................... ២២

២.៤. ចក្ខុវិស័យ និងបេសកកម្មរបស់គណៈកម្មការមូលបត្រកម្ពុជា..........................................២៣

២.៤.១. ចក្ខុវិស័យ .........................................................................................................២៣

២.៤.២. បេសកកម្ម .........................................................................................................២៣

២.៥. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា .....................................................................២៤

២.៦. រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា ...................................................២៤

២.៦.១. ក្រុមប្រឹក្សាភិបាល................................................................................................២៤

២.៦.២. រចនាសម្ព័ន្ធចាត់តាំង............................................................................................២៥

២.៦.៣.អាណត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា ...................................................................២៥

២.៧. តួនាទី និងភារកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា...................................................... ២៦

២.៧.១. តួនាទី និងភារកិច្ចរួមរបស់គណៈកម្មការមូលបត្រកម្ពុជា.......................................... ២៦

២.៧.២. តួនាទី និងភារកិច្ចនាយកដ្ឋានរបស់គណៈកម្មការមូលបត្រកម្ពុជា ............................ ២៦

២.៧.២.១. នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ.............................................................. ២៦

២.៧.២.២. នាយកដ្ឋានត្រួតពិនិត្យការបោះផ្សាយលក់មូលបត្រ ........................................ ២៧

២.៧.២.៣. នាយកដ្ឋានត្រួតពិនិត្យផ្សារមូលបត្រ............................................................. ២៨

២.៧.២.៤. នាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល អភិវឌ្ឍទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ.............................................................................................................. ២៨

២.៧.២.៥. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ....................................................... ២៩
២.៧.២.៦. នាយកដ្ឋានកិច្ចការគតិយុត្ត ........................................................................ ២៩
២.៧.២.៧. អង្គភាពសវនកម្មផ្ទៃក្នុង ............................................................................. ៣០

## ជំពូកទី៣

## ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

៣.១. នាមករណ៍ និង ផ្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ............................................... ៣៣
៣.១.១. នាមករណ៍ ......................................................................................................... ៣៣
៣.១.២. ផ្លាកសញ្ញា និង អត្ថន័យ ................................................................................... ៣៣
៣.២. ប្រវត្តិក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ................................................................................ ៣៤
៣.៣. ចក្ខុវិស័យ និង បេសកកម្មក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ................................................ ៣៥
៣.៣.១. ចក្ខុវិស័យ ....................................................................................................... ៣៥
៣.៣.២. បេសកកម្ម ....................................................................................................... ៣៥
៣.៤. រចនាសម្ព័ន្ធគ្រប់គ្រង និង ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា...................... ៣៦
៣.៥. តួនាទី និងភារកិច្ចរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ...................................................... ៣៧

## ជំពូកទី៤

## ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា

៤.១. ដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង............................ ៣៩
៤.១.១. លក្ខខណ្ឌនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ ................................... ៣៩
៤.១.១.១. លក្ខខណ្ឌបរិមាណ................................................................................. ៣៩
៤.១.១.២. លក្ខខណ្ឌគុណភាព ................................................................................ ៤០
៤.១.២. ឯកសារតម្រូវក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ........................ ៤០
៤.១.២.១. ការដាក់ពាក្យស្នើសុំ ............................................................................... ៤០
៤.១.២.២. ការដាក់ឯកសារផ្តល់ព័ត៌មាន.................................................................. ៤១
៤.២. នីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើដំបូង.................................... ៤៣

៤.២.១. ការដាក់លិខិតសម្តែងឆន្ទៈ........................................................................................... ៤៣
៤.២.២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ ....................................................................... ៤៤
៤.២.៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រជាសាធារណៈ.................................. ៤៤
៤.២.៤. ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់........................................................... ៤៤
៤.២.៥. ការដាក់ពាក្យស្នើសុំទៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ................................................ ៤៤
៤.២.៦. ការដាក់ពាក្យស្នើសុំទៅគណៈកម្មការមូលបត្រកម្ពុជា ................................................ ៤៥
៤.២.៧. ការកំណត់តម្លៃមូលបត្រតាមរយៈប៊ុកបៀលឌីង............................................................ ៤៥
៤.២.៨. ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពី ផ.ម.ក........................................................ ៤៦
៤.២.៩. ការស្នើសុំអនុញ្ញាតលើលក្ខខណ្ឌសំណើលក់ទៅ គ.ម.ក .............................................. ៤៦
៤.២.១០. ការធ្វើបរិវិសកម្មមូលបត្រ........................................................................................ ៤៦
៤.២.១១. ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្ម ........................................................ ៤៦
៤.២.១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការទៅ ផ.ម.ក.............................................................. ៤៦
៤.៣. ប្រតិបត្តិការនៃការជួញដូរមូលបត្រក្នុងទីផ្សារដំបូង........................................................... ៤៧
៤.៣.១. ដំណាក់កាលនៃការស្ទាបស្ទង់ថ្លៃ ឬប៊ុកបៀលឌីង ......................................................... ៤៧
៤.៣.២. ដំណាក់កាលសុំចុះឈ្មោះទិញមូលបត្រ ឬ បរិវិសកម្ម .................................................. ៤៩
៤.៤. ប្រតិបត្តិការនៃការជួញដូរមូលបត្រលើទីផ្សារបន្ទាប់ .......................................................... ៥០
៤.៤.១. នីតិវិធីសំខាន់ៗមុនធ្វើការជួញដូរ.................................................................................. ៥០
៤.៤.១.២. ការស្នើសុំអត្តសញ្ញាណវិនិយោគិន....................................................................... ៥២
៤.៤.១.៣. ការបើកគណនីជួញដូរ........................................................................................... ៥២
៤.៤.១.៤. ការបើកគណនីសាច់ប្រាក់........................................................................................ ៥២
៤.៤.១.៥. ការដាក់បញ្ជា.......................................................................................................... ៥៣
៤.៤.២. វិធាននៃប្រតិបត្តិការជួញដូរលើទីផ្សារ............................................................................ ៥៣
៤.៤.២.១. ពេលវេលានៃការជួញដូរ ....................................................................................... ៥៣
៤.៤.២.២. ឯកតាបញ្ជា និងឯកតាគម្លាត.................................................................................. ៥៤

៤.៤.២.៣. ដែនកំណត់នៃការប្រែប្រួលថ្លៃមូលបត្រ ......................................................... ៥៥
៤.៤.២.៤. គោលការណ៍ដេញថ្លៃ ......................................................... ៥៥
៤.៤.២.៥. ថ្លៃពិសេស ......................................................... ៥៨
៤.៤.៣. ដំណើរការនៃការជួញដូរមូលបត្រក្នុងទីផ្សារបន្ទាប់ ......................................................... ៥៨
៤.៤.៤. យន្តការនៃការផាត់ទាត់ និងទូទាត់ ......................................................... ៦០
៤.៤.៤.១. ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់សាច់ប្រាក់ ......................................................... ៦១
៤.៤.៤.២. ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់មូលបត្រ ......................................................... ៦២
៤.៤.៤.៣. ដំណើរការផាត់ទាត់ ......................................................... ៦៣
៤.៤.៤.៤. ដំណើរការទូទាត់ ......................................................... ៦៤
៤.៤.៥. យន្តការនៃការរក្សាទុកមូលបត្រ ......................................................... ៦៦

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ......................................................... ៦៩
២. ការផ្តល់អនុសាសន៍ ......................................................... ៧០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- **គ.ម.ក** = គណៈកម្មការមូលបត្រកម្ពុជា
- **ផ.ម.ក** = ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- SECC = Securities and Exchange Commission Cambodia
- CSX = Cambodia Securities Exchange
- NBC = National Bank of Cambodia
- CSD = Central Securities Depository
- SF = Securities Firm
- IPO = initial Public Offering
- CSA = Cash Securities Exchange
- CSO = Clearing and Settlement Operator
- OTC = Over the Counter

# បញ្ជីតារាង

តារាងទី ៤.១៖ ឯកតាជូញដូរ និងឯកតាគម្លាតថ្លៃ ..... ៥៤
តារាងទី ៤.២៖ គោលការណ៍ដេញថ្លៃយកថ្លៃតែមួយ ..... ៥៥
តារាងទី ៤.៣៖ គោលការណ៍ដេញថ្លៃយកថ្លៃច្រើន ..... ៥៦
តារាងទី ៤.៤៖ គោលការណ៍ដេញថ្លៃករណីបញ្ជាទិញព្រមគ្នា ..... ៥៧
តារាងទី ៤.៥៖ ការគណនាបរិមាណជូញដូរដោយបញ្ជាទិញព្រមគ្នា ..... ៥៧

# បញ្ជីរូបភាព

រូបភាពទី ២.១៖ រូបសញ្ញា និងអត្ថន័យនៃគ.ម.ក ........ ២០
រូបភាពទី ២.២៖ ត្រារបស់គ.ម.ក ........ ២២
រូបភាពទី ២.៣៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ គ.ម.ក ........ ២៥
រូបភាពទី ៣.១៖ រូបសញ្ញារបស់ផ.ម.ក ........ ៣៣
រូបភាពទី ៣.២៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ផ.ម.ក ........ ៣៦
រូបភាពទី ៣.៣៖ ក្រុមប្រឹក្សាភិបាលរបស់ផ.ម.ក ........ ៣៧
រូបភាពទី ៤.១៖ ពេលវេលានៃការជួញដូរ (ម៉ោងជួញដូរ និងថ្ងៃជួញដូរ) ........ ៥៤
រូបភាពទី ៤.២៖ គំនូសតាងដំណើរការជួញដូរ ........ ៥៩

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
ឧបសម្ព័ន្ធទី២៖ ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
ឧបសម្ព័ន្ធទី៣៖ ពាក្យស្នើសុំធ្វើប៊ុកបៀលឌីង
ឧបសម្ព័ន្ធទី៤៖ ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបានចូលរួមធ្វើប៊ុកបៀលឌីង
ឧបសម្ព័ន្ធទី៥៖ ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលមិនបានចូលរួមធ្វើប៊ុកបៀលឌីង
ឧបសម្ព័ន្ធទី៦៖ ប្រកាសស្តីពី ការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
ឧបសម្ព័ន្ធទី៧៖ ប្រកាសស្តីពី ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានលក់មូលបត្រកម្មសិទ្ធិ
ឧបសម្ព័ន្ធទី៨៖ គោលការណ៍ណែនាំស្តីពី ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន
ឧបសម្ព័ន្ធទី៩៖ គោលការណ៍ណែនាំស្តីពី យន្តការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
ឧបសម្ព័ន្ធទី១០៖ គោលការណ៍ណែនាំស្តីពី ការធ្វើប៊ុកបៀលឌីង និងធ្វើបរិវិសកម្មមូលបត្រ

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

សេដ្ឋកិច្ចប្រទេសកម្ពុជានៅតែបន្តកើនឡើង ស្របពេលដែលសេដ្ឋកិច្ចពិភពលោកត្រូវបានធនាគារពិភពលោកព្យាករណ៍ថានឹងនៅតែបន្តបន្ថយល្បឿននៃការកើនឡើង និងមានហានិភ័យកើនឡើងនៅក្នុងទស្សវត្សចុងក្រោយនេះ។ ប្រទេសកម្ពុជាមានល្បឿនកំណើនសេដ្ឋកិច្ចខ្លាំងបំផុតក្នុងចំណោមសេដ្ឋកិច្ចរបស់បណ្តាប្រទេសផ្សេងៗប្រចាំតំបន់ ដែលមានការកើនឡើង ៧.២% នៅក្នុងឆ្នាំ២០១៨ លើសបណ្តាប្រទេសទាំងអស់ក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលកំពុងឈានជំហានទៅមុខជាលំដាប់[1]។ ការស្ទុះឡើងនូវសេដ្ឋកិច្ចយ៉ាងខ្លាំងនេះ ជាហេតុដែលនាំឲ្យបង្កើតបាននូវបរិយាកាសដ៏ល្អ សម្រាប់ការទាក់ទាញវិនិយោគិនយ៉ាងសន្ធឹកសន្ធាប់ទាំងក្នុងប្រទេស និងក្រៅប្រទេស មកធ្វើការបណ្តាក់ទុនវិនិយោគលើគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា។ ការដាក់ចេញនូវយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៦-២០២៥ របស់រាជរដ្ឋាភិបាល រួមទាំងការខិតខំ ប្រឹងប្រែងយកចិត្តទុកដាក់លើកកម្ពស់ និងអភិវឌ្ឍន៍នូវវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេស ដែលជាហេតុនាំឲ្យវិស័យហិរញ្ញវត្ថុកាន់តែរីកចម្រើនគ្រប់វិស័យ ទាំងវិស័យធនាគារ វិស័យធានារ៉ាប់រង ជាពិសេសដែលគួរឲ្យកត់សម្គាល់ថាកំពុងតែមានសន្ទុះនោះគឺ វិស័យមូលបត្រ។ ម្យ៉ាងវិញទៀតនោះ ប្រទេសកម្ពុជាអាចចាត់ទុកជាទីផ្សារដ៏វ័យក្មេងមួយនៅក្នុងវិស័យមូលបត្រនេះ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសផ្សេងៗទៀតនៅក្នុងតំបន់ និងបណ្តាប្រទេសក្នុងសកលលោក ដែលជាហេតុដែលធ្វើឲ្យវិនិយោគិនរំពឹងថាជាឱកាសក្នុងការទទួលបាននូវផលចំណេញច្រើន។

ដើម្បីធានាភាពរលូននៃដំណើរការរបស់ទីផ្សារមូលបត្រកម្ពុជា រាជរដ្ឋាភិបាលបានបង្កើតឡើងនូវគណៈកម្មការមូលបត្រ (គ.ម.ក) ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងការតាក់តែងច្បាប់ ស្តីពីការប្រព្រឹត្តិទៅនៃផ្សារមូលបត្រ លក្ខខណ្ឌនៃការចូលរួមវិនិយោគក្នុងវិស័យមូលបត្រ នីតិវិធីក្នុងការបោះផ្សាយលក់មូលបត្រ នីតិវិធីក្នុងការជួញដូរមូលបត្រ និងផ្សព្វផ្សាយព័ត៌មានជាសាធារណៈតាមរយៈបណ្តាញសង្គម និងគេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា។ រួមទាំងបង្កើតឡើងនូវក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាដែលជាដៃគូសហការជាមួយគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងដើរតួនាទីជាប្រតិបត្តិករនៃផ្សារមូលបត្រដើម្បីឲ្យវិស័យនេះកាន់តែបោះជំហ៊ានទៅមុខជាលំដាប់។ បើយោងតាមការសង្កេតតាមរយៈពត៌មានតាមបណ្តាញសង្គមផ្សេងៗ យើងសង្កេតឃើញថាវិស័យមូលបត្រ នៅកម្ពុជានាពេលបច្ចុប្បន្នកំពុងតែមានការចាប់អារម្មណ៍ខ្លាំងពីសំណាក់ វិនិយោគិន

[1] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៨), ការព្យាករណ៍លើកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាឆ្នាំ ២០១៨

គ្រប់ជាន់ថ្នាក់ និងរួមទាំងក្រុមហ៊ុនឯកជនផងដែរ។ ដែលជាហេតុនាំឲ្យវិនិយោគិន ព្រមទាំងសាធារណៈជន ចង់ដឹងចង់លឺពីប្រតិបត្តិការក្នុងទីផ្សារមូលបត្រមួយនេះ ព្រមទាំងដំណើរការនៃការជួញដូរមូលបត្រនេះផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

មូលធន គឺជាកត្តាលីករដ៏សំខាន់នៅក្នុងការបង្កើតនូវអាជីវកម្មមួយ ឬសម្រាប់ប្រកបនូវមុខរបររកស៊ីអ្វីមួយ នៅក្នុងការគៀងគរនូវមូលធននេះ គឺត្រូវពឹងផ្អែកទៅលើវិស័យមូលបត្រដើម្បីជាមធ្យោបាយក្នុងការប្រមូលសម្រាប់វិនិយោគិន។

ទោះបីប្រទេសកម្ពុជាបានដំណើរការនូវផ្សារមូលបត្រអស់រយៈពេល ៧ឆ្នាំមកហើយរួមទាំងមានការជ្រោមជ្រែងពីសំណាក់រាជរដ្ឋាភិបាលក្នុងការពង្រីកនូវវិស័យមូលបត្រនេះក៏ពិតមែន ប៉ុន្តែយើងក៏នៅតែសង្កេតឃើញថា វិស័យមូលបត្រនេះនូវមានកម្រិត និងជួបនូវផលវិបាកមួយចំនួនដែលកំពុងតែជួបប្រទះ។ ម៉្យាងវិញទៀត ប្រជាជនកម្ពុជាពុំទាន់មានការយល់ដឹងច្បាស់ពី អ្វីទៅជាទីផ្សារមូលបត្រ? តើពួកគេត្រូវការលក្ខខណ្ឌអ្វីខ្លះសម្រាប់ការវិនិយោគលើវិស័យមួយនេះ? រួមទាំងនីតិវិធីដ៏ស៊ាំញ៉ាំ នៅក្នុងដំណើរការនៃការជួញដូរ ចាប់ពីទីផ្សារដំបូង រហូតដល់ទីផ្សារបន្ទាប់។ ដោយហេតុដែលខ្ញុំបានសង្កេតឃើញនូវកង្វះខាតទាំងនេះ ហើយទើបខ្ញុំបាទ សម្រេចចិត្តជ្រើសរើសយកនូវប្រធានបទ "ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា" ដើម្បីដោះស្រាយនូវចម្ងល់របស់សាធារណៈជន រួមទាំងវិនិយោគិនដែលមានបំណងចង់វិនិយោគទៅលើវិស័យមូលបត្រមួយនេះ។ ដើម្បីសម្រេចបំណងនៃការស្រាវជ្រាវនេះ ប្រកបទៅដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល ខ្ញុំបានបង្កើតនូវសំណួរដូចខាងក្រោម៖

តើប្រតិបត្តិការនៅក្នុងទីផ្សារមូលបត្រប្រទេសកម្ពុជាប្រព្រឹត្តិទៅយ៉ាងដូចម្តេច?

- តើដំណើរនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងទីផ្សារមូលបត្រកម្ពុជាប្រព្រឹត្តិទៅយ៉ាងដូចម្តេចដែរ?
- តើដំណើរការនៃការទិញលក់មូលបត្រយ៉ាងដូចម្តេច?
- នីតិវិធី និង លក្ខខណ្ឌក្នុងការជួញដូរមូលបត្រ?
- អ្វីទៅជាការជួញដូរនៅក្នុងទីផ្សារដំបូង និងទីផ្សារបន្ទាប់ ហើយវាមានលក្ខណៈដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើប្រតិបត្តិការបោះផ្សាយលក់មូលបត្រ និងការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជា តាំងពីដំណាក់កាលបោះផ្សាយលក់មូលបត្រជាលើកដំបូង រហូតដល់ដំណាក់កាលជួញដូរក្នុងទីផ្សារបន្ទាប់ ក្រុមហ៊ុនចូលរួមក្នុងវិស័យមូលបត្រ និងតួអង្គសំខាន់ៗផ្សេងៗទៀតដែលមានតួនាទីនៅក្នុងដំណើរការជួញដូរមូលបត្រ។

គោលបំណងនៃការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើចំណុចសំខាន់ៗដូចខាងក្រោមះ

- សិក្សាឲ្យកាន់តែស៊ីជម្រៅលើប្រតិបត្តិការក្នុងទីផ្សារមូលបត្រកម្ពុជា
- ស្វែងយល់ពីដំណើរការនៃការជួញដូរមូលបត្រ និងការបោះផ្សាយលក់មូលបត្រ
- ស្វែងយល់ពីគណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ស្វែងយល់ពីនីតិវិធីនិងលក្ខខណ្ឌចាំបាច់ក្នុងការជួញដូរមូលបត្រនៅក្នុងផ្សារមូលបត្រកម្ពុជា
- សិក្សាពីប្រតិបត្តិការទិញ លក់មូលបត្រក្នុងទីផ្សារដំបូង និងទីផ្សារបន្ទាប់។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ជាក់ស្តែង បើតាមស្ថានភាពមូលបត្រក្នុងប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្នបានកំពុងតែរីកចម្រើនគួរឲ្យកត់សម្គាល់ ក៏ប៉ុន្តែការវិវត្តន៍នៃវិស័យមួយនេះ ពុំទាន់មានលក្ខណៈរីកលូតលាស់ខ្លាំងដូចបណ្តាប្រទេសដទៃនៅឡើយទេ។ ដោយហេតុថា ផ្សារមូលបត្រកម្ពុជាមានភាពវ័យក្មេងបើប្រៀបធៀបទៅនឹងបណ្តាប្រទេសដទៃ ទើបចំណេះដឹងនៃវិស័យមូលបត្រមួយនេះនូវមានកម្រិត និងមិនទាន់មានភាពទូលំទូលាយដូចបណ្តាប្រទេសដទៃនៅឡើយ។ ដោយផ្សារមូលបត្រកម្ពុជាបានបើកសម្ពោធឲ្យដំណើរការនៅថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ដូចនេះហើយទើបខ្ញុំសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវដោយផ្តោតសំខាន់ទៅលើ "ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា" ក្នុងកំឡុងពេល៧ឆ្នាំចុងក្រោយ ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៩។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ លើប្រធានបទមួយនេះ គឺពិតជាមានសារៈសំខាន់ និងបានផ្តល់នូវផលប្រយោជន៍ និងពុទ្ធិជាច្រើនរួមមានះ

- ចំពោះខ្ញុំផ្ទាល់
  - ផ្តល់ជាចំណេះដឹងឲ្យកាន់តែស៊ីជម្រៅលើវិស័យមូលបត្រនៅកម្ពុជា បច្ចេកទេសនិយមន័យ និងសកម្មភាពរបស់ គ.ម.ក និង ផ.ម.ក ចំពោះវិស័យមូលបត្រនេះ។

- បង្កើននូវសមត្ថភាពនៅក្នុងការទំនាក់ទំនងជាមួយបុគ្គលសំខាន់ៗ សមត្ថភាពនៅក្នុងការស្រាវជ្រាវ ការប្រមូលនូវឯកសារ ទិន្នន័យផ្សេងៗ ដើម្បីចងក្រងឡើងនូវឯកសារសារណានេះឡើងមក។
- ចេះសិក្សា និងវិភាគលើទិន្នន័យដែលទទួលបាន និងចេះរៀបចំឯកសារឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ជាពិសេសមានទំនួលខុសត្រូវលើកិច្ចការរបស់ខ្លួន។

➢ ចំពោះសិស្សនិស្សិត

- ជាទុនក្នុងការយកទៅសិក្សាបន្ថែម និងស្វែងយល់បន្ថែមទៅលើប្រធានបទនេះសំខាន់អាចជាឯកសារសម្រាប់ជាជំនួយនៅក្នុងការសិក្សាដើម្បីត្រៀម ប្រលងប្រជែងផ្សេងៗ រួមទាំងការប្រលងចូលបម្រើការងារក្នុងវិស័យមូលបត្រនៅស្ថាប័ន និងក្រុមហ៊ុនផ្សេងៗ។
- រំលឹកនូវទ្រឹស្តី ពាក្យបច្ចេកទេស និងគន្លឹះសំខាន់ៗក្នុងដំណើរការក្នុងទីផ្សារមូលបត្រកម្ពុជា។

➢ ចំពោះគណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

- ឯកសារនៃការស្រាវជ្រាវមួយនេះ អាចផ្តល់ជាពុទ្ធិដល់ស្ថាប័ន ដើម្បីឲ្យប្រសើរឡើងនូវចំណុចខ្វះខាតមួយចំនួន ដែលស្ថាប័នបានជួបប្រទះដែលចោទជាបញ្ហាទៅលើការប្រព្រឹត្តិទៅនៃផ្សារមូលបត្រកម្ពុជានាពេលបច្ចុប្បន្ន។

➢ ចំពោះមជ្ឈដ្ឋានទូទៅ

- ជាឯកសារ និងជាចំណេះដឹងសម្រាប់សាធារណៈជនដែលមានបំណងចង់វិនិយោគលើផ្សារមូលបត្រនេះ ដើម្បីឲ្យយល់ច្បាស់មុននឹងធ្វើការសម្រេចចិត្តចូលប្រលូកនៅក្នុងផ្សារមួយនេះ និងដើម្បីឲ្យកាន់តែយល់ឲ្យស៊ីជម្រៅពីដំណើរការ នីតិវីធី និងលក្ខខណ្ឌក្នុងការជួញដូរក្នុងផ្សារមូលបត្រ។

## ៦. វិធីសាស្រ្តនៃការស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យទាំងអស់នេះ មកចងក្រងជារបាយការណ៍សារណានេះឡើង ខ្ញុំបាទបានធ្វើការស្រាវជ្រាវតាមប្រភេទទិន្នន័យបែបគុណភាព និងផ្អែកលើវិធីសាស្រ្ត ២យ៉ាងក្នុងការប្រមូលទិន្នន័យនេះ។ វិធីសាស្រ្តទាំង ២ប្រភេទនោះគឺ៖

### ៦.១. ទិន្នន័យចម្បង

- ការណែនាំ និងចង្អុលបង្ហាញពីសំណាក់សាស្រ្តចារ្យណែនាំ

- ការបកស្រាយ និងការណែនាំយ៉ាងលម្អិតពីអ្នកជំនាញក្នុងវិស័យនេះ ដែលបម្រើការងារនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

### ៦.២. ទិន្នន័យបន្ទាប់បន្សំ

- ឯកសារច្បាប់ អនុក្រឹត្យ និងឯកសារពាក់ព័ន្ធដែលទទួលបានពី គណៈកម្មការមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឯកសារទាក់ទងនឹងប្រធានបទតាមរយៈការណែនាំរបស់សាស្ត្រចារ្យណែនាំ
- ព័ត៌មានដែលទទួលបានពីគេហទំព័ររបស់ គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងក្រុមហ៊ុនមូលបត្រផ្សេងទៀត
- ទិន្នន័យដែលស្វែងរកតាមប្រព័ន្ធអ៊ីនធើណែត
- និក្ខេបបទ របាយការណ៍កម្មសិក្សា និងសារណាបញ្ចប់ការសិក្សារបស់និស្សិតរាមច្បង ដែលពាក់ព័ន្ធនឹងប្រធានបទ

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជាជំនួយដល់អ្នកអានសម្រាប់ស្វែងរកនូវខ្លឹមសារនៃប្រធានបទ និងងាយស្រួលយល់ពីអត្ថន័យ និងគំនិតសំខាន់ក្នុងរបាយការណ៍សារណានេះ ការសិក្សាលើប្រធានបទស្តីពី "ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា"នេះ ត្រូវបានបែងចែកជា ៤ជំពូកៈ

- សេចក្តីផ្តើម
- ជំពូកទី១ៈ រំលឹកទ្រឹស្តីទាក់ទងនឹងទីផ្សារមូលបត្រ
- ជំពូកទី២ៈ គណៈកម្មការមូលបត្រកម្ពុជា
- ជំពូកទី៣ៈ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ជំពូកទី៤ៈ ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា
- សេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍

# ជំពូកទី១

# រំលឹកទ្រឹស្តីទាក់ទងនឹងទីផ្សារមូលបត្រ

# ជំពូកទី១
# រំលឹកទ្រឹស្តីទាក់ទងនឹងទីផ្សារមូលបត្រ

## ១.១. ទីផ្សារមូលបត្រ

ផ្សារមូលបត្រដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចប្រទេសមួយ ដែលវាអនុញ្ញាតឲ្យក្រុមហ៊ុនសាជីវកម្ម សហាគ្រាសសាធារណៈ និងរដ្ឋាភិបាលអាចប្រមូលទុនដោយផ្ទាល់ពីសាធារណៈជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាដើម។ ម្យ៉ាងវិញទៀត អ្នកដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការធ្វើពិពិធកម្មសំណុំវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំ (ជាមួយមូលបត្រដែលមានហានិភ័យទាប) នៅក្នុងទីផ្សារមូលបត្រ។ នៅពេលដែលសាច់ប្រាក់ហូរពីអ្នកដែលមានប្រាក់ទៅអ្នកដែលត្រូវការប្រាក់ប្រកបដោយប្រសិទ្ធិភាព ពេលនោះសកម្មភាពសេដ្ឋកិច្ចដូចជាផលិតកម្ម និងពាណិជ្ជកម្ម និងរីកលូតលាស់ទៅតាមនោះផងដែរ ព្រមទាំងបង្កើតឲ្យមានការងារ និងទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅ។

### ១.១.១. ប្រវត្តិទីផ្សារមូលបត្រ

ទស្សនៈសម័យទំនើបនៃការបង្កើតទីផ្សារភាគហ៊ុន បានចាប់ផ្តើមតាំងពីចុងសតវត្សទី16។ ទីផ្សារភាគហ៊ុនត្រូវបានចាប់ផ្តើមនៅពេលបណ្តាប្រទេសនៅក្នុងទ្វីបអាមេរិក (The New World) បានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀតដែលមានដូចជាហូឡង់ ព័រទុយហ្គាល់ និងអេស្ប៉ាញ។ ខណៈពេលដែលឈ្មួញធំៗនៅអឺរ៉ុបមានបំណងចាប់ផ្តើមអាជីវកម្មទំហំធំដែលទាមទារឲ្យមានចំនួន ទឹកប្រាក់ច្រើន ពុំមានឈ្មួញណាម្នាក់ មានប្រាក់ច្រើនសន្ធឹកសន្ធាប់សម្រាប់ចាប់ផ្តើមអាជីវកម្មដ៏ធំតែម្នាក់ឯងបាននោះទេ។ ជាលទ្ធផល វិនិយោគិន បានយកប្រាក់សន្សំរបស់ពួកគេទៅដាក់ទុនរួម ហើយបានក្លាយជាដៃគូអាជីវកម្ម និងជាសហកម្មសិទ្ធិជាមួយនឹងចំណែកភាគហ៊ុនរបស់ខ្លួននៅក្នុងអាជីវកម្មមួយដែលមានទម្រង់រួមទុន។ ក្រុមហ៊ុនរួមទុនដែលមានដើមកំណើតនៅប្រទេសហូឡង់បានក្លាយជាគំរូអាជីវកម្មមួយសម្រាប់អាជីវកម្មដទៃដែលកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ១៦០២ ក្រុមហ៊ុន ឌឺ ឌាចហ៍ អីស ឥណ្ឌា (The Dutch East India Co.) បានបោះផ្សាយក្រដាសតំណាងភាគហ៊ុនជាលើកដំបូង។ ឧបករណ៍ដែលអាចជួញដូរបាននេះ អនុញ្ញាតឲ្យភាគហ៊ុនិកមានភាពងាយស្រួលក្នុងការទិញ-លក់ និងធ្វើការជួញដូរភាគហ៊ុនរបស់ខ្លួនជាមួយនឹងម្ចាស់ភាគហ៊ុនផ្សេងៗ និងវិនិយោគិនដទៃទៀត។

គំនិតនេះ ទទួលបានជោគជ័យដោយការលក់ភាគហ៊ុនបានរីករាលដាលដល់ប្រទេស មហាអំណាចដែនសមុទ្រផ្សេងទៀតដូចជាប្រទេសព័រទុយហ្គាល់ អេស្ប៉ាញ និងបារាំង។ នៅទីបំផុតការ

អនុវត្តគំនិតនេះក៏បានរីករាលដាលដល់ចក្រភពអង់គ្លេស។ ឧស្សាហកម្មដទៃទៀតក្នុងកំឡុងពេលបដិវត្តន៍ឧស្សាហកម្ម បានចាប់ផ្ដើមប្រើការលក់ភាគហ៊ុនជាវិធីដើម្បីប្រមូលមូលធនសម្រាប់ធ្វើអាជីវកម្ម។ ការហូរចូលនៃមូលធននេះ បានបន្តឱ្យមានការរកឃើញ និងការអភិវឌ្ឍនៃពិភពលោកថ្មី (The New World) និងការរីកលូតលាស់នៃឧស្សាហកម្មសម័យទំនើប។

ការកើនឡើងនូវបរិមាណជួញដូរភាគហ៊ុន បានជំរុញឱ្យមានការបង្កើតទីកន្លែងច្បាស់លាស់មួយសម្រាប់ជួញដូរ។ ជាលទ្ធផល ពាណិជ្ជករភាគហ៊ុនបានសម្រេចចិត្តទៅជួបគ្នានៅហាងកាហ្វេមួយនៅទីក្រុងឡុងដ៍។ ក្រោយមក ហាងកាហ្វេនោះត្រូវបានពាណិជ្ជករភាគហ៊ុនទិញយក ហើយប្រែឈ្មោះក្លាយជាទីផ្សារភាគហ៊ុនដែលមានការរៀបចំ និង គ្រប់គ្រងត្រឹមត្រូវនៅក្នុងឆ្នាំ១៧៧៣។ ទីផ្សារភាគហ៊ុនទីក្រុងឡុងដ៍ (The London Stock Exchange) ជាទីផ្សារភាគហ៊ុនផ្លូវការដំបូងគេ។ គំនិតនៃការរៀបចំបែបនេះ ក៏បានហូរចូលទៅក្នុងប្រទេសអាមេរិក ហើយក៏បានចាប់ផ្ដើមនៅទីក្រុងភីឡាដែលភីយ៉ា (Philadelphia) ក្នុងឆ្នាំ១៧៩០[2]។

### ១.១.២. និយមន័យនៃផ្សារមូលបត្រ

ទីផ្សារមូលបត្រ គឺជាកន្លែងសម្រាប់ធ្វើនូវប្រតិបត្តិការទិញ និងលក់មូលបត្រគ្រប់ប្រភេទ។ វាអាចជាទីផ្សាររូបីឬ ជាទីផ្សារអរូបិយដែលជួញដូរអាចតាមរយៈប្រព័ន្ធអេឡិចត្រូនិច[3]។

តាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្ដល់មធ្យោបាយ នៃការធ្វើសំណើលក់ ផ្ទេរឬ ស្នើការទិញ លក់មូលបត្រ[4]។

## ១.២. ប្រភេទនៃទីផ្សារមូលបត្រ

### ១.២.១. ទីផ្សារដំបូង

ទីផ្សារដំបូង គឺជាកន្លែងដែលមូលបត្រត្រូវបានដាក់លក់ជាលើកទីមួយទៅឲ្យវិនិយោគិដែលការទិញមូលបត្រនេះត្រូវទិញដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយ។ ឬក៏អាចឲ្យនិយមន័យមួយទៀតថា ទីផ្សារដំបូងជាទីផ្សារដែលភាគហ៊ុន (ទើបបោះផ្សាយជាសាធារណៈលើកដំបូងដោយក្រុមហ៊ុនមួយ) ត្រូវបានដាក់ឲ្យជួញដូរជាលើកដំបូង។ បានសេចក្ដីថា ជាទីផ្សារដែលវិនិយោគិនសាធារណៈ

---

[2] London Stock Exchange Group, https://www.lseg.com/ (ចូលទស្សនាថ្ងៃ១៥ មិថុនា ២០១៩)

[3] សៀវ សុស៊ីខា, ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រ, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

[4] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/០១០៧/០២៨, ២៣ តុលា ២០០៧, សន្ធានុក្រម

ទិញភាគហ៊ុនដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយ គឺប្រៀបបាននឹងការទិញទំនិញមួយដោយអ្នកប្រើប្រាស់ដោយផ្ទាល់ពីក្រុមហ៊ុនផលិតដូច្នោះដែរ។ ទីផ្សារដំបូងអនុវត្តន៍នូវមុខងារសំខាន់សម្រាប់ទីផ្សារមូលធននោះ គឺជាមុខងារសេដ្ឋកិច្ច មានន័យថាលំហូរចូលមូលធនពីអ្នកដែលមានមូលធនលើស ទៅឲ្យអ្នកដែលមានតម្រូវការមូលធន ឬការគៀងគរមូលធនដែលទំនេរយកទៅធ្វើការវិនិយោគបន្ថែម។ សរុបជារួមមក ទីផ្សារដំបូងជាកន្លែងទិញ លក់បណ្តាមូលបត្រដែលទើបនឹងបោះផ្សាយរវាងអ្នកបោះផ្សាយលក់មូលបត្រ (អ្នកលក់) និងអ្នកវិនិយោគ (អ្នកទិញ)។

### ១.២.២. ទីផ្សារបន្ទាប់

វិនិយោគិនដែល ទិញភាគហ៊ុននៅទីផ្សារដំបូង ហើយចង់លក់ភាគហ៊ុននោះចេញដើម្បីយកសាច់ប្រាក់មកវិញ ត្រូវលក់ភាគហ៊ុននោះទៅឲ្យវិនិយោគិនដទៃទៀតដែលចង់ទិញភាគហ៊ុនរបស់ខ្លួន គឺមិនមែនលក់ទៅឲ្យក្រុមហ៊ុនបោះផ្សាយវិញទេ ។ ការទិញលក់តទៅនេះ រវាងវិនិយោគិន (អ្នកទិញ) និងវិនិយោគិន (អ្នកលក់) ត្រូវបានគេហៅថា ជាការទិញលក់នៅទីផ្សារបន្ទាប់ គឺប្រៀបបាននឹងការជួញដូរវត្ថុជជុះរវាងអ្នកប្រើប្រាស់ដូចគ្នា ដូច្នោះដែរ គ្រាន់តែភាគហ៊ុនមិនចេះសឹករេចរឹលប៉ុណ្ណោះ។ ការជួញដូរនៅទីផ្សារបន្ទាប់ គឺធ្វើឡើងនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ផ.ម.ក. មានតួនាទីចម្បងក្នុងការផ្តល់សេវាទីកន្លែងនិងប្រព័ន្ធជួញដូរ សម្រាប់វិនិយោគិនងាយស្រួលរកគ្នាឃើញ (អ្នកលក់ និងអ្នកទិញ) ដើម្បីជួញដូរជាមួយគ្នា ។

នៅលើទីផ្សារបន្ទាប់ គេប្រើប្រាស់ប្រតិបត្តិការតាម ២ វិធី៖

- Organized Exchanged Market: ប្រតិបត្តិការតាមមូលដ្ឋានជួញដូរ គឺជាមជ្ឈដ្ឋានជួញដូរមានទីតាំងត្រឹមត្រូវ មានវិធាន និងបទបញ្ញត្តិសម្រាប់គ្រប់គ្រងឲ្យត្រឹមត្រូវ។
- Over-the-Counter Market: តាមរយៈការទិញ លក់មូលបត្រដែលធ្វើការជួញដូរមូលបត្រនៅទីកន្លែងផ្សេងគ្នា និងក្នុងតម្លៃព្រមព្រៀងគ្នា។ ទីផ្សារនេះមិនមានវិធាន និងបទបញ្ញត្តិគ្រប់គ្រងដូច Organized Exchanged Market ទេ។

### ១.២.៣. ទីផ្សាររូបិយបណ្ណ

ទីផ្សាររូបិយវត្ថុ (Money Market) គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរមូលបត្ររយៈពេលខ្លីតិចជាងមួយឆ្នាំ ដែលមានដូចជា ប័ណ្ណរតនាគារ ផលបត្រពាណិជ្ជកម្ម Banker Acceptance ជាដើម។ ទីផ្សាររូបិយប័ណ្ណបានក្លាយជាផ្នែកមួយនៃទីផ្សារហិរញ្ញវត្ថុសម្រាប់ការទិញ និងលក់មូលបត្រដែលមាន រយៈពេលខ្លីរយៈពេលមួយឆ្នាំ ឬ តិចជាងដូចជាវិក័យប័ត្ររតនាគារនិងឯកសារពាណិជ្ជកម្ម។

**១.២.៤.ទីផ្សារមូលធន**

ទីផ្សារមូលធន (Capital Market) គឺជាទីផ្សារហិរញ្ញវត្ថុដែលអ្នកលក់ និង អ្នកទិញជួញដូរនូវភាគហ៊ុន បណ្ណបំណុល រូបិយបណ្ណអន្តរជាតិ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលមានឥណប្រតិទានរយៈពេលមួយឆ្នាំ ឬច្រើនជាងមួយឆ្នាំ។ ទីផ្សារមូលធននេះ ជាកន្លែងដែលជួយប្រមូលនូវមូលធនពីអ្នកដែលមានមូលធន ទៅអ្នកដែលត្រូវការមូលធនក្នុងការវិនិយោគផ្សេងៗ។

## ១.៣. ប្រភេទនៃមូលបត្រ

### ១.៣.១. មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលបរទេសប្រហាក់ប្រហែលហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោតភាគហ៊ុនមិនបង់ថ្លៃគ្រប់និងភាគហ៊ុនបុរិមា[5]។

**ភាគហ៊ុន** គឺជាប្រភេទមូលបត្រកម្មសិទ្ធិដែលតំណាងឲ្យភាពជាម្ចាស់មួយផ្នែកនៅក្នុងក្រុមហ៊ុនសាជីវកម្មមួយ និងសិទ្ធិក្នុងការទាមទារចំណែកនៃទ្រព្យសម្បត្តិ និងប្រាក់ចំណេញរបស់ក្រុមហ៊ុន ដោយផ្អែកទៅលើសមមាត្រភាគហ៊ុនដែលវិនិយោគិនម្នាក់មាន[6]។

នៅពេលដែលអ្នកកាន់កាប់ភាគហ៊ុនកាន់តែច្រើន ភាពជាម្ចាស់កម្មសិទ្ធិរបស់អ្នកនៅក្នុងក្រុមហ៊ុនកាន់តែធំ។ កាលពីអតីតកាល នៅពេលដែលវិនិយោគិនចង់លក់នូវភាគហ៊ុនរបស់ពួកគេពួកគេយកសន្លឹកភាគហ៊ុនរបស់ពួកគេទៅជួបឈ្មួញជើងសារមូលបត្ររបស់ពួកគេ។ ឥឡូវនេះ ការជួញដូរត្រូវបានធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិចទាំងអស់ ពួកគេអាចទូរស័ព្ទ ផ្ញើអ៊ីម៉ែល ទៅឈ្មួញជើងសារមូលបត្ររបស់ពួកគេ។

ភាគហ៊ុនចែកចេញជាពីរប្រភេទៈ

**ភាគហ៊ុនធម្មតា៖** ភាគហ៊ុនធម្មតាគឺជាភាគហ៊ុនដែលមានការលើកទឹកចិត្តដោយផ្ទាល់ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈ ភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុនការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។

ម្ចាស់ភាគហ៊ុនធម្មតា មានសិទ្ធិបោះឆ្នោតសម្រេចរាល់ប្រតិបត្តិការរបស់ក្រុមហ៊ុន។ ម្ចាស់

---

[5] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/០១០៧/០២៨, ២៣ តុលា ២០០៧, សន្ធានុក្រម

[6] សៀវ សុស៊ីខា, ប្រភេទមូលបត្រ, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច)

ភាគហ៊ុនធម្មតាមានឥទ្ធិពលលើអាជីវកម្មរបស់ក្រុមហ៊ុន តាមរយៈសិទ្ធិបោះឆ្នោត ក្នុងការសម្រេចចិត្តលើទិសដៅ និងគោលនយោបាយរបស់ក្រុមហ៊ុន ព្រមទាំងជ្រើសរើសក្រុមប្រឹក្សាភិបាលជាដើម ម្ចាស់ភាគហ៊ុនធម្មតាទាំងអស់របស់ក្រុមហ៊ុនធ្វើការបោះឆ្នោត ដើម្បីជ្រើសរើសក្រុមប្រឹក្សាភិបាល។ បន្ទាប់មក ក្រុមប្រឹក្សាភិបាលនឹងធ្វើការជ្រើសរើស អ្នកគ្រប់គ្រងក្រុមហ៊ុន ដែលជាអ្នកគ្រប់គ្រងក្រុមហ៊ុនជាអចិន្ត្រៃយ។ អ្នកគ្រប់គ្រងនេះ មានតួនាទីទទួលខុសត្រូវក្នុងការបង្កើនផលប្រយោជន៍របស់ភាគហ៊ុនិក តាមរយៈការបង្កើន ថ្លៃរបស់មូលបត្រកម្មសិទ្ធិ ក៏ដូចជាអាចធ្វើអោយក្រុមហ៊ុនមាន លទ្ធភាពទូទាត់ភាគលាភ យ៉ាងទៀងទាត់ដល់ភាគហ៊ុនិកជាដើម។

នៅក្នុងករណីក្រុមហ៊ុនក្ស័យធន ម្ចាស់ភាគហ៊ុនធម្មតានឹងទទួលបានការទូទាត់សង ក្រោយម្ចាស់ភាគហ៊ុនបុរិមា ម្ចាស់សញ្ញាប័ណ្ណ និងម្ចាស់បំណុលជាដើម។ ប៉ុន្តែទោះយ៉ាងណា ម្ចាស់ភាគហ៊ុនធម្មតាទទួលបានចំណេញពីដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនជាងម្ចាស់ភាគហ៊ុនបុរិមា និងម្ចាស់សញ្ញាប័ណ្ណ ដោយអាស្រ័យទៅតាមស្ថានភាពអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

ម្ចាស់ភាគហ៊ុនធម្មតាអាចទទួលបានការទូទាត់ភាគលាភប្រែប្រួល និងកម្រិតចំណេញ មូលធនមួយខ្ពស់ នៅពេលពួកគេលក់ភាគហ៊ុនរបស់ខ្លួន ទៅតាមស្ថានភាពអាជីវកម្មជាក់ស្តែង របស់ក្រុមហ៊ុនដែលបោះផ្សាយ។ ប៉ុន្តែក្រុមហ៊ុនបោះផ្សាយមូលបត្រគ្មានកាតព្វកិច្ច ផ្លូវច្បាប់ណាមួយក្នុងការបង់ភាគលាភទៅឲ្យភាគហ៊ុនិកឡើយ។ ឥណប្រតិទាន របស់ភាគហ៊ុនធម្មតា គឺគ្មានកំណត់ទេ ហើយទទួលបានការទូទាត់សង់ក្រោយគេបង្អស់ និង បំណុលមានកំណត់ មានន័យថានៅពេលក្រុមហ៊ុនក្ស័យធន ម្ចាស់ភាគហ៊ុនធម្មតា នឹងទទួលបានការទូទាត់សងក្រោយគេ ឬក៏រួមចំណែកខាតបង់មានកម្រិតត្រឹមតម្លៃភាគហ៊ុន ដែលខ្លួនបានទិញប៉ុណ្ណោះផងដែរ។ ចំណាំការទូទាត់សងក្រោយគេនេះមិនមែន ទូទាត់តាមតម្លៃនៃភាគហ៊ុននោះទេ ប៉ុន្តែទូទាត់តាមចំណែកនៃភាគហ៊ុនដែលមាន ធៀបនឹងសំណល់ដែលសល់ពីការទូទាត់សងដល់ម្ចាស់ភាគហ៊ុនបុរិមា។ តម្លៃទូទាត់អាចធំជាងតម្លៃភាគហ៊ុនប្រសិនបើសំណល់ពីការទូទាត់សងដល់ម្ចាស់ភាគហ៊ុនបុរិមា ធំជាងតម្លៃមូលធនីយកម្មឬតម្លៃភាគហ៊ុនធម្មតាសរុប។

**ភាគហ៊ុនបុរិមា៖** ភាគហ៊ុនបុរិមាក៏ជាផ្នែកមួយនៃទ្រព្យកម្មសិទ្ធិផងដែរ។ ភាពខុសគ្នារវាងភាគហ៊ុនបុរិមា និងភាគហ៊ុនធម្មតាគឺ អ្នកកាន់កាប់ភាគហ៊ុនបុរិមានឹងមានសិទ្ធិទទួលបានមូលនិធិ ឬប្រាក់ចំណេញរបស់ក្រុមហ៊ុនមុនភាគហ៊ុនធម្មតា។

ភាគហ៊ុនបុរិមា ជាមូលបត្រកម្មសិទ្ធិពិសេសមួយ ដែលមានលក្ខណៈទាំងពីរ គឺលក្ខណៈជាឧបករណ៍កម្មសិទ្ធិផង និងឧបករណ៍បំណុលផង។ ជាទូទៅវាត្រូវបានគេហៅថាឧបករណ៍កូនកាត់។

មូលបត្រកម្មសិទ្ធិនេះមានឈ្មោះថាភាគហ៊ុនបុរិមា ព្រោះម្ចាស់ភាគហ៊ុននេះនឹងទទួលបានការទូទាត់ភាគលាភមុនម្ចាស់ ភាគហ៊ុនធម្មតា ប៉ុន្តែជាទូទៅម្ចាស់ភាគហ៊ុននេះពុំមានសិទ្ធិក្នុងការបោះឆ្នោតឡើយ។ នៅពេលក្រុមហ៊ុនក្ស័យធន ហើយលក់ទ្រព្យសកម្មរបស់ខ្លួនម្ចាស់ភាគហ៊ុនបុរិមាទទួលបានចំណែក ទូទាត់សងការខូចខាតមុនម្ចាស់ភាគហ៊ុនធម្មតា។

ជាទូទៅភាគហ៊ុនបុរិមានេះមានលក្ខណៈប្រហាក់ប្រហែលនឹងសញ្ញាប័ណ្ណដែរ ព្រោះវាត្រូវបានក្រុមហ៊ុនធ្វើចំណាត់ថ្នាក់បំណុល ផ្តល់ចំណាត់ថ្នាក់ឲ្យ។ ហើយដែលជាទូទៅចំណាត់ថ្នាក់របស់ភាគហ៊ុនបុរិមាទាំងនេះ ត្រូវបានគេចាត់ថ្នាក់ទាបជាងសញ្ញាប័ណ្ណ ព្រោះតែភាគលាភរបស់ភាគហ៊ុនរបស់វាមិនត្រូវបានធានាថានឹងទូទាត់អោយម្ចាស់ដូចការប្រាក់របស់សញ្ញាប័ណ្ណឡើយ។

**ភាគលាភ (Dividend)** គឺជាចំណែកនៃប្រាក់ចំណេញដែលបង់ទៅម្ចាស់ភាគហ៊ុនតាមរយៈសាជីវកម្ម។

ភាគលាភមាន ៣ប្រភេទ[7]៖

- ភាគលាភជាសាច់ប្រាក់ (Cash Dividends) គឺជាភាគលាភជាសាច់ប្រាក់ដែលចំណែកប្រាក់ចំណេញរបស់ក្រុមហ៊ុនដែលបានបង់ទៅម្ចាស់ភាគហ៊ុននៃអាជីវកម្ម។
- ភាគលាភជាភាគហ៊ុន (Stock Dividends) គឺជាការបែងចែកតាមសមមាត្រនៃភាគហ៊ុនបន្ថែមរបស់ក្រុមហ៊ុនទៅម្ចាស់ភាគហ៊ុនធម្មតា។
- ភាគហ៊ុនជាទ្រព្យសម្បត្តិ (Property Dividends) គឺជាការបែងចែកនូវទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទៅម្ចាស់ភាគហ៊ុនជំនួសនូវសាច់ប្រាក់ ឬភាគហ៊ុន។

### ១.៣.២. មូលបត្របំណុល

មូលបត្របំណុល (Debt Securities) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយ (ក្រុមហ៊ុន) ដោយបញ្ជាក់ ឬទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលបានឲ្យប្រាក់ខ្ចី ឬដាក់ជាប្រាក់បញ្ញើជាមួយបុគ្គលនោះ ឬបុគ្គលនោះជំពាក់តាមវិធីផ្សេងពីនេះហើយទោះបីជាមាន ឬគ្មានទ្រព្យដាក់ធានាក្តី[8]។

សញ្ញាបណ្ណ គឺជាប្រភេទមូលបត្របំណុល ដែលតំណាងឲ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល (រួមមានសាជីវកម្ម សហគ្រាសរដ្ឋ ឬរាជរដ្ឋាភិបាល) និងវិនិយោគិន។

[7] សៀវ សុស៊ីខា, ប្រភេទមូលបត្រ, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច)

[8] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/០១០៧/០២៨, ២៣ តុលា ២០០៧, សន្ធានុក្រម

តាមរយៈកិច្ចសន្យានេះ បុគ្គលបោះផ្សាយមូលបត្របំណុលមានកាតព្វកិច្ចបង់ឲ្យវិនិយោគិននូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា "គូប៉ុង" ឬ "ការប្រាក់" (លើកលែងសម្រាប់សញ្ញាបណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើមនៅពេលដែលសញ្ញាបណ្ណនោះដល់កាលកំណត់សង ដែលហៅថា "ឥណប្រតិទាន"។ ជំនួសឲ្យការខ្ចីប្រាក់ពីធនាគារ ក្រុមហ៊ុនឬអង្គភាពមួយអាចបោះផ្សាយសញ្ញាបណ្ណទៅឲ្យវិនិយោគិនដោយផ្ទាល់ នៅពេលដែលក្រុមហ៊ុននោះត្រូវការសាច់ប្រាក់ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីៗ បន្តប្រតិបត្តិការក្រុមហ៊ុន ឬដើម្បីទូទាត់បំណុល។

មូលបត្របំណុលរួមមាន៖

១. បណ្ណបំណុលរតនាគារ (Treasury Bill) គឺជាមូលបត្របំណុលរយៈពេលខ្លីបំផុតដែលជាធម្មតាឥណប្រតិទាន (Maturity) របស់មូលបត្រនេះចាប់ពី ១, ៣, ៦, ៩ ឬ១២ខែ។

២. បណ្ណរតនាគារ (Treasury Note) គឺជាមូលបត្របំណុលរបស់រាជរដ្ឋាភិបាលដែលត្រូវបោះផ្សាយដោយនាយកដ្ឋានរតនាគារនៃប្រទេសមួយដែលឥណប្រតិទាន ចាប់ពី១ឆ្នាំ ដល់១០ឆ្នាំ។

៣. បណ្ណបំណុលរតនាគារ (Treasury Bond) គឺជាប័ណ្ណបំណុលរបស់រាជរដ្ឋាភិបាលអាមេរិចដែលមានអត្រាការប្រាក់ថេរ ហើយមានឥណប្រតិទានច្រើនជាង ១០ឆ្នាំ។

៤. សញ្ញាបណ្ណខេត្ត ក្រុង (Municipal Bond) គឺជាសញ្ញាបណ្ណដែលបោះផ្សាយដោយអាជ្ញាធរក្នុងតំបន់ ក្នុងគោលបំណងដើម្បីបង្កើនមូលធនសម្រាប់គម្រោងជាក់លាក់ ដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់របស់ខ្លួន។

៥. សញ្ញាបណ្ណអាជីវកម្ម គឺជាសញ្ញាបណ្ណដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្មដែលមានអត្រាគូប៉ុងខ្ពស់ជាងមូលបត្របំណុលដទៃ។

៦. Junk Bond គឺជាសញ្ញាបណ្ណដែលអត្រាទិន្នផលខ្ពស់ជាងសញ្ញាបណ្ណផ្សេងទៀត ដែលតម្លៃនៃសញ្ញាបណ្ណនេះ ប្រែប្រួលខ្លាំងអាស្រ័យលើសមិទ្ធផលរបស់ក្រុមហ៊ុនបោះផ្សាយ។

៧. Floating Rate Bonds ជាប្រភេទសញ្ញាបណ្ណដែលមានការប្រាក់ប្រែប្រួលតាមអត្រាការប្រាក់នៅលើទីផ្សារ។

៨. Baby Bonds គឺជាសញ្ញាបណ្ណដែលបោះផ្សាយដែលមានតម្លៃចារឹកតិចជាង $១,០០០។

៩. Zero Coupon Bonds ឬ Discount Coupon Bonds គឺជាប្រភេទសញ្ញាបណ្ណត្រូវសងភ្លាមពេលបោះផ្សាយ ត្រូវបានដកពីលើទឹកប្រាក់ទិញ Bonds។

#### ១.៣.៣. ឧបករណ៍និស្សន្ទ

ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ គឺជាឧបករណ៍ហិរញ្ញវត្ថុ និងកិច្ចសន្យារវាងភាគីពីរ ឬច្រើនដែលតម្លៃរបស់វាត្រូវបានកំណត់ដោយការប្រែប្រួលនៃទ្រព្យសកម្ម។ ទ្រព្យសកម្មទាំងនោះជាទូទៅរួមមាន ភាគហ៊ុន សញ្ញាបណ្ណ វត្ថុធាតុ (មាស ប្រេង) រូបិយបណ្ណ អត្រាការប្រាក់និងសន្ទស្សន៍ទីផ្សារ។

## ១.៤. តួអង្គដែលចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា

### ១.៤.១. រចនាសម្ព័ន្ធរបស់ប្រតិបត្តិករនៅក្នុងផ្សារមូលបត្រ

#### ១.៤.១.១. និយ័តករមូលបត្រ

និយ័តករមូលបត្រ (គណៈកម្មការមូលបត្រកម្ពុជា) សំដៅស្ថាប័នរាជរដ្ឋាភិបាល ទទួលខុសត្រូវក្នុងការតាក់តែងច្បាប់ គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យមូលបត្រកម្ពុជា។

#### ១.៤.១.២. ប្រតិបត្តិករទីផ្សារមូលបត្រ

ប្រតិបត្តិករទីផ្សារមូលបត្រ សំដៅដល់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ដែលជាកន្លែងផ្តល់នូវប្រព័ន្ធជួញដូរមូលបត្រ និងជានិយ័តករជួរមុខក្នុងការគ្រប់គ្រងដំណើរការជួញដូរមូលបត្រក្នុងផ្សារមូលបត្រ ដែលជាប្រតិបត្តិករផ្សារមូលបត្រទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា។

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានតួនាទី៖

- ជាកន្លែងដែលមូលបត្រ ត្រូវបានទិញ និងលក់
- ជាកន្លែងដែលផ្តល់នូវប្រព័ន្ធជួញដូរ
- ជានិយ័តករជួរមុខ ក្នុងការគ្រប់គ្រងនូវដំណើរការជួញដូរមូលបត្រក្នុងផ្សារមូលបត្រ។

#### ១.៤.១.៣. ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និង ទូទាត់មូលបត្រ

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ សំដៅដល់ស្ថាប័នដែលធានាថាមូលបត្របានដល់ដៃអ្នកទិញ ហើយប្រាក់ដែលទិញមូលបត្របានដល់ដៃអ្នកលក់ក្នុងពេលតែមួយក្រោយពីការផ្ទៀងផ្ទាត់ទទួលបានជោគជ័យ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រនេះ មានតួនាទីធ្វើការត្រួតពិនិត្យមូលបត្រខាងអ្នកលក់ (ថាតើមានមូលបត្រគ្រប់គ្រាន់សម្រាប់ធ្វើការដាក់លក់ឬទេ) និងខាងអ្នកទិញ (ថាតើមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទិញឬទេ) ដោយហេតុដើម្បីបញ្ចៀសនូវហានិភ័យការទូទាត់។

ការទូទាត់ ត្រូវធ្វើឡើងដោយដកសាច់ប្រាក់ពីអ្នកទិញ តាមរយៈភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដែលមានដូចជា ធនាគារអេស៊ីលីដា ភីអិលស៊ី ធនាគារកាណាឌីយ៉ា ក.អ និង

ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ហើយធ្វើការដកមូលបត្រពីអ្នកលក់ តាមរយៈប្រតិបត្តិកររក្សាទុកមូលបត្រ។ ការផាត់ទាត់ធ្វើឡើងនៅ ២ថ្ងៃ ក្រោយបន្ទាប់ គឺថ្ងៃជួញដូរ (T+2)។

**១.៤.១.៤. ប្រតិបត្តិកររក្សាទុកមូលបត្រ**

ប្រតិបត្តិកររក្សាទុកមូលបត្រ សំដៅដល់បុគ្គលមួយយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀតដែលជាអតិថិជនរបស់ខ្លួនថាផ្តល់សេវា ដូចខាងក្រោមទោះបីជាអតិថិជននោះធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយៈ

ក. កាន់កាប់ ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ក្នុងនាមអតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

ខ. ទទួលរក្សាទុកនូវមូលបត្រ ឬ ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត ទោះបីមានរូបភាពជាវិញ្ញាបនបត្រកម្មសិទ្ធិ ឬ ជាទម្រង់អរូបីក្តី ដោយស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ ក្នុងនាមអតិថិជន ឬ បុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

គ. ផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងៗទៀត ដែលទាក់ទងនឹងសេវាខាងលើ។

**១.៤.១.៥. ក្រុមហ៊ុនធានាទិញមូលបត្រ**

ក្រុមហ៊ុនធានាទិញមូលបត្រ ជាស្ថាប័នដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការចេញលក់ និងផ្សព្វផ្សាយ មូលបត្រជាសាធារណៈពីសារជីវកម្ម ដែលទទួលអាជ្ញាប័ណ្ណពីគណៈកម្មការមូលបត្រកម្ពុជា។ ក្រុមហ៊ុនធានាទិញមូលបត្រដើរតួយ៉ាងសំខាន់ក្នុងការជួយសម្របសម្រួល និងសហការជាមួយសមាជិកក្រុមកាងារបោះផ្សាយលក់មូលបត្រផ្សេងទៀត ក្នុងការរៀបចំឯកសារពាក់ព័ន្ធ និងត្រួតពិនិត្យដំណើរការចុះបញ្ជីទាំងស្រុង រួមទាំងដំណាក់កាលនៃការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ផងដែរ។ តួនាទីចម្បងរបស់ក្រុមហ៊ុនធានាទិញមូលបត្រ គឺការផ្តល់ប្រឹក្សាក្នុងដំណើរការបោះផ្សាយមូលបត្រជាសាធារណៈជាលើកដំបូង (Initial Public Offering)។ ក្រុមហ៊ុនធានាទិញមូលបត្រនេះផងដែរគឺមានឯកទេសផ្នែកហិរញ្ញវត្ថុដែលមានសហប្រតិបត្តិការជាមួយស្ថាប័នបោះផ្សាយ ដើម្បីកំណត់ថ្លៃលក់មូលបត្រលក់ជាលើកដំបូង ទំហំទឹកប្រាក់នៃមូលបត្រ ចំនួនមូលបត្របោះផ្សាយ និងពេលវេលានៃការបោះផ្សាយលក់មូលបត្រ ទៅវិនិយោគិនតាមរយៈបណ្តាញចែកចាយរបស់ក្រុមហ៊ុនធានាទិញមូលបត្រ។

ក្រៅពីតួនាទីសំខាន់ៗខាងលើ ក្រុមហ៊ុនធានាទិញមូលបត្រក៏មានតួនាទីផ្សេងទៀតដូចខាងក្រោមៈ

- ទិញមូលបត្រទាំងអស់ ឬ មួយផ្នែកពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈដើម្បី

ធានានូវភាពជោគជ័យរបស់ក្រុមហ៊ុនបោះផ្សាយនោះ។

- ទិញមូលបត្រដែលលក់មិនអស់ នៅក្នុងដំណើរការការបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងគោលដៅធានានូវការជោគជ័យនៃការបោះផ្សាយ។
- ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ឬ ចូលរួមដោយផ្ទាល់ ឬ មិនផ្ទាល់ក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- លើសពីនេះក្រុមហ៊ុនធានាទិញមូលបត្រ អាចធ្វើអាជីវកម្មផ្សេងទៀតដូចជា អាជីវកម្មជួញដូរមូលបត្រ ឈ្មួញជើងសារមូលបត្រ នឹងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។

ក្រុមហ៊ុនធានាទិញមូលបត្រ (Underwriter) បច្ចុប្បន្នរួមមាន៖

- យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី
- អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក
- កាណា ស៊ីឃ្យូរីធី អិលធីឌី
- កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី
- អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី
- ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី

**១.៤.១.៦. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ សំដៅដល់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈ។

- ចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត គឺសំដៅដល់ក្រុមហ៊ុនដែលបានបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្នុងគោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- នីតិបុគ្គលប្រតិស្រុត (Permitted Entity) សំដៅដល់នីតិបុគ្គលដែលបានអនុញ្ញាតឲ្យបោះផ្សាយ និងធ្វើសំណើលក់មូលបត្រជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។ នីតិបុគ្គលនេះមិនមែនជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ។

**១.៤.១.៧. វិនិយោគិនមូលបត្រ**

វិនិយោគិនមូលបត្រ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិក្នុងការទិញ ឬលក់មូលបត្រដែលបានបោះផ្សាយ និងធ្វើសំណើលក់ជាសាធារណៈនៅលើទីផ្សារមូលបត្រ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**១.៤.២. តួអង្គដទៃទៀត**

នៅក្នុងដំណើរការផ្សារមូលបត្រ ក្រៅពីតួអង្គសំខាន់ៗខាងលើ វិស័យមូលបត្រក៏មានតួអង្គចូលរួមដទៃទៀតដូចជា៖

**១.៤.២.១. ភ្នាក់ងារទូទាត់ប្រាក់ទាក់ទងនឹងមូលបត្រ**

ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ ជាធនាគារដែលទទួលបានអាជ្ញាបណ្ណជាធនាគារពាណិជ្ជ និងទទួលស្គាល់ពី គ.ម.ក ដែលគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។ ភ្នាក់ងារដែលទទួលបន្ទុកមានដូចជា៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ធនាគារ កាណាឌីយ៉ា ក.អ
- ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី

**១.៤.២.២. ភ្នាក់ងារបញ្ញើកាមូលបត្រ**

ភ្នាក់ងារបញ្ញើកាមូលបត្រ ជាភ្នាក់ងារដែលទទួលស្គាល់ពី គ.ម.ក ដែលគ្រប់គ្រងនូវដំណើរនៃការធ្វើបរិវិសកម្ម និងការបែងចែកមូលបត្រ កត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រ និងធ្វើរបាយការណ៍ស្តីពីការបញ្ចាប់ និងជោគជ័យនៃការរក្សាទុកមូលបត្រ។ ភ្នាក់ងារដែលទទួលបន្ទុកមានដូចជា៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ក្រុមហ៊ុន គ្រាយខ័រ ស៊ីឃ្យូរីធី ស៊ីរីស ភីអិលស៊ី
- ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី

**១.៤.២.៣. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ**

ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ជាភ្នាក់ងារដែលទទួលស្គាល់ដោយ គ.ម.ក ដែលគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្រឲ្យមានសង្គតិភាព ការផ្លាស់ប្តូរកម្មសិទ្ធិករ ការធ្វើរបាយការណ៍ ស្ថិតិ និងការរៀបចំការពាក់ព័ន្ធនឹងសិទ្ធិរបស់កម្មសិទ្ធិករមូលបត្រ ដូចជាការជូនដំណឹងអំពីការបែងចែកភាគលាភ និងការបង់ការប្រាក់ជាដើម។ ភ្នាក់ងារដែលទទួលបន្ទុកមានដូចជា៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ក្រុមហ៊ុន គ្រាយខ័រ ស៊ីឃ្យូរីធី ស៊ីរីស ភីអិលស៊ី

- ក្រុមហ៊ុន ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី

**១.៤.២.៤. ភ្នាក់ងារទូទាត់មូលបត្រ**

ភ្នាក់ងារទូទាត់មូលបត្រ ជាភ្នាក់ងារដែលទទួលស្គាល់ពី គ.ម.ក ដែលមានតួនាទីជាអ្នកគណនាភាគលាភ ការប្រាក់ ប្រាក់ដើម ទូទាត់ជូនកម្មសិទ្ធិករ ឬភាគីដែលមានពាក់ព័ន្ធក្នុងនាមជាក្រុមហ៊ុនបោះផ្សាយ និងបញ្ជូនពត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ដល់កម្មសិទ្ធិករមូលបត្រ និងទៅក្រុមហ៊ុនបោះផ្សាយ និង គ.ម.ក តាមការចាំបាច់។ ភ្នាក់ងារដែលទទួលបន្ទុកមានដូចជា៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ក្រុមហ៊ុន គ្រាយខ័រ ស៊ីយូរីធី ស៊ីវីស ភីអិលស៊ី
- ក្រុមហ៊ុន ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី

**១.៤.២.៥. ក្រុមហ៊ុនគណនេយ្យករជំនាញផ្តល់សេវាក្នុងវិស័យមូលបត្រ និងសវនករឯករាជ្យ**

ក្រុមហ៊ុនគណនេយ្យករជំនាញផ្តល់សេវាក្នុងវិស័យមូលបត្រ និងសវនករឯករាជ្យ ជាក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យដែលទទួលស្គាល់ពី គ.ម.ក ដើម្បីធ្វើសវនកម្មនូវរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុវត្តតាមស្តង់ដារដែលបានកំណត់។ ក្រុមហ៊ុនគណនេយ្យជំនាញនឹងជួយលោកអ្នកក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានតាមលក្ខខណ្ឌតម្រូវក្នុងឯកសារផ្តល់ព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ។

ក្រុមហ៊ុនគណនេយ្យករជំនាញផ្តល់សេវាក្នុងវិស័យមូលបត្រនិងសវនករឯករាជ្យមាន៖

- ក្រុមហ៊ុន ប្រាយវ៉តធ័រ ហាវខូភើស៍ (ខេមបូឌា)
- ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា
- ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត
- ក្រុមហ៊ុន អ៊ីនស៍្ទ អែន យ៉ាំង (ខេមបូឌា)
- ក្រុមហ៊ុន អង្គរ ស៊ីធីហ្វាយ អ៊ីខោនថឹន ណោតវើកអិមស៊ី មីលលែន រូដ (ខេមបូឌា)
- ក្រុមហ៊ុន ប្រ៉េនួន សនថុន (ខេមបូឌា) លីមីធីត
- ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក
- ក្រុមហ៊ុន ឌីឡយធ៍ (ខេមបូឌា) ខូ អិលធីឌី
- ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក

### ១.៤.២.៦. ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យមូលបត្រ

ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យមូលបត្រ ជាក្រុមហ៊ុនដែលទទួលស្គាល់ដោយ គ.ម.ក ដើម្បីវាយតម្លៃលើទ្រព្យសកម្ម ដោយអនុវត្តន៍ខ្ជាប់ខ្ជួននូវស្តង់ដារដែលបានកំណត់។ ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យមូលបត្រមានដូចជាៈ

- ក្រុមហ៊ុន វីគ្រាស់ អីព្រេហ្សល
- ក្រុមហ៊ុន រៀល អ៊ីស្ទេត វី.អិម.ស៊ី (ខេមបូឌា) អិលធីឌី
- ក្រុមហ៊ុន ណាយ ហ្វ្រេង (ខេមបូឌា)

### ១.៤.២.៧. ភ្នាក់ងារដាក់ពិន្ទុឥណទាន

ភ្នាក់ងារដាក់ដាក់ពិន្ទុឥណទាន ជាភ្នាក់ងារដែលទទួលស្គាល់ពី គ.ម.ក សម្រាប់ការផ្តល់សេវាផ្តល់ពិន្ទុឥណទានដល់ក្រុមហ៊ុនបោះផ្សាយ។ ភ្នាក់ងារនេះផ្តល់នូវសេវាដាក់ពិន្ទុឥណទានដែលអាចទុកចិត្តបាន និងថែទាំនូវប្រតិបត្តិការដាក់ពិន្ទុឥណទាន និងមានឧបករណ៍ជំរុញផ្សេងៗដែលមានសុវត្ថិភាពគ្រប់គ្រាន់ប្រព័ន្ធដែលអាចប្រើប្រាស់បាន និងគ្រប់គ្រងហានិភ័យផ្សេងៗ។

❖ **សេចក្តីសន្និដ្ឋាន**

ជាទូទៅគេស្គាល់ទីផ្សារមូលបត្រ គឺជាកន្លែងសម្រាប់ធ្វើនូវប្រតិបត្តិការទិញ លក់មូលបត្រគ្រប់ប្រភេទ។ ដែលទីផ្សារមូលបត្រមួយនេះត្រូវបានចាប់ផ្តើមកកើតដំបូងនៅចុងសតវត្សទី១៦ ដោយត្រូវបានចាប់ផ្តើមនៅពេលបណ្តាប្រទេសនៅក្នុងទ្វីបអាមេរិក (The New World) បានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀតដែលមានដូចជាហូឡង់ ព័រទុយហ្គាល់ និងអេស្ប៉ាញ ក្នុងពេលដែលបណ្តាប្រទេសនៅអឺរ៉ុបត្រូវការមូលធនយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងការកសាងនូវអាជីវកម្ម ដូចនេះបានបង្កើតឲ្យមានការចូលរួមរវាងប្រទេសផ្សេងដើម្បីជាជំនួយនូវមូលធនដើម្បីកសាងនូវអាជីវកម្មនោះ។ វិស័យមូលបត្របានបន្តរហូតមកដល់សព្វថ្ងៃនេះ ដែលបានប្រព្រឹត្តិទៅនៅក្នុងទីផ្សារចំនួន ២ គឺទីផ្សារដំបូង និងទីផ្សារបន្ទាប់ ដែលមានការជួញដូរទៅលើមូលបត្រប្រភេទដូចជា មូលបត្រកម្មសិទ្ធិ មូលបត្របំណុល មូលបត្រនិស្សន្ទ។ បើតាមការសិក្សាស្រាវជ្រាវដំណើរការផ្សេងៗនៅក្នុងវិស័យមូលបត្រនេះ ត្រូវមានការចូលរួមពីសំណាក់តួអង្គផ្សេងៗដែលមានមុខងារ និងតួនាទីផ្សេងៗគ្នា នៅក្នុងកិច្ចការប្រព្រឹត្តិទៅក្នុងទីផ្សារមូលបត្រ ដែលរួមមាន និយ័តករមូលបត្រ ប្រតិបត្តិករផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ជាពិសេសវិនិយោគិនមូលបត្រ ដែលរួមសហការជាមួយតួអង្គមួយចំនួនទៀតដែលមានតួនាទីនៅក្នុងវិស័យមូលបត្រនេះផងដែរ តួយ៉ាងដូចជា ភ្នាក់ងារទូទាត់

ប្រាក់ទាក់ទងនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីមូលបត្រ ភ្នាក់ងារទូទាត់មូលបត្រ ក្រុមហ៊ុនគណនេយ្យករជំនាញ សវនករឯករាជ្យ ក្រុមហ៊ុនវាយតម្លៃមូលបត្រ ភ្នាក់ងារដាក់ពិន្ទុឥណទានជាដើម។

សរុបជារួមមក ដើម្បីជាជំនួយនៅក្នុងការសិក្សាលើកិច្ចការសារណាក្រោមប្រធានបទប្រតិបត្តិការផ្សារមូលបត្រកម្ពុជា នេះឲ្យកាន់តែស៊ីជម្រៅ ខ្ញុំបានសិក្សានូវប្រវត្តិ និយមន័យ ទ្រឹស្តីមួយចំនួនដែលទាក់ទងនឹងផ្សារមូលបត្រ ដូចដែលបានលើកឡើងខាងលើ ដើម្បីជាពុទ្ធិបន្ថែមក្នុងការសម្រេចនូវអត្ថន័យនៃកិច្ចការសារណាមួយនេះ។

# ជំពូកទី២
# គណៈកម្មការមូលបត្រកម្ពុជា

# ជំពូកទី២

# គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា ហៅកាត់ថា គ.ម.ក ដែលមានឈ្មោះជា ភាសាអង់គ្លេសថា Securities and Exchange Commission of Cambodia (SECC) ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឲ្យមានការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃប្រទេសកម្ពុជា ព្រមទាំងមានសមត្ថកិច្ច និងសិទ្ធិអំណាចពេញលេញក្នុងការរៀបចំនូវបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ។

## ២.១. រូបសញ្ញា និង អត្ថន័យនៃរូបសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាមានត្រា និង រូបសញ្ញា ព្រមទាំងអត្ថន័យនៃរូបសញ្ញាដែលមានកំណត់សម្គាល់ដូចខាងក្រោម[9]៖

### ២.១.១. រូបសញ្ញា

**រូបភាពទី ២.១៖ រូបសញ្ញា និងអត្ថន័យនៃគ.ម.ក**

- រូបហង្សពណ៌មាស។
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្ដាំរំលេចស្រមោលពណ៌ប្រផេះ។
- រូបរង្វង់ថាសដែលពាក់កណ្ដាលមានពណ៌មាស និងពាក់កណ្ដាលទៀតមានពណ៌ប្រផេះ។

[9] គណៈកម្មការមូលបត្រកម្ពុជា, រូបសញ្ញារបស់គ.ម.ក, http://www.secc.gov.kh/khmer/m17.php?pn=1 (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០១៩)

- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា "គណៈកម្មការមូលបត្រកម្ពុជា" និងព័ទ្ធរង្វង់នៅផ្នែក ខាងក្រោមដោយអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE COMMISSION OF CAMBODIA"។

**២.១.២. អត្ថន័យនៃរូបសញ្ញា**

- រូបហង្សមានពណ៌មាស តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការ មូលបត្រ និងធានាឱ្យដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ ដែលតំណាងឱ្យ ភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។
- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃ ពណ៌ប្រផេះ ចង់បង្ហាញថាភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួត ពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និង តម្លាភាព។
- រូបស្លឹកឈើ តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ច- ជាតិ។

❖ **មូលហេតុនៃការជ្រើសរើសរូបហង្សមាសជានិមិត្តសញ្ញា**

- រូបហង្សពណ៌មាសជាប់ពាក់ព័ន្ធទៅនឹងដំណើរការវិវឌ្ឍនៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ ជាលើកដំបូងនៅលើប្រាក់ប្រាសាទ ក្នុងរជ្ជកាលព្រះបាទអង្គឌួង ដើម្បីរំលឹកដល់លោក សំអាង ហង្ស ដែល ព្រះបាទអង្គឌួងបញ្ជូនឱ្យទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស ហើយលោកបានរួមចំណែកយ៉ាងខ្លាំងក្នុង ការធ្វើឱ្យរូបិយវត្ថុខ្មែរមានអត្តសញ្ញាណច្បាស់លាស់ និងដាក់ឱ្យចរាចរក្នុងសេដ្ឋកិច្ច។
- រូបហង្សពណ៌មាសនេះ ជារូបសញ្ញាតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាសម័យសង្គមរាស្ត្រនិយម សម័យសាធារណរដ្ឋ និងក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែល ការណ៍នេះ ត្រូវគ្នានឹងគណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុមួយ ហើយមានប្រធានជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់។

### ២.១.៣. ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា

រូបភាពទី ២.២៖ ត្រារបស់គ.ម.ក




ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "ព្រះរាជាណាចក្រកម្ពុជា" ផ្នែកកណ្តាលមានសញ្ញាប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា"គណៈកម្មការមូលបត្រកម្ពុជា"។

## ២.២. ប្រវត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃ គ.ម.ក ត្រូវបានធ្វើឡើងដោយអនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ គណៈកម្មការមូលបត្រកម្ពុជា ដែលត្រូវប្រកាសឲ្យប្រើនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០០៨។

## ២.៣. គោលដៅ និង គោលបំណងរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) មានគោលដៅ និងគោលបំណងដូចខាងក្រោម[10]៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ រួមទាំងទីផ្សារមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- ដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ

[10] គណៈកម្មការមូលបត្រកម្ពុជា, គោលដៅ និងគោលបំណង, http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី ១០ មិថុនា ២០១៩)

- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា
- បង្កើត និងរក្សាទំនុកចិត្តអ្នកវិនិយោគដោយការពារសិទ្ធិរបស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ
- ជម្រុញការអភិវឌ្ឍន៍ទីផ្សារមូលបត្រ
- បង្ការ និងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

## ២.៤. ចក្ខុវិស័យ និងបេសកកម្មរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាមាន ចក្ខុវិស័យ និងបេសកកម្មដូចខាងក្រោម[11]៖

### ២.៤.១. ចក្ខុវិស័យ

គណៈកម្មការមូលត្រកម្ពុជាហៅកាត់ថា គ.ម.ក ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ គ.ម.ក មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែក ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

### ២.៤.២. បេសកកម្ម

បេសកកម្មរបស់ គណៈកម្មការមូលបត្រកម្ពុជាគឺ៖

- បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ
- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ
- ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេសនិងការចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា

[11] គណៈកម្មការមូលបត្រកម្ពុជា, ចក្ខុវិស័យ និង បេសកកម្ម, http://www.secc.gov.kh/khmer/m11.php?pn=1 (ចូលទស្សនាថ្ងៃទី ១០ មិថុនា ២០១៩)

- ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.៥. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា

មុខងាររបស់ គ.ម.ក រួមមាន[12]៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា
- ដាក់ឲ្យអនុវត្តន៍គោលនយោបាយដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- លើកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់
- ដើរតួនាទីជាស្ថាប័នពិនិត្យនិងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិក អ្នកចូលរួម និងអ្នកវិនិយោគ
- ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសមស្រប ដើម្បីបង្កើតនូវគោលនយោបាយ សម្រាប់ការអភិវឌ្ឍន៍ទីផ្សារមូលបត្រកម្ពុជា
- បំពេញលក្ខខណ្ឌផ្សេងៗទៀតដែលមានចែងក្នុងអនុក្រឹត្យ

## ២.៦. រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា

### ២.៦.១. ក្រុមប្រឹក្សាភិបាល

- ប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សមាជិកនៃក្រុមប្រឹក្សាភិបាល មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១ |
| ២. តំណាងធានាគារជាតិនៃកម្ពុជា | ០១ |
| ៣. តំណាងក្រសួងពាណិជ្ជកម្ម | ០១ |
| ៤. តំណាងក្រសួងយុត្តិធម៌ | ០១ |

[12] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/០១០៧/០២៨, ២៣ តុលា ២០០៧, មាត្រា ៧

៥. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១

៦. អគ្គនាយក គ.ម.ក ០១

៧. អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២

បេក្ខជនរបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជូនប្រមុខរដ្ឋាភិបាល។

### ២.៦.២. រចនាសម្ព័ន្ធចាត់តាំង

គ.ម.ក មានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម ៖

**រូបភាពទី ២.៣៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ គ.ម.ក**




### ២.៦.៣.អាណត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា

- គ.ម.ក ត្រូវបង្កើតឡើងក្រោមច្បាប់ស្តីពីច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលមានប្រធាន ០១ (មួយ) រូប និងសមាជិក ០៨ (ប្រាំបី) រូប ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ។
- សមាជិក គ.ម.ក មានអាណត្តិរយៈពេល ០៥ (ប្រាំ) ឆ្នាំ។
- សមាជិក គ.ម.ក អាចត្រូវបានតែងតាំងសារជាថ្មីទៀត ឬក៏ផ្ទេរភារកិច្ចតាមសំណើររបស់ប្រធាន គ.ម.ក នៅពេលផុតអាណត្តិ។
- ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកអាចត្រូវបានដកហូត ឬផ្លាស់ប្តូរភារកិច្ច មុនពេលអស់អាណត្តិ។

- សមាជិក គ.ម.ក អាចត្រូវបានតែងតាំងសារជាថ្មីទៀត តាមសំណើរបស់ប្រធាន គ.ម.ក នៅពេលផុតអាណត្តិ។

## ២.៧. តួនាទី និងភារកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា

### ២.៧.១. តួនាទី និងភារកិច្ចរួមរបស់គណៈកម្មការមូលបត្រកម្ពុជា

តួនាទី និងភារកិច្ចរួមរបស់គណៈកម្មការមូលបត្រកម្ពុជាមាន[13]៖

- ជាស្ថាប័នអាណាព្យាបាលលើវិស័យមូលបត្រ គឺមានន័យថា គ.ម.ក មានតួនាទីក្នុងការគ្រប់គ្រងលើស្ថាប័នទាំងឡាយ ដែលទាក់ទងនឹងវិស័យមូលបត្រ និងគ្រប់គ្រងទីផ្សារមូលបត្រ និងក្រុមហ៊ុនមូលបត្រទាំងមូល នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងមូលបត្ររដ្ឋ។
- ជានិយ័តករលើវិស័យមូលបត្រ គឺមានន័យថា គ.ម.ក ជាអ្នករៀបចំនឹងដាក់ឲ្យអនុវត្តគោលនយោបាយ ដែលពាក់ព័ន្ធនឹងផ្សារមូលបត្រ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករផ្សារមូលបត្រ ប្រតិបត្តិករជាត់ទាត់ និងទូទាត់មូលបត្រ ឬ ប្រតិបត្តិកររក្សាទុកមូលបត្រ។
- ជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងវិស័យមូលបត្រ ក្នុងការបង្ការ និងស៊ើបអង្កេតពីបទល្មើសពាក់ព័ន្ធ និងវិស័យមូលបត្រនៅកម្ពុជា។
- គ្រប់គ្រង ត្រួតពិនិត្យកិច្ចការ និងរៀបចំនូវបទប្បញ្ញត្តិនានា នៅក្នុងវិស័យមូលបត្រ ។

### ២.៧.២. តួនាទី និងភារកិច្ចនាយកដ្ឋានរបស់គណៈកម្មការមូលបត្រកម្ពុជា

តួនាទី និងភារកិច្ចរបស់នាយកដ្ឋានរបស់គ.ម.ក មានដូចខាងក្រោម[14]៖

#### ២.៧.២.១. នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មានមុខងារតួនាទីដូចតទៅ៖

- រៀបចំផែនការ និងថវិការបស់ គ.ម.ក.
- គ្រប់គ្រងកិច្ចការរដ្ឋបាល
- ផ្គង់ផ្គង់ និងជួសជុលសំភារៈបរិក្ខារការិយាល័យ
- ចាត់ចែងការងារពិធីការ
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជននានា
- រៀបចំគោលនយោបាយ គ្រប់គ្រង និងជ្រើសរើសបុគ្គលិក

[13] ធូ រិទ្ធី, ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា, (និក្ខេបបទបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៥), ១៦-២០

[14] គណៈកម្មការមូលបត្រកម្ពុជា, តួនាទី និង ភារកិច្ចរបស់នាយកដ្ឋាន ,http://www.secc.gov.kh/khmer/m14.php?pn=1 (ចូលទស្សនាថ្ងៃទី ១០ មិថុនា ២០១៩)

- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ គ.ម.ក.
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន។

### ២.៧.២.២. នាយកដ្ឋានត្រួតពិនិត្យការបោះផ្សាយលក់មូលបត្រ

នាយកដ្ឋានត្រួតពិនិត្យការបោះផ្សាយលក់មូលបត្រមានតួនាទីដូចតទៅ៖

- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុននានាបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយមូលបត្រជា សាធារណៈ
- ត្រួតពិនិត្យលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ជាសាធារណៈ ជាប្រចាំ
- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដាគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន បោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យ និងផ្តល់យោបល់លើការស្នើសុំបោះផ្សាយមូលបត្រលក់ជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជី ឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារ ផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ
- ចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និង សេចក្តីថ្លែង នានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និង សេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិក ឬ/និង តាមប្រព័ន្ធផ្សព្វផ្សាយ សាធារណៈ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ឬ/និង របាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រលក់ ជាសាធារណៈ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយ លក់ មូលបត្រជាសាធារណៈ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត។

- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែង របស់ក្រុមហ៊ុនស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ ប្រសិនបើមាន ការចាំបាច់ស្របតាមក្របខ័ណ្ឌការងារ។

**២.៧.២.៣. នាយកដ្ឋានត្រួតពិនិត្យផ្សារមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យផ្សារមូលបត្រមានមុខងារនិងតួនាទីដូចតទៅ៖

- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឲ្យធ្វើប្រតិបត្តិការជាមួយប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រដើម្បីដាក់សុំការ ពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាត ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធទូទាត់ និងផាត់ទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការនៃប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធ ផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ទៅនាយកដ្ឋានកិច្ចការ គតិយុត្តដើគតិយុត្តដើម្បីធ្វើការស៊ើបអង្កេតបន្ត

**២.៧.២.៤. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ**

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិមានមុខងារតួនាទីដូចតទៅ៖

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានាដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា សិក្សាស្រាវជ្រាវលើការអភិវ
- គ្រប់គ្រង និង ការអភិវឌ្ឍវិស័យមូលបត្រ រៀបចំយុទ្ធសាស្ត្រដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ សិក្សាវាយតម្លៃ និងផ្តល់យោបល
- រៀបចំយុទ្ធសាស្ត្រ ដើម្បីជំរុញឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី មុននឹងអនុញ្ញាតឲ្យបោះផ្សាយនៅលើទីផ្សារ
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ និងធ្វើទំនាក់ទំនងជាមួយនិយ័តករមូលបត្រនៃបណ្តាប្រទេសក្នុងតំបន់ និងក្នុងពិភពលោក
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា។

**២.៧.២.៥. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**

នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រមានតួនាទីដូចតទៅ៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូល រួមដ៏នៃនៅក្នុងទីផ្សារ ដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.
- ពិនិត្យ និងផ្តល់យោបល់ដល់ការស្នើសុំអាជ្ញាប័ណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងាររបស់ក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូល រួមដ៏ទៃទៀតនៅក្នុងទីផ្សារ
- ត្រួតពិនិត្យ និងតាមដាននូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅ ក្នុងទីផ្សារ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ នូវប្រតិបត្តិការរបស់ ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុន មូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូល រួមដ៏ទៃទៀតនៅក្នុងទីផ្សារ
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធក្រុមហ៊ុនមូលបត្រភ្នាក់ងារ ក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដ៏ទៃទៀតនៅក្នុងទីផ្សារ

**២.៧.២.៦. នាយកដ្ឋានកិច្ចការគតិយុត្ត**

នាយកដ្ឋានកិច្ចការគតិយុត្ត មានមុខងារនិងតួនាទីដូចតទៅ៖

- រៀបចំបទប្បញ្ញត្តិចាំបាច់នានា និងលើកសំណើធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិផ្សេងៗ ដើម្បីគាំទ្រដល់ ការអភិវឌ្ឍវិស័យមូលបត្រ

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការត្រួតពិនិត្យ និងសម្រេចពីអគ្គនាយកនៃ គ.ម.ក
- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការដែលស្នើដោយស្ថាប័ននិយ័តករ
- ពង្រឹងការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធវិស័យមូលបត្រ
- ទទួលពាក្យបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែល ល្មើសច្បាប់ ឬមិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូង និងនៅក្នុងទីផ្សារបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់ដើម្បីចាត់វិធានការដាក់ពិន័យនានា ពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- សម្រុះសម្រួលដោះស្រាយវិវាទអ្នកចូលរួមក្នុងទីផ្សារមូលបត្រ
- ចាត់វិធានការផាកពិន័យអន្តរការណ៍ លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ពាព័ន្ធនឹង វិស័យមូលបត្រ
- រៀបចំសំណុំរឿងពាក់ព័ន្ធដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ អគ្គនាយកនៃគ.ម.ក។

### ២.៧.២.៧. អង្គភាពសវនកម្មផ្ទៃក្នុង

គ.ម.ក មានអង្គភាពសវនកម្មផ្ទៃក្នុងមួយដែលចិតនៅក្រោមការដឹកនាំផ្ទាល់របស់ ប្រធានគណៈកម្មការមូលបត្រកម្ពុជា។អង្គភាពសវនកម្មផ្ទៃក្នុងមានមុខងារនិងតួនាទីដូចតទៅ៖

- ត្រួតពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និងប្រតិបត្តិការនានារបស់ គ.ម.ក. ក្នុងការិយបរិច្ឆេតសមស្រប ដើម្បីកំនត់ការអនុវត្តអោយបានសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ញា និងបទបញ្ញត្តិផ្សេងៗ ការចាត់តាំងការងារ និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និង នីតិវិធីជាធរមាន និងស្របតាមគោលដៅរបស់ គ.ម.ក.
- កំនត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រង់ផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋបាល និងប្រតិបត្តិការនានារបស់ គ.ម.ក.
- ពិនិត្យលើភាពដែលអាចជឿជាក់បាន និងភាពពេញលេញនៃព័ត៌មាន ទិន្នន័យ និងវិធីសាស្ត្រនៃការរៀបចំរបាយការណ៍ អំពីព័ត៌មាន និងទិន្នន័យទាំងនេះក្នុងការិយបរិច្ឆេតសមស្រប
- ពិនិត្យលើមធ្យោបាយក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ គ.ម.ក.

- ពិនិត្យលើប្រព័ន្ធដែលបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់និងបទបញ្ញត្តិនានា ហើយលើកសំណើកែតម្រូវ និងកែលំអ ប្រសិនបើមានកំហុស
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពសេដ្ឋកិច្ច នៃការប្រើប្រាស់ធនធានរបស់ គ.ម.ក. ហើយលើកសំណើដោះស្រាយ និងកែលំអការអនុវត្តិប្រតិបត្តិការ
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំណាយ ចំណូលថវិការបស់ គ.ម.ក. ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក . អំពីការប្រព្រឹត្តិទៅរបស់នាយកដ្ឋាន ឬអង្គភាពដែលបានធ្វើសវនកម្មរួចហើយ
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីផ្ញើជូនប្រធាន និងសមាជិកនៃគ.ម.ក. ពិនិត្យ និងផ្តល់ការណែនាំ
- ធ្វើសវនកម្មផ្ទៃក្នុង នៅពេលដែលមានការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃគ.ម.ក.
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន និងសមាជិកនៃ គ.ម.ក. ពិនិត្យ និង សម្រេច
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុង ជាមួយនឹងអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការឲ្យបានគ្រប់គ្រាន់ និងសមស្រប ជាពិសេសកាត់បន្ថយការងារស្ទួនគ្នា។

❖ **សេចក្តីសន្និដ្ឋាន**

វិស័យមូលបត្រនៅកម្ពុជាដែលអាចធ្វើដំណើរការទៅបាន ត្រូវមានការចូលរួមពីក្រុមហ៊ុនផ្សារមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ វិនិយោគិន និងប្រតិបត្តិករពាក់ព័ន្ធនឹងផ្សារមូលបត្រដែលស្ថិតនៅក្រោមការជ្រោមជ្រែងរបស់គណៈកម្មការមូលបត្រកម្ពុជា ដែលជាស្ថាប័នរាជរដ្ឋាភិបាលដែលបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ហើយដើរតួនាទីក្នុងការទទួលខុសត្រូវក្នុងការតាក់តែងច្បាប់ គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យមូលបត្រនៅប្រទេសកម្ពុជា។

ដើម្បីឲ្យដំណើរការនៃប្រតិបត្តិការនៅក្នុងទីផ្សារមូលបត្រកម្ពុជា អាចទៅបានយ៉ាងរលូនរហូតមកដល់ពេលបច្ចុប្បន្ន និងរួមទាំងការអភិវឌ្ឍន៍នូវសេដ្ឋកិច្ចជាតិ រួមទាំងការអភិវឌ្ឍន៍នូវវិស័យមួយនេះ គណៈកម្មការមូលបត្រកម្ពុជា បានកំណត់គោលដៅ និងគោលបំណងយ៉ាងច្បាស់លាស់

ដូចដែលបានរៀបរាប់ខាងលើ រួមទាំងការដាក់ចេញនូវចក្ខុវិស័យ និងបេសកកម្ម ដើម្បីជួយគាំទ្រនូវគោលដៅ និងគោលបំណងដែលគណៈកម្មការមូលបត្រកម្ពុជាចង់បាន។ គណៈកម្មការមូលបត្រកម្ពុជា មានដំណើរការទៅបានបែបនេះ និងអាចគ្រប់គ្រងនូវស្ថានការណ៍ និងការអភិវឌ្ឍន៍នូវវិស័យមូលបត្រនេះបាន មកពីការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង ព្រមទាំងការបែងចែកការងារជាច្រើននាយកដ្ឋាននៅក្នុងការដំណើរការនៃការងារនីមួយៗ ឲ្យបានល្អ។

# ជំពូកទី៣

# ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

# ជំពូកទី៣

# ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) គឺជាកន្លែងដែលផ្តល់នូវប្រព័ន្ធជួញដូរមូលបត្រ និងជានិយ័តករជួរមុខក្នុងការគ្រប់គ្រងដំណើរការជួញដូរមូលបត្រក្នុងផ្សារមូលបត្រ ដែលជាប្រតិបត្តិករផ្សារមូលបត្រទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា។ ដែលយើងដឹងជាទូទៅថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាកន្លែងទិញ លក់មូលបត្រ។

## ៣.១. នាមករណ៍ និង ផ្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមាននាមករណ៍ និងផ្លាកសញ្ញាដូចខាងក្រោម៖

### ៣.១.១. នាមករណ៍

នាមករណ៍របស់ក្រុមហ៊ុនមានឈ្មោះជាភាសាខ្មែរថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) និងជាភាសាអង់គ្លេសថា Cambodia Securities Exchange (CSX)។

### ៣.១.២. ផ្លាកសញ្ញា និង អត្ថន័យ

រូបភាពទី ៣.១៖ រូបសញ្ញារបស់ផ.ម.ក

ផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានអត្តសញ្ញាណដូចខាងក្រោម៖

- ផ្នែកខាងលើ មានសរសេរអក្សរពណ៌ខៀវថា ផ្សារមូលបត្រកម្ពុជា ដែលជាឈ្មោះតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។
- ក្រោមអក្សរផ្នែកស្តាំ មានរូបហង្សមាសពណ៌មួយ ដែលឈរបែរមុខទៅខាងស្តាំ
- ក្រោមអក្សរផ្នែកខាងឆ្វេង មានឈ្មោះរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលសរសេរជាអក្សរកាត់ពណ៌ខៀវជាភាសាអង់គ្លេស (CSX)។

## ៣.២. ប្រវត្តិក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ប្រទេសកម្ពុជា ដោយឈរលើគោលដៅក្នុងការជម្រុញកំណើនសេដ្ឋកិច្ច តាមរយៈលំហូរមូលធន ការវិនិយោគ និងការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែ វិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះ ហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី (ការអភិវឌ្ឍផ្សារមូលបត្រនៅប្រទេសកម្ពុជា)។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកឲ្យដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅខែ កញ្ញា ឆ្នាំ ២០០៧។ នៅឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

នៅខែ មីនា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀងក្រុមហ៊ុនចម្រុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ស្របតាមច្បាប់ស្តីពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០។ ស្របទៅតាមកិច្ចព្រមព្រៀង ក្រុមហ៊ុនចម្រុះ (Joint Venture) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុន ៥៥% នៃចំនួនភាគហ៊ុនសរុបក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុប។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាទទួលអាជ្ញាបណ្ណជា ប្រតិបត្តិករផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

- **ប្រវត្តិសង្ខេបនៃផ.ម.ក**

- ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២៖ ពិធីប្រកាសបើកការជួញដូរមូលបត្រនៅ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។
- ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១៖ ការទទួលបានការអនុញ្ញាតធ្វើប្រតិបត្តិករទីផ្សារ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តករក្សាទុកមូលបត្រ ពី គ.ម.ក។
- ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០៖ ចុះបញ្ជីពាណិជ្ជកម្ម។

- ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៩៖ កិច្ចព្រមព្រៀង ក្រុមហ៊ុនចម្រុះ រវាងរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
- ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨៖ អនុស្សរណៈយោគយល់អំពីការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។
- ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧៖ ការដាក់ឲ្យដំណើរការគម្រោងបង្កើតផ្សារមូលបត្រនៅកម្ពុជា។
- ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦៖ អនុស្សរណៈយោគយល់អំពីការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា[15]។

## ៣.៣. ចក្ខុវិស័យ និង បេសកកម្មក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានចក្ខុវិស័យ និង បេសកម្មដូចខាងក្រោម[16]៖

### ៣.៣.១. ចក្ខុវិស័យ

វិស័យមូលបត្រគឺជាផ្នែកមួយក្នុងការធ្វើឲ្យវិស័យហិរញ្ញហិរញ្ញវត្ថុកាន់តែមានសន្ទុះក្នុងការកើនឡើងជាលំដាប់។ ហេតុនេះហើយដើម្បីឲ្យដំណើរការនៃវិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជាកាន់តែរីកចម្រើន ប្រកបទៅដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានកំណត់នូវចក្ខុវិស័យរបស់ខ្លួនយ៉ាងច្បាស់លាស់ក្នុងការជួយគាំទ្រនូវវិស័យហិរញ្ញវត្ថុកម្ពុជានោះគឺដើម្បីកសាងនូវមហាវិថីហិរញ្ញវត្ថុសម្រាប់កម្ពុជា។

### ៣.៣.២. បេសកកម្ម

គណៈកម្មការមូលបត្រកម្ពុជា ដើម្បីសម្រេចនូវចក្ខុវិស័យដែលខ្លួនបានដាក់ចេញខាងលើក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានដាក់ចេញនូវបេសកកម្មដែលមានដូចខាងក្រោម៖

- ដើម្បីសម្រួលក្នុងការកៀងគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស
- ដើម្បីបង្កើននូវផលិតផលនិងសេវាកម្មទំនើបជាច្រើនប្រភេទសម្រាប់ចូលរួមទីផ្សារទាំងអស់

[15] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ប្រវត្តិរបស់ផ.ម.ក, http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ឆ្នាំ ២០១៩)

[16] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ចក្ខុវិស័យ និងបេសកកម្ម, http://csx.com.kh/kh/about/mission.jsp?MNCD=1020 (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ឆ្នាំ ២០១៩)

- ដើម្បីដាក់ឲ្យដំណើរការនៅសហគ្រាសសាធារណៈមួយដែលមានស្វ័យចីរភាព ក្រោមមគ្គុទេសក៍ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ៣.៤. រចនាសម្ព័ន្ធគ្រប់គ្រង និង ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានដាក់ចេញនូវរចនាសម្ព័ន្ធគ្រប់គ្រង និង ក្រុមប្រឹក្សាភិបាលដូចខាងក្រោម[17]៖

### ❖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដឹកនាំដោយអគ្គនាយក ១រូប ដែលមានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ និងមានអគ្គនាយករងជាជំនួយការ។

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មាននាយកដ្ឋានចំណុះចំនួន០៦ នាយកដ្ឋានដូចខាងក្រោម៖

- នាយកដ្ឋានប្រតិបត្តិការផ្សារមូលបត្រ
- នាយកដ្ឋានព័ត៌មានវិទ្យា
- នាយកដ្ឋានផាត់ទាត់ និងទូទាត់មូលបត្រ
- នាយកដ្ឋានរក្សាទុកមូលបត្រ
- នាយកដ្ឋានចុះបញ្ជី និងការផ្តល់ព័ត៌មាន
- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**រូបភាពទី ៣.២៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ផ.ម.ក**




[17] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, រចនាសម័ន្ធគ្រប់គ្រងរបស់ផ.ម.ក, http://csx.com.kh/kh/about/org.jsp?MNCD=10302 (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ឆ្នាំ ២០១៩)

❖ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

**រូបភាពទី ៣.៣៖ ក្រុមប្រឹក្សាភិបាលរបស់ផ.ម.ក**




- ក្រុមប្រឹក្សាភិបាលនៃផ.ម.ក. រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល(ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
- សមាជិកចំនួន ៤រូបផ្សេងទៀតគឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ២រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

## ៣.៥. តួនាទី និងភារកិច្ចរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រមានតួនាទី និងភារកិច្ចរួមដូចខាងក្រោម[18]៖

- ភារកិច្ចចម្បងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺដើម្បីបង្កើត និងដាក់ឲ្យដំណើរការទីផ្សារមូលបត្រប្រព័ន្ធផាត់ទាត់ និងទូទាត់ មូលបត្រ និងប្រព័ន្ធរក្សាទុកមូលបត្រ ស្របតាមច្បាប់ស្ដីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិដែលពាក់ពន្ធ័។
- បង្កើតឲ្យមានបរិយាកាសក្នុងការជួញដូរក្នុងផ្សារមូលបត្រប្រចាំថ្ងៃ។
- បម្រើសេវាកម្ម និងផលិតផលជូនវិនិយោគិន និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។

[18] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, តួនាទីចម្បងរបស់ផ.ម.ក, http://csx.com.kh/kh/about/chairman.jsp?MNCD=1000 (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ឆ្នាំ ២០១៩)

❖ **សេចក្តីសន្និដ្ឋាន**

ការចូលរួមរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺជាកត្តាលីករដ៏សំខាន់ក្នុងការជួយជ្រោមជ្រែងនូវដំណើរការនៃការអភិវឌ្ឍន៍វិស័យមូលបត្រ ជាពិសេសដំណើរការនៃការជួញដូរមូលបត្រជាប្រចាំថ្ងៃ ក្នុងផ្សារមូលបត្រកម្ពុជា។ ដោយក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងដោយកិច្ចសហការរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ ដែលត្រូវបានចុះកិច្ចព្រមព្រៀងឲ្យបង្កើតឡើងនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩ ដែលការបង្កើតឡើងនេះគឺមានគោលបំណងច្បាស់លាស់ គឺដើម្បីឲ្យដំណើរការនៃវិស័យហិរញ្ញវត្ថុកម្ពុជា ឲ្យកាន់តែរីកចម្រើនប្រកបទៅដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល និងដើម្បីកសាងនូវមហាវិថីហិរញ្ញវត្ថុកម្ពុជា។ ជាពិសេសទៀតនោះ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាកន្លែងដែលផ្តល់ប្រព័ន្ធជួញដូរមូលបត្រ និងជានិយ័តករជួរមុខក្នុងការគ្រប់គ្រងដំណើរការជួញដូរមូលបត្រ ហើយក៏បានរៀបចំនូវរចនាសម្ព័ន្ធ និងក្រុមប្រឹក្សាភិបាល នៅក្នុងដំណើរការគ្រប់គ្រងក្រុមហ៊ុន និងដើម្បីផ្តល់សេវាកម្មដល់វិនិយោគិន ដែលស្ថិតនៅលក្រោមការគ្រប់គ្រងរបស់គណៈកម្មការមូលបត្រកម្ពុជា។

សរុបជារួមមក ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺជាកន្លែងសម្រាប់ផ្តល់ភាពងាយស្រួលក្នុងការវិនិយោគទៅលើទីផ្សារមូលបត្រសម្រាប់វិនិយោគិន ព្រោះក្រុមហ៊ុនផ្សារមូលបត្រនេះ ជាប្រតិបត្តិករដ៏ជំនាញនៅក្នុងប្រទេសកម្ពុជា នៅក្នុងការជួញដូរនូវមូលបត្រសម្រាប់វិនិយោគិនទាំងនីតិបុគ្គល និងរូបវន្តបុគ្គល។

# ជំពូកទី៤

# ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា

# ជំពូកទី៤

# ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា

នៅក្នុងវិស័យមូលបត្រនៅកម្ពុជា ក៏ដូចជាបណ្តាប្រទេសផ្សេងទៀតនៅលើពិភពលោក ប្រតិបត្តិការនៅក្នុងវិស័យនេះពិតជាមានភាពស៊ាំញ៉ាំខ្លាំង ដូចដែលយើងបានដឹងហើយថា ប្រតិបត្តិការនៅក្នុងវិស័យមូលបត្រមានដូចជា ការបោះផ្សាយមូលបត្រ និង ការជួញដូរមូលបត្រ គឺជាចំណុចសំខាន់បំផុតក្នុងដំណើរការនៅក្នុងផ្សារមូលបត្រនេះ ហើយក៏ជាចំណុចសំខាន់ដែលអ្នកវិនិយោគចង់ដឹង សម្រាប់ធ្វើការវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់។

## ៤.១. ដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្នុងការគៀងគរនូវមូលធនក្នុងការយកទៅវិនិយោគ ឬដើម្បីយកទៅអភិវឌ្ឍបន្ថែមនៅក្នុងក្រុមហ៊ុនតាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ដើម្បីធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនដែលមានបំណងបោះផ្សាយមូលបត្រ ត្រូវគោរព និងប្រតិបត្តិតាមដំណើរការបោះផ្សាយលក់មូលបត្រ ដូចខាងក្រោម៖

### ៤.១.១. លក្ខខណ្ឌនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ

ការបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវគោរពតាមលក្ខខណ្ឌ ២ គឺ លក្ខខណ្ឌបរិមាណ និងលក្ខខណ្ឌគុណភាព ដែលមានលក្ខខណ្ឌកំណត់ដូចខាងក្រោម៖

#### ៤.១.១.១. លក្ខខណ្ឌបរិមាណ

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម[19]៖

- មានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០,០០០,០០០,០០០ (សាមសិបពាន់លាន) រៀលគិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក។
- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២,០០០,០០០,០០០ (ពីរពាន់លាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣,០០០,០០០,០០០ (បីពាន់លាន) រៀលសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។
- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច

[19] ប្រកាសស្តីពីការកែប្រែលក់វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៩/១៨គ.ម.ក./ប្រ.ក., ១៩ ធ្នូ ២០១៨, ប្រការ ៨ ថ្មី

២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក តាមការស្នើសុំរបស់ ផ.ម.ក។

- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបតិចជាង ៧ (ប្រាំពីរ) ភាគរយនៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក តាមការស្នើសុំរបស់ ផ.ម.ក។

#### ៤.១.១.២. លក្ខខណ្ឌគុណភាព

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវមានលក្ខណៈដូចខាងក្រោម៖

- ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និង នីតិប្រតិស្រុត
- មានសកម្មភាពអាជីវកម្មដែលមានស្ថេរភាព និងធានាឲ្យមានកំណើនរយៈពេលវែង
- មានស្ថេរភាពហិរញ្ញវត្ថុ និងមានមូលនិធិបង្វិលគ្រប់គ្រាន់
- គោរពតាមបទបញ្ញត្តិពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ
- មានរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ
- មានកិច្ចសន្យាធានាទិញមូលបត្រជាមួយក្រុមហ៊ុនធានាទិញមូលបត្រ។

### ៤.១.២. ឯកសារតម្រូវក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវដាក់ពាក្យស្នើសុំ ដោយភ្ជាប់មកជាមួយនូវឯកសារផ្តល់ព័ត៌មាន និងឯកសារភ្ជាប់មកគណៈកម្មការមូលបត្រកម្ពុជា។

#### ៤.១.២.១. ការដាក់ពាក្យស្នើសុំ

ទម្រង់កំណត់នៃពាក្យស្នើសុំផ្តល់ដោយ គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានបែងចែកជា ១៣ ផ្នែក រួមមាន៖

- ផ្នែកទី១៖ ព័ត៌មានទូទៅ
- ផ្នែកទី២៖ ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិ
- ផ្នែកទី៣៖ មូលធនភាគហ៊ុនិក និងចំណេញភាព

- ផ្នែកទី៤៖ រចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន និងភាគហ៊ុនិក
- ផ្នែកទី៥៖ ព័ត៌មានអំពីអភិបាល
- ផ្នែកទី៦៖ ព័ត៌មានអំពីបុគ្គលិកជាន់ខ្ពស់
- ផ្នែកទី៧៖ ព័ត៌មានអំពីក្រុមហ៊ុនហូលឌីង ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ
- ផ្នែកទី៨៖ ព័ត៌មានអំពីការបោះផ្សាយមូលបត្រជាសាធារណៈពីមុន
- ផ្នែកទី៩៖ ព័ត៌មានអំពីការបដិសេធឯកសារផ្តល់ព័ត៌មាន
- ផ្នែកទី១០៖ ព័ត៌មានអំពីភាគីពាក់ព័ន្ធ
- ផ្នែកទី១១៖ ឯកសារភ្ជាប់
- ផ្នែកទី១២៖ សេចក្តីប្រកាស និងកិច្ចសន្យារបស់បុគ្គលដាក់ពាក្យស្នើសុំ
- ផ្នែកទី១៣៖ ការបង់ថ្លៃពាក្យស្នើសុំ និងសាហ៊ុយសិក្សាសំណុំលិខិត។

#### ៤.១.២.២. ការដាក់ឯកសារផ្តល់ព័ត៌មាន

ឯកសារផ្តល់ព័ត៌មាន សំដៅដល់លិខិតជូនដំណឹង ឬ សេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលអធិប្បាយអំពីប្រវត្តិក្រុមហ៊ុន របាយការណ៍ហិរញ្ញវត្ថុ ឬ ជាការអញ្ជើញឲ្យទិញ ឬ សំណើឲ្យគេដាក់ពាក្យសុំទិញ ឬ ទិញមូលបត្រ ឬ ប្រកាសអំពីការដាក់លក់ ឬ ការលក់មូលបត្រ និងរាប់បញ្ចូលទាំងឯកសារផ្តល់ព័ត៌មានជាប្រចាំ ឬ ឯកសារផ្តល់ព័ត៌មានជំនួសផងដែរ។

ឯកសារព័ត៌មានដែលត្រូវផ្តល់ឲ្យរួមមាន[20]៖

- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ
- ព័ត៌មានស្តីពីកត្តាហានិភ័យ
- ការប្រើប្រាស់សាច់ប្រាក់ដែលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- ផែនការវិនិយោគ
- ការពិពណ៌នាអំពីធុរកិច្ច
- ការពិពណ៌នាអំពីអចលកម្មទ្រព្យរបស់ក្រុមហ៊ុនបោះផ្សាយ
- ផែនការប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ
- ការវាយតម្លៃទ្រព្យសកម្ម និងការវាយតម្លៃទ្រព្យសកម្មឡើងវិញ

[20] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ៧

- ព័ត៌មានពាក់ព័ន្ធនឹងអភិបាល និងបុគ្គលិកជាន់ខ្ពស់
- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់
- ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ
- ប្រាក់បំណាច់ ឬ លាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់
- សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឲ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិក
- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក
- ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ
- កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ
- ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់
- ការពិពណ៌នាពីមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់
- ព័ត៌មានហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុ។

#### ៤.១.២.៣. ការដាក់ឯកសារភ្ជាប់

បុគ្គលដាក់ពាក្យស្នើសុំត្រូវភ្ជាប់ជាមួយពាក្យស្នើសុំនូវឯកសារមួយចំនួនដូចខាងក្រោម[21]៖

- លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក
- លិខិតប្រគល់សិទ្ធិដោយមានបញ្ជាក់ពីតួនាទី និងភារកិច្ចជាអភិបាល ឬ នាយកប្រតិបត្តិនៅក្នុងការបម្រើការងារនៅក្នុងក្រុមហ៊ុនបោះផ្សាយដោយមានការចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់
- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន
- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ
- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ

[21] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ២៩

- កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ
- លិខិតបញ្ជាក់កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ
- លិខិតបញ្ជាក់កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ
- លិខិតបញ្ជាក់កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់ជំនួស
- កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនបើមាន
- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជ ឬ លិខិតបញ្ជាក់ពីសវនកម្មនូវចំនួនទឹកប្រាក់តម្កល់សម្រាប់ធ្វើជាមូលធន
- របាយការណ៍អនុសាសន៍ស្ដីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់សវនករឯករាជ្យ ដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ គ.ម.ក
- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនគណនេយ្យករជំនាញមានគុណវុឌ្ឍិទទួលស្គាល់ដោយ គ.ម.ក
- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ចេញដោយមេធាវីមានគុណវុឌ្ឍិទទួលស្គាល់ដោយ គ.ម.ក។

## ៤.២. នីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើដំបូង

នីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរួមមាន ១២ ដំណាក់កាលដូចខាងក្រោម[22]៖

### ៤.២.១. ការដាក់លិខិតសម្ដែងឆន្ទៈ

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្ដែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក គ.ម.ក ដែលលិខិតមានខ្លឹមសារ ០៣ ចំណុចដូចខាងក្រោម៖

១. គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)

២. ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង ដែលរំពឹងទុករួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

[22] គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង, លេខ០០១គ.ម.ក/គ.ណ.ក, ០៨ កញ្ញា ២០១១

៣. គម្រោងពេលវេលាកំណត់នៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង

### ៤.២.២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាប័ណ្ណពី គ.ម.ក។

### ៤.២.៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រជាសាធារណៈ

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀតដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទបញ្ញត្តិជាធរមាន។

ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

### ៤.២.៤. ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ។

### ៤.២.៥. ការដាក់ពាក្យស្នើសុំទៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជី

លក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

ឯកសារដែលត្រូវភ្ជាប់មកជាមួយ ដើម្បីដាក់ជូនទៅ ផ.ម.ក មានដូចខាងក្រោម[23]៖

១. ព័ត៌មានទូទៅ៖ ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ និងអក្សរឡាតាំង អាសយដ្ឋានក្រុមហ៊ុន កាលបរិច្ឆេទបង្កើតក្រុមហ៊ុន កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន វិញ្ញាបនបត្រចុះបញ្ជី ពាណិជ្ជកម្ម និង លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ។

២. ព័ត៌មានពីបុគ្គលតំណាងក្រុមហ៊ុន៖ អត្តសញ្ញាណបុគ្គលតំណាងក្រុមហ៊ុន។

៣. ព័ត៌មានអំពីភាគហ៊ុនិក៖ អត្តសញ្ញាណភាគហ៊ុនិក។

៤. ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ៖ ប្រភេទមូលបត្រ ស្ថានភាពហិរញ្ញវត្ថុ ការទទួលបានប្រាក់ចំណេញ ការវាយតម្លៃទ្រព្យសកម្ម។

៥. ព័ត៌មានពីស្ថានភាពអាជីវកម្ម៖ ព័ត៌មានអំពីធុរកិច្ច អភិបាលកិច្ច និងហានិភ័យ។

៦. ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់បានមកពីការបោះផ្សាយមូលបត្រ។

៧. ព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពចុះបញ្ជីលក់មូលបត្រ។

### ៤.២.៦. ការដាក់ពាក្យស្នើសុំទៅគណៈកម្មការមូលបត្រកម្ពុជា

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធផលអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈមក គ.ម.ក។

គ.ម.ក ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជូនក្រុមហ៊ុនបោះផ្សាយ។

### ៤.២.៧. ការកំណត់តម្លៃមូលបត្រតាមរយៈប៊ុកបៀលឌីង

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ពី គ.ម.ក ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

[23] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥គ.ម.ក/ប្រ.ក., ១០ កញ្ញា ២០១៥, ប្រការ៤

**៤.២.៨. ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពី ផ.ម.ក**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃការជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

**៤.២.៩. ការស្នើសុំអនុញ្ញាតលើលក្ខខណ្ឌសំណើលក់ទៅ គ.ម.ក**

ក្រោយពីការបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមបោះផ្សាយលក់មូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូន គ.ម.ក ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**៤.២.១០. ការធ្វើបរិវិសកម្មមូលបត្រ**

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីគ.ម.ក ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមធ្វើដំណើរការធ្វើ បរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី៣ និងជំពូកទី៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**៤.២.១១. ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្ម**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្លាមជូន គ.ម.ក។

**៤.២.១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិទៅឲ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវ

ការដោយអនុលោម តាមបទប្បញ្ញត្តិជាធរមាន។

នៅក្នុងការបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រផ្លូវការនៅ ផ.ម.ក បុគ្គលដែលទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ត្រូវផ្តល់ជូន ផ.ម.កនូវឯកសារដូចខាងក្រោម[24]៖

១. ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ គ.ម.ក

២. ឯកសារបញ្ជាក់អំពីការទូទាត់បរិវិសកម្មមូលបត្រ

៣. ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ

៤. ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយភ្នាក់ងារទូទាត់

៥. របាយការណ៍បែងចែកមូលបត្រ

៦. លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

## ៤.៣. ប្រតិបត្តិការនៃការជួញដូរមូលបត្រក្នុងទីផ្សារដំបូង

### ៤.៣.១. ដំណាក់កាលនៃការស្ទាបស្ទង់ថ្លៃ ឬប៊ុកបៀលឌីង

ការស្ទាបស្ទង់ថ្លៃ ឬ ការធ្វើប៊ុកបៀលឌីងមានដំណើរប្រព្រឹត្តិទៅដូចខាងក្រោម[25]៖

១. បន្ទាប់ពីទទួលបានការអនុញ្ញាត ជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើប៊ុកបៀលឌីង ដោយត្រូវធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈ ដើម្បីអញ្ជើញវិនិយោគិនឲ្យចូលរួម។

២. ដើម្បីជម្រុញឲ្យវិនិយោគិន ចូលរួមយ៉ាងសកម្មក្នុងដំណើរប៊ុកបៀលឌីង ក្នុងគោលដៅធានាថា ថ្លៃមូលបត្រកម្មសិទ្ធិ បានឆ្លុះបញ្ចាំងតម្រូវការទីផ្សារ មូលបត្រកម្មសិទ្ធិដែលត្រូវដាក់ឲ្យធ្វើប៊ុកបៀលឌីងមានចំនួន ៧០ (ចិតសិប) ភាគរយ នៃមូលបត្រកម្មសិទ្ធិសរុប ដែលនៅសល់បន្ទាប់ការលៃបម្រុងទុកជូនបុគ្គលិក ករណីក្រុមហ៊ុនបោះផ្សាយមានគោលនយោបាយលើកទឹកចិត្ត តាមរយៈការលក់មូលបត្រកម្មសិទ្ធិជូនបុគ្គលិក។ ដោយឡែកចំណែកនៃមូលបត្រកម្មសិទ្ធិដែលនៅសល់ចំនួន ៣០ (សាមសិប) ភាគរយ ទៀត គឺត្រូវលៃបម្រុងទុកសម្រាប់ការធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរប៊ុកបៀលឌីង។

[24] ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥គ.ម.ក/ប្រ.ក., ១០ កញ្ញា ២០១៥, ប្រការ១០

[25] គោលការណ៍ណែនាំស្តីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ, លេខ០០២/១២គ.ម.ក/គ.ណ.ន, ០៩ កុម្ភៈ ២០១២

៣. វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង (Book-Building Form) ដោយកំណត់ដោយគណៈកម្មការមូលបត្រកម្ពុជា។ វិនិយោគិនត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃ (Price Range) នៃថ្លៃមូលបត្រកម្មសិទ្ធិក្នុងឯកសារផ្តល់ព័ត៌មានដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងចំនួនមូលបត្រកម្មសិទ្ធិដែលមានបំណងចង់ធ្វើបរិវិសកម្ម បន្ទាប់ពីបញ្ចប់ដំណាក់កាលនៃការធ្វើប៊ុកបៀលឌីង។

៤. វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវតម្កល់ប្រាក់កក់ស្មើនឹង ១០ (ដប់) ភាគរយ នៃថ្លៃមូលបត្រកម្មសិទ្ធិសរុបដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

៥. ក្រោយដំណើរការប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយមូល ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price) ដើម្បីស្នើសុំការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា និងភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ។

៦. វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សំដៅដល់វិនិយោគិនដែលបានដាក់ថ្លៃខ្ពស់ជាង ឬស្មើ ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price)។ ក្រុមហ៊ុនបោះផ្សាយមូល ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវគណនាថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ដោយប្រើប្រាស់បច្ចេកទេសថ្លឹង រកមធ្យមភាគ (Weight-Average) លើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិ ដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំធ្វើប៊ុកបៀលឌីង។

៧. ថ្លៃមូលបត្រកម្មសិទ្ធិដែលបានគណនាក្នុងកថាខ័ណ្ឌ ៦ ខាងលើ អាចត្រូវបានធ្វើការកែតម្រូវ (Adjustment) ដើម្បីឆ្លើយតបទៅស្ថានភាពទីផ្សារ ដោយមានការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា។

៨. ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការជូនដំណឹងភ្លាមដល់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានទទួលបានជោគជ័យបន្ទាប់ពីគណៈកម្មការមូលបត្រកម្ពុជា បានផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។ ជាមួយគ្នានេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្ទេរប្រាក់កក់ ១០ (ដប់) ភាគរយជូនវិនិយោគិនដែលមិនបានទទួលជោគជ័យក្នុងប៊ុក

បៀលឌីងវិញ ឬរក្សាទុកក្នុងករណីវិនិយោគិនមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានបំណងបន្តធ្វើបរិវិសកម្ម។

**៤.៣.២. ដំណាក់កាលសុំចុះឈ្មោះទិញមូលបត្រ ឬ បរិវិសកម្ម**

ការសុំចុះឈ្មោះទិញមូលបត្រ ឬ បរិវិសកម្ម មានដំណើរប្រព្រឹត្តិទៅដូចខាងក្រោមៈ

១. វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនដែលមានដាក់ក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀឌីង ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបានធ្វើ។

២. វិនិយោគិនមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ដែលមានបំណងបន្តធ្វើបរិវិសកម្ម អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើ។

៣. វិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវតម្កល់ប្រាក់កក់យ៉ាងតិច ១០០ (មួយរយ) ភាគរយ នៃទំហំមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្ម។

៤. វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ត្រូវដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងរយៈពេលធ្វើបរិវិសកម្ម ករណីមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិសកម្មលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃមប្រុងសម្រាប់ធ្វើប៊ុកបៀលឌីង ហើយវិនិយោគិនដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង ប៉ុន្តែមិនទាន់ដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម វិនិយោគិននោះ អាចមិនដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម និងអាចដកប្រាក់កក់ ១០ ភាគរយ វិញបាន។

៥. ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិដែលលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលដាក់ពាក្យធ្វើបរិវិសកម្ម តាមវិធានប្រូរ៉ាតា (Pro Rata)។

៦. ករណីវិនិយោគិនដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីងមានចំនួនច្រើនលើសលប់ ដោយមានទាំង វិនិយោគិនជានីតិបុគ្គល ឬ/និង វិនិយោគិនជារូបវន្តបុគ្គល ហើយបានដាក់ពាក្យស្នើធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិក្នុងចំនួនច្រើនលើសលប់ លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង នោះគណៈកម្មការមូលបត្រកម្ពុជា អាចពិនិត្យធ្វើការបែងចែកក្នុងចំនួនមិនលើសពី ពីរភាគបី (២/៣)នៃមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀល

ឌីងនិងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ហើយផ្ទេរទៅបន្ថែមក្នុងចំណែកមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីងដើម្បីបែងចែកជូនដល់វិនិយោគិនដែលបានដាក់ពាក្យធ្វើបរិវិសកម្មក្នុងចំនួនដ៏ច្រើនលើសលប់នោះ។

៧. បន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ ក្នុងករណីមានអ្នកធ្វើបរិវិសកម្មមិនទទួលបានមូលបត្រកម្មសិទ្ធិតាមការដាក់ពាក្យស្នើសុំ នោះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវធ្វើការផ្ទេរសាច់ប្រាក់ដែលនៅសល់ពីការធ្វើបរិវិសកម្មជូនអ្នកធ្វើបរិវិសកម្មពាក់ព័ន្ធនោះ។

៨. ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ហើយធ្វើបរិវិសកម្មនោះ មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង វិនិយោគិនទាំងអស់ដែលត្រូវបានជោគជ័យ ក្នុងប៊ុកបៀលឌីង ត្រូវធ្វើបរិវិសកម្មសិទ្ធិយ៉ាងតិចស្មើនឹងប្រាក់កក់ ១០ (ដប់) ភាគរយ។

៩. ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងតាមការស្នើសុំ។ ចំនួនមូលបត្រដែលនៅសល់ ត្រូវធ្វើការបែងចែកទៅឲ្យវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង។

១០. ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបម្រុងទុក។

## ៤.៤. ប្រតិបត្តិការនៃការជួញដូរមូលបត្រលើទីផ្សារបន្ទាប់

### ៤.៤.១. នីតិវិធីសំខាន់ៗមុនធ្វើការជួញដូរ

ចំពោះសាធារណៈជន ឬវិនិយោគិនដែលមានបំណងធ្វើការជួញដូរមូលបត្រកម្មសិទ្ធិនៅក្នុងទីផ្សារមូលបត្រកម្ពុជា ត្រូវតែអនុវត្តនូវជំហ៊ានដូចខាងក្រោម៖

#### ៤.៤.១.១. ការជ្រើសរើសក្រុមហ៊ុនមូលបត្រ

ជំហ៊ានដំបូងមុននឹងធ្វើការជួញដូរនូវមូលបត្រវិនិយោគិនត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក និងជាសមាជិករបស់ផ្សារមូលបត្រកម្ពុជា ដើម្បីធ្វើជាតំណាង

របស់ខ្លួនក្នុងការជួញដូរមូលបត្រ។ បន្ទាប់ពីវិនិយោគិនជ្រើសរើសក្រុមហ៊ុនមូលបត្ររួច វិនិយោគិនត្រូវបំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនត្រឹមត្រូវ តាមការណែនាំរបស់ក្រុមហ៊ុនមូលបត្រ ហើយជាទូទៅត្រូវភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម[26]៖

- **សម្រាប់វិនិយោគិនជារូបវន្តបុគ្គល**

១. បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ដោយមានរូបថត ដែលថតចំពីមុខ ទំហំ ៤ គុណនឹង៦ ពីរសន្លឹក។

២. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានសុពលភាពថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនសញ្ជាតិខ្មែរ។

៣. លិខិតឆ្លងដែនមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ។

៤. លិខិតបញ្ជាក់គណនីនៅធនាគារ។

- **សម្រាប់វិនិយោគិនជានីតិបុគ្គល**

១. បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ដោយមានរូបថត ដែលថតចំពីមុខ ទំហំ ៤គុណនឹង៦ ពីរសន្លឹក។

២. វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬអាជ្ញាប័ណ្ណធ្វើអាជីវកម្មថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។

៣. វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ប្រសិនបើមាន។

៤. សេចក្តីចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់អ្នកតំណាង។

៥. សេចក្តីចម្លងនៃអត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនថតចម្លងរបស់អភិបាលទាំងអស់

៦. លិខិតបញ្ជាក់គណនីនៅធនាគារ។

សម្គាល់៖ នៅក្នុងការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ចំពោះរូបវន្តបុគ្គល ត្រូវបង់ចំនួន ២០,០០០ រៀល និងនីតិបុគ្គលបង់ ចំនួន ៥០,០០០ រៀល។ ក្រុមហ៊ុនមូលបត្រដែលវិនិយោគិនត្រូវជ្រើសរើសមានដូចជា៖

- ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ (Securities Underwriter/6SF)
- ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មជួញដូរមូលបត្រ (Securities Dealers/1SF)
- ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មជើងសារមូលបត្រ (Securities Brokers/2SF)

[26] គោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន, លេខ០០១គ.ម/គ.ណ.ន, ០៦ កុម្ភៈ ២០១២

- ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ (Investment Advisers/2SF)

#### ៤.៤.១.២. ការស្នើសុំអត្តសញ្ញាណវិនិយោគិន

មុននឹងធ្វើការវិនិយោគលើទីផ្សារ វិនិយោគិនធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក។ ការស្នើសុំអាចធ្វើឡើង ដោយសាមីខ្លួនវិនិយោគិនផ្ទាល់ទៅ គ.ម.ក ឬ តាមរយៈក្រុមហ៊ុនមូលបត្រដែលបានជ្រើសរើសរួច។ ក្នុងនោះ គ.ម.ក តម្រូវឲ្យរូបវន្តបុគ្គលបង់ថ្លៃសេវាចំនួន ២០,០០០ រៀល និងនីតិបុគ្គលត្រូវបង់សេវាចំនួន ៥០,០០០ រៀល។ គណៈកម្មការមូលបត្រកម្ពុជានឹងផ្តល់ជូននូវលេខអត្តសញ្ញាណវិនិយោគិនដោយផ្ទាល់ ឬ តាមរយៈក្រុមហ៊ុនមូលបត្រ ក្នុងរយៈពេល ០២ ថ្ងៃនៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមទម្រង់អេឡិចត្រូនិច (Soft Copy) ឬ រយៈពេល ០៥ ថ្ងៃនៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមទម្រង់បោះពុម្ព (Hard Copy)។ លេខអត្តសញ្ញាណវិនិយោគិន មានសុពលភាពរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដែល គ.ម.ក បានផ្តល់ជូនលេខអត្តសញ្ញាណដល់វិនិយោគិន។ វិនិយោគិនអាចបន្តការប្រើប្រាស់ លេខអត្តសញ្ញាណវិនិយោគិនបាន ដោយដាក់ពាក្យស្នើសុំបន្តការប្រើប្រាស់ ក្នុងរយៈពេល ០៣ ខែមុនថ្ងៃផុតកំណត់[27]។

#### ៤.៤.១.៣. ការបើកគណនីជួញដូរ

បន្ទាប់ពីទទួលបានលេខអត្តសញ្ញាណវិនិយោគិន វិនិយោគិនត្រូវធ្វើការបំពេញ ពាក្យស្នើសុំបើកគណនីជួញដូរ និងចុះកិច្ចព្រមព្រៀងអតិថិជននៅក្រុមហ៊ុនមូលបត្រណាមួយដែលជាសមាជិករបស់ ផ.ម.ក នៅមួយថ្ងៃមុនថ្ងៃជួញដូរ។ ការបើកគណនីជួញដូរនេះ វិនិយោគិនមានសិទ្ធិបើកគណនីតែមួយ នៅក្រុមហ៊ុនមូលបត្រមួយ។ នៅពេលគណនីបានបើករួច វិនិយោគិនត្រូវរងចាំដល់ថ្ងៃធ្វើការបន្ទាប់ ទើបអាចដាក់បញ្ជាជួញដូរបាន។

#### ៤.៤.១.៤. ការបើកគណនីសាច់ប្រាក់

បន្ទាប់ពីការបើកគណនីជួញដូររួចរាល់ វិនិយោគិនត្រូវបើកគណនីសាច់ប្រាក់ ដែលវិនិយោគិនអាចយកសាច់ប្រាក់ទៅបញ្ចូលក្នុងគណនីនោះតែម្តង ឬអាចផ្ទេរពីគណនីសាច់ប្រាក់សម្រាប់ជួញដូរមូលបត្រ។ នៅពេលគណនីជួញដូរមានសុពលភាពហើយ វិនិយោគិនអាចទិញ ឬលក់ភាគហ៊ុន ដែលចុះបញ្ជីនៅ ផ.ម.ក បាន តាមរយៈក្រុមហ៊ុនមូលបត្រដែលខ្លួនបានបើកគណនីជួញដូរនៅទីនោះ។

[27] គោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន, លេខ០០១គ.ម/គ.ណ.ន, ០៦ កុម្ភៈ ២០១២

#### ៤.៤.១.៥. ការដាក់បញ្ជា

បន្ទាប់ពីទទួលបានលេខអត្តសញ្ញាណវិនិយោគិន និង បានបើកគណនីជួញដូរមូលបត្ររួច ហើយ វិនិយោគិនអាចធ្វើការដាក់បញ្ជាទិញ លក់មូលបត្រ តាមរយៈក្រុមហ៊ុនទៅកាន់ជ.ម.ក បាន។ ប៉ុន្តែមុននឹងដាក់បញ្ជាបាន វិនិយោគិនត្រូវមានសាច់ប្រាក់យ៉ាងហោចណាស់ ១០០% (សម្រាប់បញ្ជាទិញ) និងមានមូលបត្រយ៉ាងហោចណាស់ ១០០% (សម្រាប់បញ្ជាលក់) នៃបញ្ជាសរុប។ នៅពេលបញ្ជាត្រូវបានបញ្ជូន សាច់ប្រាក់ និងមូលបត្រទាំងនេះនឹងត្រូវបានបង្កដោយក្រុមហ៊ុនផ្សារមូលបត្រ ក្នុងគោលការដើម្បីទូទាត់ ឬ បង្កទុករហូតដល់បញ្ជាអស់សុពលភាព។

វិនិយោគិនត្រូវដាក់ពាក្យទៅ ជ.ម.ក ដោយភ្ជាប់នូវព័ត៌មាននៃការដាក់បញ្ជាដូចខាងក្រោម៖

- ឈ្មោះវិនិយោគិន
- លេខអត្តសញ្ញាណវិនិយោគិន
- លេខគណនីជួញដូរ
- ឈ្មោះមូលបត្រ
- ប្រភេទបញ្ជា (ទិញ លក់ កែប្រែ ឬ លុប)
- លេខបញ្ជាដើមក្នុងករណីជាបញ្ជាកែប្រែ ឬ លុប
- បរិមាណ
- ថ្លៃ។

### ៤.៤.២. វិធាននៃប្រតិបត្តិការជួញដូរលើទីផ្សារ

#### ៤.៤.២.១. ពេលវេលានៃការជួញដូរ

ផ្សារមូលបត្រកម្ពុជា អនុវត្តការជួញដូរមូលបត្រកម្មសិទ្ធិដូចខាងក្រោម[28]៖

- ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រលើកលែងតែថ្ងៃឈប់សម្រាកជាសាធារណៈ។
- ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ០៨:០០ ព្រឹក រហូតដល់ ១១:៣០ ព្រឹក។
- ការអនុវត្តការជួញដូរ ឬ ការផ្គូផ្គងធ្វើឡើង ០៦ (ប្រាំមួយ) ដងក្នុងមួយថ្ងៃ។
    - ការផ្គូផ្គងលើកទី១ នៅម៉ោង ០៩:០០ ព្រឹក
    - ការផ្គូផ្គងលើកទី២ នៅម៉ោង ០៩:៣០ ព្រឹក

[28] សៀវ សុស៊ីខា, Listing and Securities Trading on CSX, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

- ការផ្តូផ្គងលើកទី៣ នៅម៉ោង ១០:០០ ព្រឹក
- ការផ្តូផ្គងលើកទី៤ នៅម៉ោង ១០:៣០ ព្រឹក
- ការផ្តូផ្គងលើកទី៥ នៅម៉ោង ១១:០០ ព្រឹក
- ការផ្តូផ្គងលើកទី៦ នៅម៉ោង ១១:៣០ ព្រឹក

• ចំពោះរូបិយប័ណ្ណបរទេសត្រូវប្តូរទៅជារូបិយប័ណ្ណជាតិ។

**រូបភាពទី ៤.១៖ ពេលវេលានៃការជួញដូរ (ម៉ោងជួញដូរ និងថ្ងៃជួញដូរ)**

| វគ្គជួនដូរ | ម៉ោងបិទ/បើកវគ្គ | ចំនួនជួញដូរ | ម៉ោងជួញដូរ | វិធីសាស្ត្រជួញដូរ |
|---|---|---|---|---|
| វគ្គបើក | ០៨:០០ - ០៩:០០ ព្រឹក | ០១ ដង | ០៩:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គជួញដូរនិរន្តន៍ | ០៩:០០ - ១១:០០ ព្រឹក | មិនកំណត់ | ០៩:០០ - ១១:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃច្រើន (មានករណីលើកលែង) |
| វគ្គបិទ | ១១:០០ - ១១:៣០ ព្រឹក | ០១ ដង | ១១:៣០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |

#### ៤.៤.២.២. ឯកតាបញ្ជា និងឯកតាគម្លាត

ឯកតាបញ្ជាមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជា គឺ ០១ (មួយ) ឯកតាមូលបត្រ។ បរិមាណជួញដូរមូលបត្រកម្មសិទ្ធិអប្បបរមាក្នុងមួយប្រតិបត្តិការនៅ ផ.ម.ក គឺ ០១ (មួយ) ឯកតាមូលបត្រ។

ឯកតាគម្លាតតម្លៃ សម្រាប់ថ្លៃនៃមូលបត្រនីមួយៗត្រូវបានកំណត់ដូចខាងក្រោម[29]៖

**តារាងទី ៤.១៖ ឯកតាជួញដូរ និងឯកតាគម្លាតថ្លៃ**

| ថ្លៃ (P) | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាដែលខុស | ឧទាហរណ៍ថ្លៃបញ្ជាដែលត្រឹមត្រូវ |
|---|---|---|---|
| P < ៤.០០០ | ១០ | ២.៥៥៥; ៣.០១២; ៣.៩៩៩ | ២.៥៥០; ២.៥៦០; ៣.០១០; ៣.០២០; ៣.៩៩០ |
| ៤.០០០ ≤ P < ២០.០០០ | ២០ | ៤.២១០; ១៩.៥២៥ | ៤.២០០; ៤.២២០; ១៩.៥២០; ១៩.៥៤០ |
| ២០.០០០ ≤ P < ៤០.០០០ | ៥០ | ២០.១១០; ៣៥.៥៣០ | ២០.១០០; ២០.១៥០; ៣៥.៥០០; ៣៥.៥៥០ |
| ៤០.០០០ ≤ P < ១០០.០០០ | ១០០ | ៥០.៧២០; ៩០.៤៥០ | ៥០.៧០០; ៥០.៨០០; ៩០.៤០០; ៩០.៥០០ |
| ១០០.០០០ ≤ P < ២០០.០០០ | ២០០ | ១៥០.៥០០; ១២៥.៣០០ | ១៥០.៤០០; ១៥០.៦០០; ១២៥.២០០; ១២៥.៤០០ |
| ២០០.០០០ ≤ P < ៤០០.០០០ | ៥០០ | ៣០០.១០០; ៣៥០.២០០ | ៣០០.០០០; ៣០០.៥០០; ៣៥០.០០០; ៣៥០.៥០០ |
| P ≥ ៤០០.០០០ | ១.០០០ | ៦២០.៥០០; ៨៥២.១០០ | ៦២០.០០០; ៦២១.០០០; ៨៥២.០០០; ៨៥៣.០០០ |

[29] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ឯកតាគម្លាតតម្លៃ, http://csx.com.kh/operation/stock/listPosts.do?MNCD=30202 (ចូលទស្សនាថ្ងៃទី០៦ កក្កដា ២០១៩)

#### ៤.៤.២.៣. ដែនកំណត់នៃការប្រែប្រួលថ្លៃមូលបត្រ

ដែនកំណត់នៃការប្រែប្រួលថ្លៃមូលបត្រ សម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់លើកដំបូង (ថ្លៃដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីនៅ គ.ម.ក) នៅលើទីផ្សារបន្ទាប់គឺចន្លោះពី ៩០% ទៅ ១៥០% មានន័យថាវាប្រែប្រួលពី ១០% ទៅ ៥០% នៃថ្លៃមូលដ្ឋាន ។ ចំណែកដែនកំណត់បម្រែបម្រួលប្រចាំថ្ងៃគឺ អនុញ្ញាតឲ្យប្រែប្រួលពី -១០% ទៅ +១០% នៃថ្លៃមូលដ្ឋាន។ វិនិយោគិនអាចដាក់បញ្ជាបានតែក្នុងចន្លោះនោះទេ បើដាក់ខុសពីបម្រែបម្រួលនេះមិនអាចបញ្ជាបានទេ។

#### ៤.៤.២.៤. គោលការណ៍ដេញថ្លៃ

រាល់ការជួញដូរទាំងអស់ ត្រូវបានអនុវត្តតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃ ដោយយកថ្លៃតែមួយ (Single Price Auction)។

អាទិភាពនៃការបញ្ជាទិញ និងបញ្ជាលក់ត្រូវស្របតាមគោលការណ៍ដូចខាងក្រោម[30]៖

**១. ករណីតាមគោលការណ៍**

**ក. អាទិភាពដោយគិតលើថ្លៃ (Price Priority)**

- បញ្ជាលក់ ដែលមានថ្លៃទាបជាង មានអទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង។
- បញ្ជាទិញ ដែលមានថ្លៃខ្ពស់ជាង មានអទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

**តារាងទី ៤.២៖ គោលការណ៍ដេញថ្លៃយកថ្លៃតែមួយ**

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | ៧.៥០០ | |
| ① ~~៣០០~~ | ៧.៤០០ | ~~៧០០~~ ៥០ |
| ③ ~~៥០~~ ② ~~៦០០~~ | ៧.៣០០ | |
| ④ ~~១០០~~ | ៧.២០០ | |
| **៦៥០** | **សរុប** | **៧០០** |

ថ្លៃជួញដូរគឺ ៧,៤០០ ៛ ហើយបរិមាណចំនួន ៦៥០ ភាគហ៊ុន នឹងត្រូវបានជួញដូរ។

តម្លៃជួញដូរ = បរិមាណជួញដូរ × ថ្លៃជួញដូរ ឬ ៦៥០ × ៧,៤០០ ៛ = ៤,៨១០,០០០ ៛

[30] សៀវ សុស៊ីខា, Listing and Securities Trading on CSX, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ)

### ខ. អទិភាពដោយគិតលើរយៈពេល (Time Priority)

ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអទិភាពលើបញ្ជាដែលទទួលបានក្រោយ។

**តារាងទី ៤.៣៖ គោលការណ៍ដេញថ្លៃយកថ្លៃច្រើន**

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | : | |
| | ៦.៥០០ | ①៥០០(បញ្ជាទិញដែលមានថ្លៃខ្ពស់ជាង) |
| | ៦.៤៨០ | ②១០០③២០០ |
| | ៦.៤៦០ | |
| ③៣០០②២០០ | ៦.៤២០ | |
| (បញ្ជាលក់ដែលមានថ្លៃទាបជាង) ①៤៥០ | ៦.៤០០ | |
| | : | |

### ២. ករណីនៃការបញ្ជាព្រមពេលគ្នា

ក្នុងករណីការបញ្ជាមានបរិមាណស្មើគ្នាការបញ្ជានៅពេលដូចគ្នា និងថ្លៃដូចគ្នា។ ក្នុងករណីការបញ្ជាមានបរិមាណស្មើគ្នាការបញ្ជាដែល ផ.ម.ក ទទួលបានមុនតាមរយៈប្រព័ន្ធជួញដូរត្រូវមានអទិភាព។

ការបែងចែកបរិមាណមូលបត្រ សម្រាប់ការបញ្ជាព្រមពេលគ្នា ត្រូវអនុវត្តតាមលំដាប់លំដោយអទិភាពដូចខាងក្រោម៖

- ១០០ ដងនៃឯកតាជួញដូរ
- ៥០០ ដងនៃឯកតាជួញដូរ
- ១០០០ ដងនៃឯកតាជួញដូរ
- ៥០% នៃបរិមាណដែលនៅសល់។ បើសិនបរិមាណនោះទាបជាងឯកតាជួញដូរ ត្រូវកំណត់យកត្រឹមឯកតាជួញដូរ។
- បរិមាណដែលនៅសល់ទាំងអស់ត្រូវផ្តល់ឲ្យតាមអទិភាព

**តារាងទី ៤.៤៖ គោលការណ៍ដេញថ្លៃករណីបញ្ជាទិញព្រមគ្នា**

| បញ្ជាលក់ | | | | តម្លៃ | បញ្ជាទិញ | | | |
|---|---|---|---|---|---|---|---|---|
| ៤,០០០ | ១,៥០០ | ៦០០ | (៦,១០០) | ៧,២០០ | ១,០០០[១] | ២០០[២] | ១០,០០០[៣] | ៥,០០០[៤] |
| | ១,៧០០ | ១,៥០០ | (៣,២០០) | ៧,១០០ | ៥០០ | ៧០០ | | |
| | ១,៣០០ | ១,០០០ | (២,៣០០) | ៧,០០០ | ៤០០ | | | |
| | | ៨០០ | (៨០០) | ៦,៩០០ | | | | |
| | | ៧០០ | (៧០០) | ៦,៨០០ | | | | |
| | | | ១៣,១០០ | សរុប | ១៦,២០០ | | | |

❖ កំណត់សម្គាល់

- ១,០០០[១]៖ ការបញ្ជាទិញចំនួន ១,០០០ នៅលើកទី១
- ២០០[២]៖ ការបញ្ជាទិញចំនួន ២០០ នៅលើកទី២
- ១០,០០០[៣]៖ ការបញ្ជាទិញចំនួន ១០,០០០ នៅលើកទី៣
- ៥,០០០[៤]៖ ការបញ្ជាទិញចំនួន ៥,០០០ នៅលើកទី៤

**តារាងទី ៤.៥៖ ការគណនាបរិមាណជួញដូរដោយបញ្ជាទិញព្រមគ្នា**

| | លើកទី១ (១០០) | លើកទី១ (៥០០) | លើកទី១ (១,០០០) | លើកទី១ (១/២) | លើកទី១ (នៅសល់) | បរិមាណជួញដូរ |
|---|---|---|---|---|---|---|
| **បញ្ជាទិញទី៣ (១០,០០០)** | ១០០ | ៥០០ | ១,០០០ | ៤,២០០ | ២,៨០០ | ៨,៦០០ |
| **បញ្ជាទិញទី៤ (៥,០០០)** | ១០០ | ៥០០ | ១,០០០ | ១,៧០០ | ០ | ៣,៣០០ |
| **បញ្ជាទិញទី១ (១,០០០)** | ១០០ | ៥០០ | ៤០០ | ០ | ០ | ១,០០០ |
| **បញ្ជាទិញទី២ (២០០)** | ១០០ | ១០០ | ០ | ០ | ០ | ២០០ |
| **សរុប** | ៤០០ | ១,៦០០ | ២,៤០០ | ២,៨០០ | ២,៨០០ | ១៣,១០០ |

**៤.៤.២.៥. ថ្លៃពិសេស**

ថ្លៃពិសេស សំដៅលើថ្លៃបិទនៃភាគហ៊ុនមួយដែលគ្មានការជួញដូរហូតដល់ម៉ោងបិទទីផ្សារ ថ្លៃពិសេស អាចជាថ្លៃល្អបំផុតនៃសំណើលក់ ដែលថ្លៃនៃសំណើលក់នេះទាបជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងសម្រាប់ថ្ងៃជួញដូរលើកដំបូង(សម្រាប់ថ្ងៃជួញដូរលើកដំបូង) ឬ ជាថ្លៃល្អបំផុតនៃសំណើទិញ ដែលថ្លៃនៃសំណើទិញនេះខ្ពស់ជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង(សម្រាប់ថ្ងៃជួញដូរលើកដំបូង)[31]។

**៤.៤.៣. ដំណើរការនៃការជួញដូរមូលបត្រក្នុងទីផ្សារបន្ទាប់**

ដំណើរការជួញដូរមូលបត្រនេះ ស្ថិតនៅក្រោមវិធានប្រត្តិបត្តិការទីផ្សារមូលបត្រកម្ពុជានៅពេលដែលមូលបត្របានចុះបញ្ជីរួចនៅលើទីផ្សាមូលបត្រ។

បន្ទាប់ពីវិនិយោគិនបានទទួលបានលេខអត្តសញ្ញាណវិនិយោគិន បើកគណនីជួញដូរ និងធ្វើការជ្រើសរើសក្រុមហ៊ុនមូលបត្ររួច វិនិយោគិនអាចចាប់ផ្តើមធ្វើការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ។

❖ **ថ្ងៃជួញដូរ(T0)**

មុននឹងធ្វើការជួញដូរ វិនិយោគិនត្រូវបញ្ចូលសាច់ប្រាក់ទៅក្នុងគណនីជួញដូរ របស់ក្រុមហ៊ុនមូលបត្រអោយបានមុនម៉ោងជួញដូរ។ ម៉ោងជួញដូរនៅ ផ.ម.ក ត្រូវបានបែងចែកជាពីវគ្គ (Trading Session) ដែលវគ្គទីមួយចាប់ផ្តើមពីម៉ោង ៨:០០ ដល់ម៉ោង ៩:០០ ព្រឹក និងវគ្គទីពីរចាប់ផ្តើមពីម៉ោង ៩:០០ ដល់ម៉ោង ១១:៣០ ព្រឹក។

ការទទួលបញ្ជាទិញ ឬលក់មូលបត្រគឺចាប់ពីម៉ោង៨:០០ ដល់ម៉ោង ១១:៣០ ព្រឹក ប៉ុន្តែការអនុវត្តជួញដូរ គឺធ្វើឡើងចំនួនពីរដង គឺនៅម៉ោង ៩:០០ ព្រឹកម្តង និងម៉ោង ១១:០០ ព្រឹកម្តងទៀត។ ក្រោយពីការជួញដូរត្រូវបានបញ្ចប់នៅម៉ោង ១១:៣០ ព្រឹកនៃថ្ងៃជួញដូរ (T0) រហូតដល់មុនម៉ោង ១២:០០ ថ្ងៃត្រង់ នៃថ្ងៃជួញដូរ (T+1) គឺជាកំឡុងពេលសម្រាប់ការកែបញ្ជាទិញ ឬលក់មូលបត្រ។

❖ **មួយថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+1)**

ពីម៉ោង ១២:១៥ នាទីថ្ងៃត្រង់ ប្រត្តិបត្តិការប្រព័ន្ធជាត់ទាត់ និងទូទាត់ (ផ.ម.ក) ចាប់ផ្តើមធ្វើការផាត់ទាត់សាច់ប្រាក់ និងមូលបត្រ ដើម្បីស្វែងរកលទ្ធផលនៃចំនួនសាច់ប្រាក់ និងចំនួនមូលបត្រសរុបដែលវិនិយោគិនម្នាក់ៗត្រូវទទួលបាន។

[31] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ថ្លៃពិសេស, http://csx.com.kh/operation/stock/listPosts.do?MNCD=30202 (ចូលទស្សនាថ្ងៃទី០៦ កក្កដា ២០១៩)

ពីម៉ោង១១:៣០ ដល់ម៉ោង ២:៣០ នាទីថ្ងៃ ឬ មុនម៉ោង ២:៣០ នាទី ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ ចេញសេចក្តីណែនាំសម្រាប់ធ្វើការទូទាត់ (Settlement Instruction) ទៅកាន់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនិងមូលបត្រ (CSA) និងក្រុមហ៊ុនមូលបត្រ (SF)។ ការចេញសេចក្តីណែនាំនេះ គឺធ្វើឡើងដោយ ស្វ័យប្រវត្តិពីប្រព័ន្ធបច្ចេកវិទ្យារបស់ ផ.ម.ក។

❖ **ពីរថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ(T+២)**

មុនម៉ោង ៨:៣០ នាទីព្រឹក ក្រុមហ៊ុនមូលបត្រដែលជាអ្នកទិញ ផ្ទេរសាច់ប្រាក់ពីគណនីក្រុមហ៊ុនមូលបត្រចូលទៅក្នុងគណនីរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (CSO Account)។

ម៉ោង១១:៣០ នាទីព្រឹក សាច់ប្រាក់ត្រូវបានផ្ទេរពីគណនីប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (CSO) ទៅគណនីក្រុមហ៊ុនមូលបត្រ (SF) ដែលជាអ្នកលក់។ ស្របពេលជាមួយគ្នាមូលបត្រត្រូវបានផ្ទេរពីគណនីក្រុមហ៊ុនមូលបត្រដែលជាអ្នកលក់ ទៅគណនីក្រុមហ៊ុនមូលបត្រដែលជាអ្នកទិញ តាមរយ:គណនីមូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (CSO Account)។

**រូបភាពទី ៤.២៖ គំនូសតាងដំណើរការជួញដូរ**



១. វិនិយោគិនបើកគណនីជួញដូរ (គណនីមូលបត្រ និងគណនីសាច់ប្រាក់) នៅក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T-1។ ក្រុមហ៊ុនមូលបត្រនឹងធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនជូនអតិថិជនរបស់ខ្លួនពីគណៈកម្មការមូលបត្រកម្ពុជា។

២. វិនិយោគិនផ្តល់សេចក្តីបង្គាប់ឲ្យដាក់បញ្ជាទិញ ឬលក់នៅថ្ងៃ T+0 ទៅកាន់ក្រុមហ៊ុនមូលបត្រជាលាយលក្ខណ៍អក្សរ ជាពាក្យសម្តី (ត្រូវបានថតទុកដោយអ្នកតំណាងនៅក្នុងទីផ្សារ) ឬមធ្យោបាយអេឡិចត្រូនិចនានា។

៣. ក្រោយពីត្រួតពិនិត្យមូលបត្រ និងសាច់ប្រាក់នៅក្នុងគណនីរបស់វិនិយោគិន (សាច់ប្រាក់ ឬបរិមាណមូលបត្រមួយរយភាគរយដែលពាក់ព័ន្ធនឹងបញ្ជានោះ) អ្នកតំណាងនៅក្នុងទីផ្សារដាក់បញ្ជាតាមការបង្គាប់មកក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. នៅថ្ងៃ T+0។ សាច់ប្រាក់ ឬមូលបត្រនឹងត្រូវបានបង្កកទុកសម្រាប់ទូទាត់នៅថ្ងៃ T+2។

៤. ការបញ្ជាទាំងឡាយត្រូវបានផ្គូរផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។

៥. ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0។

៦. ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួន នៅថ្ងៃT+0។

៧. ក្នុងករណីមានកំហុសឆ្គងដែលបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ ផ.ម.ក. ដើម្បីកែតម្រូវអោយបានមុនពេលថ្ងៃត្រង់នៃថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំនុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

៨. វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រនៅថ្ងៃ T+2។

៩. ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមជាវិនិយោគិននៅ ផ.ម.ក.[32]។

### ៤.៤.៤. យន្តការនៃការផាត់ទាត់ និងទូទាត់

ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទូទាត់សាច់ប្រាក់ និងទូទាត់មូលបត្រនៅក្នុងដំណើរការនៃការផាត់ទាត់ និងទូទាត់មូលបត្រកម្មសិទ្ធិ សមាជិក នៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិករផាត់ទាត់ និងទូទាត់មូលបត្រ តម្រូវឲ្យបើកគណនី ០២ ប្រភេទ គឺបើកគណនីទូទាត់សម្រាប់ការទូទាត់សាច់ប្រាក់ និងគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ។

[32] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ដំណើរការជួញដូរ, http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី ២៦ មិថុនា ឆ្នាំ ២០១៩)

#### ៤.៤.៤.១. ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់សាច់ប្រាក់

មុននឹងចាប់ផ្តើម ប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ អាចដំណើរការទៅបាន គ្រប់សមាជិក និងអ្នកពាក់ព័ន្ធនិងការទូទាត់សាច់ប្រាក់ ចាំបាច់ត្រូវបើកគណនីទូទាត់សាច់ប្រាក់ ក្នុងគោលបំណងបំពេញកាតព្វកិច្ចក្នុងការទូទាត់សាច់ប្រាក់ ពេលធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

សមាជិកទាំងអស់តម្រូវឲ្យបើកគណនីសាច់ប្រាក់ ៣ សំខាន់ៗគឺ[33]៖

- គណនីទូទាត់សាច់ប្រាក់ក្នុងនាមខ្លួនផ្ទាល់ (Cash Account)៖ បើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។ បន្ទាប់ពីបានបើកគណនីសាច់ប្រាក់ ឬ មានការផ្លាស់ប្តូរគណនីសាច់ប្រាក់ សមាជិកត្រូវរាយការណ៍អំពីឈ្មោះនៃភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន និងលេខគណនីទូទាត់ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ យ៉ាងហោចណាស់ ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមជួញដូរ។
- គណនីទូទាត់សាច់ប្រាក់ក្នុងនាមអតិថិជន (Client Money Account)៖ បើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ក្រោមឈ្មោះរបស់ក្រុមហ៊ុនមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់នៅក្នុងប្រតិបត្តិការជួញដូរមូលបត្រ។ អតិថិជនអាចធ្វើការទូទាត់សាច់ប្រាក់ជាប្រាក់រៀល ឬ ដុល្លារអាមេរិចបាន ដែលនេះជាកត្តាមួយដែលបង្កភាពងាយស្រួលដល់អតិថិជន។
- គណនីទូទាត់ទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (Cash Settlement Account)៖ បើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) ជាប្រាក់រៀល ដើម្បីអនុញ្ញាតឲ្យប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (CSO) បំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់ទៅឲ្យសមាជិករបស់ខ្លួននៅកាលបរិច្ឆេទទូទាត់ជាប្រាក់រៀល តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់សមាជិកទៅគណនីទូទាត់សាច់ប្រាក់ របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវផ្ទេរសាច់ប្រាក់ដែលទទួលបាននេះ ទៅសមាជិក

[33] សៀវ សុស៊ីខា, ប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ រក្សាទុកមូលបត្រកម្មសិទ្ធិ, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

ដែលត្រូវទទួលបានការទូទាត់សាច់ប្រាក់។

ចំពោះគណនីទូទាត់សាច់ប្រាក់ដែលបើករួច គឺអាចបិទបានក្នុងករណីដូចខាងក្រោម៖

១. សមាជិកបើកគណនីទូទាត់សាច់ប្រាក់ ដោយមិនបានធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់រវាងគ្នា និងគ្នាទាល់តែសោះអស់រយៈពេល ០២ ឆ្នាំ ដូចនេះ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) មានសិទ្ធិក្នុងការបិទគណនីទូទាត់សាច់ប្រាក់មួយនោះ។

២. សមាជិកស្នើសុំបិទគណនីទូទាត់សាច់ប្រាក់ដោយខ្លួនឯង។

### ៤.៤.៤.២. ការបើកគណនីសាច់ប្រាក់សម្រាប់ការទូទាត់មូលបត្រ

ចំពោះប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ កាលបើកគណនីទូទាត់សាច់ប្រាក់តែមួយដើម្បីបំពេញការទូទាត់ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ដូច្នេះសមាជិក និងអ្នកពាក់ព័ន្ធនឹងការទូទាត់មូលបត្រចាំបាច់ ត្រូវបើកគណនីមួយប្រភេទទៀតគឺគណនីមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចក្នុងការទូទាត់មូលបត្រ ក្នុងប្រតិបត្តិការជួញដូរ។

ក្រុមហ៊ុនមូលបត្រត្រូវបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ក្រោមឈ្មោះរបស់ក្រុមហ៊ុនមូលបត្រ ស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ របស់ប្រតិបត្តិការរក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចក្នុងការទូទាត់មូលបត្រ។

ក្រុមហ៊ុនមូលបត្រត្រូវបើកគណនីទូទាត់មូលបត្រតំណាងឲ្យអតិថិជន នៅប្រតិបត្តិកររក្សាទុកមូលបត្រ ដោយដាក់ក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ និងត្រូវចុះបញ្ជីក្រោមឈ្មោះរបស់កម្មសិទ្ធិករមូលបត្រ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចក្នុងការទូទាត់មូលបត្រនិងធានាដល់ការទូទាត់មូលបត្រដែលជាសមាជិក។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីមូលបត្ររបស់សមាជិកទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះ ទៅសមាជិកដែលត្រូវទទួលបានការទូទាត់មូលបត្រ។

ក្នុងករណីបិទគណនីមូលបត្រ ក្រុមហ៊ុនមូលបត្រត្រូវគោរពតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រដូចខាងក្រោម៖

១. ធ្វើការស្នើសុំបិទគណនីទូទាត់មូលបត្រសមាជិកផ្ទាល់។

២. បន្ទាប់ពីសមាជិកបើកគណនីទូទាត់មូលបត្ររួច មិនមានប្រតិបត្តិការទូទាត់មូលបត្រ ឬ ការផ្ទេរមូលបត្ររវាងគណនី និងគណនី ដូច្នេះប្រតិបត្តិកររក្សាទុកមូលបត្រមានសិទ្ធិក្នុងការបិទគណនីទូទាត់មូលបត្រនេះ។

### ៤.៤.៤.៣. ដំណើរការផាត់ទាត់

នៅពេលពត៌មានជួញដូរត្រូវបានបញ្ជាក់ដោយអតិថិជន និងបានផ្ទៀងផ្ទាត់ដោយសមាជិកទាំងអស់ដែលតំណាងអោយអតិថិជនរួចហើយ ក្រុមហ៊ុនមូលបត្រត្រូវតាំងនាមឲ្យអតិថិជន ក្នុងការទូទាត់សាច់ប្រាក់សម្រាប់មូលបត្រដែលបានទិញ ឬ បញ្ជូនមូលបត្រដែលបានលក់ទៅកាន់ភាគីម្ខាងទៀតដែលជាសមាជិកនិងជាអន្តរការីរបស់អ្នកលក់មូលបត្រ ឬ អ្នកទទួលមូលបត្រដែលបានប្រើប្រាស់សាច់ប្រាក់ ឬ មូលបត្រដែលបានបង្កកទុករួចហើយ ក្នុងភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនិងមូលបត្រ (CSA)។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងការទូទាត់មូលបត្រ ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ចុងក្រោយដោយសមាជិកនិងត្រូវធ្វើការបន្សុទ្ធ ឬកាត់កង(Netting) ចំនួនមូលបត្រនិងសាច់ប្រាក់ដែលត្រូវទូទាត់ក្នុងថ្ងៃដូចគ្នារបស់សមាជិកនីមួយៗ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងការទូទាត់មូលបត្រ ត្រូវជូនព័ត៌មានដូចខាងក្រោមទៅដល់សមាជិកនៅកាលបរិច្ឆេទការផាត់ទាត់ និងកាលបរិច្ឆេទការទូទាត់ ៖

១. កាលបរិច្ឆេទការផាត់ទាត់ និងកាលបរិច្ឆេទការទូទាត់

២. បរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជន។

៣. ទឹកប្រាក់ដែលត្រូវទូទាត់ផ្ទាល់ដោយសមាជិក ឬក្នុងនាមអតិថិជន។

❖ វិធីសាស្ត្រនៃការផាត់ទាត់

វិធីសាស្ត្រក្នុងការគណនាបរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ដែលត្រូវបានផាត់ទាត់មានដូចខាងក្រោម៖

១.ចំពោះមូលបត្រ៖ ត្រូវបានត្រូវបានគណនាដោយធ្វើការផាត់ទាត់បរិមាណសរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ សម្រាប់សមាជិកដែលពាក់ព័ន្ធ។

២.ចំពោះសាច់ប្រាក់៖ ត្រូវបានគណនាដោយធ្វើការផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សរុបសម្រាប់សមាជិកនីមួយៗដែលពាក់ព័ន្ធ។

**៤.៤.៤.៤. ដំណើរការទូទាត់**

ការទូទាត់ គឺជាការបញ្ចប់ប្រតិបត្តិការដែលអ្នកលក់ផ្ទេរមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុទៅអោយអ្នកទិញ ចំណែកអ្នកទិញបានផ្ទេរសាច់ប្រាក់ទៅអោយអ្នកលក់វិញ។

និតិវិធីនៃការផាត់ទាត់ និងការទូទាត់មូលបត្រមានដំណើរការដូចខាងក្រោម៖

១. ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវបញ្ជូនព័ត៌មានពីការជួញដូរដែលបានបន្សំរួចរាល់ (Confirmed Trading) ទៅប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។ បន្ទាប់មក ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវធ្វើការបន្សុទ្ធ ទាំងសាច់ប្រាក់ និងមូលបត្រទៅតាមព័ត៌មានដែលទទួលបាន។

២.ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្របញ្ជូនព័ត៌មាននៃកាលបរិច្ឆេទផាត់ទាត់ និងទូទាត់បរិមាណសាច់ប្រាក់ និងបរិមាណនីមួយៗនៃមូលបត្រ ដែលត្រូវការធ្វើការទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជន ទៅកាន់ក្រុមហ៊ុនមូលបត្រ (SFs) ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (CSA) និងប្រតិបត្តិកររក្សាទុកមូលបត្រ(CSD)។

៣.បន្ទាប់មកទៀតក្រុមហ៊ុនមូលបត្រត្រូវបានដាក់បញ្ជាទៅកាន់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនិងមូលបត្រ ដើម្បីធ្វើការទូទាត់សាច់ប្រាក់ ទៅអោយសមាជិកដែលត្រូវទទួលបានសាច់ប្រាក់ ឬ សមាជិកដែលបានលក់មូលបត្រ។

៤.ក្រុមហ៊ុនមូលបត្រត្រូវបានដាក់បញ្ជាទៅកាន់ប្រតិបត្តិកររក្សាទុកមូលបត្រដើម្បីធ្វើការផាត់ទាត់មូលបត្រទៅកាន់សមាជិកដែលត្រូវទទួលការមូលបត្រក្នុងនាមផ្ទាល់ ឬតាំងនាមអតិថិជន[34]។

ការផាត់ទាត់និងទូទាត់សម្រាប់ប្រតិបត្តិការជួញដូរនីមួយៗ៖

១. ករណីមូលបត្រ៖ ផាត់ទាត់ដោយ ផ.ម.ក និងទូទាត់ដោយ ផ.ម.ក។

២. ករណីសាច់ប្រាក់ផាត់ទាត់ដោយ ផ.ម.ក និងទូទាត់ដោយភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធ និងមូលបត្រ (CSA)[35]។

---

[34] ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ការផាត់ទាត់ និងទូទាត់សម្រាប់ប្រតិបត្តិការជួញដូរ, http://csx.com.kh/operation/clearing/listPosts.do?MNCD=3030 (ចូលទស្សនាថ្ងៃទី ០១ កក្កដា ២០១៩)

[35] សៀវ សុស៊ីខា, ប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ រក្សាទុកមូលបត្រកម្មសិទ្ធិ, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

**ក.ការទូទាត់សាច់ប្រាក់**

ការទូទាត់សាច់ប្រាក់ ជាផ្នែកមួយដ៏សំខាន់ក្នុងការជួញដូរមូលបត្រកម្មសិទ្ធ។ ដូចនេះដើម្បីបង្កលក្ខណៈងាយស្រួលដល់វិនិយោគិន ក្នុងការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងបំបាត់នូវកំហុសឆ្គង ដែលអាចកើតឡើងដោយយថាហេតុ នៅអំឡុងពេលប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ ផ្សារមូលបត្រកម្ពុជាបានបែងចែកការទូទាត់សាច់ប្រាក់ជា ០២ របៀបគឺ ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ និងការទូទាត់សាច់ប្រាក់ជាអន្តរធនាគារ ។

❖ **ការទូទាត់សាច់ប្រាក់ក្នុងធនាគារតែមួយ**

ក្រុមហ៊ុនផ្សារមូលបត្រ (ផ.ម.ក)ត្រូវបង្វែរសាច់ប្រាក់បន្ត ទៅគណនីទូទាត់សាច់ប្រាក់របស់អតិថិជន ក្នុងនាមជាអ្នកលក់ដែលបានបើកគណនី ក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ យ៉ាងយូរត្រឹមម៉ោង ១០:៣០ នាទីព្រឹក។ ចប់ម៉ោង ១០:៣០ នាទីនៃកាលបរិច្ឆេទទូទាត់ (T+២) ក្រុមហ៊ុនមូលបត្រត្រូវផ្ទេរសាច់ប្រាក់ចូលទៅក្នុងគណនីអតិថិជនដែលជាអ្នកលក់។

ក្រោយពីចប់សព្វគ្រប់ហើយ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវជូនដំណឹងដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រអំពីការទូទាត់សាច់ប្រាក់ដែលបានអនុវត្តរួច។

❖ **ការទូទាត់សាច់ប្រាក់ក្នុងអន្តរធនាគារ**

នៅក្នុងការទូទាត់សាច់ប្រាក់តាមរយៈធនាគារពីរផ្សេងគ្នាត្រូវបានអនុវត្តតាមដំណាក់កាលដូចខាងក្រោម៖

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្តល់ការប្រឹក្សាដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវផ្តល់ការប្រឹក្សាដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ (CSA1) ខាងអ្នកទិញ និងភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ (CSA2) ខាងអ្នកលក់ អំពីទម្រង់នៃការផ្ទេរសាច់ប្រាក់រវាងគ្នានិងគ្នា។ បន្ទាប់មកមុនម៉ោង៨:៣០ នាទីព្រឹកនៃការទូទាត់ (T+២) ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ ខាងអ្នកទិញ (CSA1) ត្រូវផ្ទេរសាច់ប្រាក់ពីគណនីអតិថិជនរបស់អ្នកទិញ ទៅកាន់គណនីទូទាត់សាច់ប្រាក់ក្នុងនាមជាអ្នកទិញ ដែលបើកក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ (CSO) ដែលបើកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនិងមូលបត្រខាងអ្នកទិញ (CSA1) យ៉ាងយូរមុនម៉ោង ៨:៣០ នាទីព្រឹក។ ក្រោយមកទៀត (CSA1) ត្រូវផ្ទេរសាច់ប្រាក់ ទៅកាន់គណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ដែលបើកនៅភ្នាក់ងារទូទាត់

សាច់ប្រាក់ពាក់ព័ន្ធនិងមូលបត្រខាងអ្នកលក់ (CSA2) ឆ្លងតាមរយៈសភាផាត់ទាត់នៃធនាគារជាតិនៃកម្ពុជា (NBC)។ នៅថ្ងៃដដែល ប្រតិបត្តិករផាត់និងទូទាត់មូលបត្រ ត្រូវផ្ទេរសាច់ប្រាក់ទៅគណនីទូទាត់សាច់ប្រាក់របស់អតិថិជន ដែលបើកក្រោមឈ្មោះក្រុមហ៊ុនមូលបត្រ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនិងមូលបត្រខាងអ្នកលក់ (CSA2) យ៉ាងយូរត្រឹមម៉ោង ១១:៣០ នាទីព្រឹក។ រួចមកក្រុមហ៊ុនមូលបត្រខាងអ្នកលក់ត្រូវផ្ទេរសាច់ប្រាក់បន្តទៅកាន់គណនីអតិថិជនរបស់អ្នកលក់។

ចុងបញ្ចប់ ក្រុមហ៊ុនមូលបត្រទាំងសងខាងត្រូវត្រួតពិនិត្យពីសមតុល្យសាច់ប្រាក់នៅក្នុងគណនីអតិថិជនថាតើក្នុងគណនីអតិថិជនខាងអ្នកលក់បានទទួលសាច់ប្រាក់តាមការទូទាត់ដែរឬទេ។

### ខ.ការទូទាត់មូលបត្រ

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ជូនដំណឹងដល់ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិការទីផ្សារមូលបត្រ អំពីការទូទាត់សាច់ប្រាក់ត្រូវបានបំពេញរួចរាល់ ចប់សព្វគ្រប់អស់ហើយបន្ទាប់មកប្រតិបត្តិកររក្សាទុកមូលបត្រត្រូវផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្រ (SF) ដែលតំណាងឲ្យអតិថិជន (អ្នកលក់) ទៅកាន់គណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្ររបស់ CSO ដែលបានបើកនៅក្នុងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីធ្វើការផាត់ទាត់មូលបត្រ នៅពេលមានប្រតិបត្តិការជួញដូរមូលបត្រកើតមានឡើង។ ក្រោយមកទៀតប្រតិបត្តិករប្រព័ន្ធផាត់ទាត់មូលបត្រ (CSO) ត្រូវធ្វើការផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ខ្លួន ទៅកាន់គណនីមូលបត្ររបស់ក្រុមហ៊ុនមូលបត្រ (SF) ដែលតំណាងឲ្យអតិថិជន (អ្នកទិញ)។

### ៤.៤.៥. យន្តការនៃការរក្សាទុកមូលបត្រ

ប្រតិបត្តិការរក្សាទុកមូលបត្រសំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើមូលបត្រ។ ការដាក់ផ្ញើមូលបត្រគឺជាដំណើរការនៃការផ្ទេរកម្មសិទ្ធិមូលបត្រ តាមរយៈការផ្ទេររវាងគណនី (Book Entry ឬ ការកត់ត្រាឥណទាន/ឥណពន្ធ ក្នុងសៀវភៅគណនីរបស់សមាជិក និងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវន្ត។

នៅពេលមូលបត្រមានការជួញដូររវាងវិនិយោគិន ប្រតិបត្តិកររក្សាទុកមូលបត្រធ្វើការទូទាត់នូវប្រតិបត្តិការទាំងនោះតាមរយៈការផ្ទេរគណនីរវាងគណនី (Book Entry) ដោយគ្មានការផ្ទេរ មូលបត្ររូបវន្ត។ ដូចនេះ ហានិភ័យកើតចំពោះការបាត់ និងការលួចមូលបត្រត្រូវបានជៀសវាងទាំងស្រុង ។ សមាជិក អ្នកចូលរួម និងអតិថិជន ដែលបានដាក់ផ្ញើមូលបត្រនៅ ផ.ម.ក. មិនចាំបាច់

ដកមូលបត្រទៅវិញ នៅពេលដែលត្រូវអនុវត្តសិទ្ធិកម្មសិទ្ធិករឡើយ។

បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្ររួមមាន ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។ បុគ្គលដែលមានបំណងបើកគណនីមូលបត្រត្រូវមានបំពេញបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ គ្រប់គណនីមូលបត្រទាំងអស់រួមមានគណនីមូលបត្ររបស់សមាជិក ឬ អតិថិជនត្រូវបានបង្កើតឡើងក្នុង ប្រព័ន្ធ Ledger របស់ ផ.ម.ក. ដែលផ្ទុកផងដែរនូវទិន្នន័យលម្អិតនៃប្រតិបត្តិការរបស់សមាជិក និងអតិថិជនព្រមទាំងទិន្នន័យលម្អិតនៃបញ្ជីភាគហ៊ុនិក។

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ បុគ្គលដែលដាក់ផ្ញើត្រូវផ្តល់ព័ត៌មានដូចខាងក្រោមដល់ប្រតិបត្តិកររក្សាទុកមូលបត្រ៖

- ប្រភេទមូលបត្រ
- ចំនួននៃការបោះផ្សាយ
- ឈ្មោះមូលបត្រ
- អក្សរកូដ
- ចំនួនមូលបត្រសរុប
- កាលបរិច្ឆេទបោះផ្សាយ
- កាលបរិច្ឆេទចុះបញ្ជី
- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពមូលបត្រ។

### ❖ សេចក្តីសន្និដ្ឋាន

ដំណើរការនៅក្នុងប្រតិបត្តិការផ្សារមូលបត្រ គឺផ្តោតសំខាន់លើប្រតិបត្តិការផ្សេងៗដែលទីផ្សារមូលបត្រមួយនេះ ប្រព្រឹត្តិទៅជាប្រចាំ ដែលការសិក្សានេះបានផ្តោតសំខាន់លើប្រតិបត្តិការចាប់តាំងពីការបោះផ្សាយលក់ រហូតដល់ការជួញដូរ។ ចំពោះការបោះផ្សាយលក់មូលបត្រជាសាធារណៈ គឺផ្តោតសំខាន់ការសិក្សាពី លក្ខខណ្ឌតម្រូវសម្រាប់ក្រុមហ៊ុន ឬស្ថាប័នដែលមានបំណងចង់បោះផ្សាយលក់មូលបត្រ នីតិវិធី និងឯកសារផ្សេងៗដែលក្រុមហ៊ុនបោះផ្សាយត្រូវគោរពតាម និងយន្តការនៃការបោះផ្សាយលក់មូលបត្រ រួមទាំងដំណើរការនៃការធ្វើប៊ុកបៀលឌីង និង ការធ្វើបរិវិសកម្មមូលបត្រ។ ជាងនេះទៅទៀតក៏បានផ្តោតសំខាន់ទៅលើការជួញដូរមូលបត្រ ដោយសិក្សាអំពីលក្ខខណ្ឌតម្រូវវិនិយោគិន វិធាននៃប្រតិបត្តិការជួញដូរ ការបើកគណនី ការដាក់បញ្ជា ជាពិសេសគឺដំណើរការក្នុងការទិញ លក់មូលបត្ររបស់វិនិយោគិន។

សរុបជារួមមក រាល់ប្រតិបត្តិការនៅក្នុងទីផ្សារមូលបត្រ ត្រូវតែមានការចូលរួមសហការជាមួយក្រុមហ៊ុន ប្រតិបត្តិករជំនាញផ្សេងៗ ដែលមានតួនាទីក្នុងទីផ្សារមួយនេះ។ រាល់ប្រតិបត្តិការនៅក្នុងផ្សារមូលបត្រនេះ វិនិយោគិន ឬក្រុមហ៊ុនបោះផ្សាយនិងភ្នាក់ងារពាក់ព័ន្ធត្រូវគោរពតាមបទប្បញ្ញត្តិផ្សេងៗដែលបានចែងសម្រាប់ដំណើរការផ្សារមូលបត្រនេះ ដើម្បីបញ្ចៀសនូវហានិភ័យដែលអាចនឹងកើតមានផ្សេងៗ និងដើម្បីទទួលបាននូវការអនុវត្តការងារបានយ៉ាងរលូន។

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទស្តីពី ប្រតិបត្តិការក្នុងទីផ្សារមូលបត្រកម្ពុជា រួចមក ខ្ញុំបានទទួលបាននូវចំណេះដឹងជាច្រើនដែលទាក់ទងទៅនឹងវិស័យមូលបត្រដែលរួមមាននូវដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដំណើរការនៅក្នុងការជួញដូរមូលបត្រនៅក្នុងផ្សារមូលបត្រ។ ជារួមមក តាមការសិក្សានេះផងដែរយើងបានសង្កេតថាដំណើរការនៅក្នុងផ្សារមូលបត្រ ទាំងការបោះផ្សាយលក់មូលបត្រ និងការជួញដូរមូលបត្រ ពិតជាមានភាពស្មុគស្មាញ និងមាននូវដំណាក់កាល និងនីតិវិធីជាច្រើន។ ជាក់ស្តែងនៅក្នុងការជួញដូរមូលបត្រ វាពិតជាមានដំណាក់កាលជាច្រើន និងស៊ាំញ៉ាំមែន ក៏ប៉ុន្តែមានពុំសូវមានផលវិបាកសម្រាប់វិនិយោគិននោះទេ ដោយសារតែវិនិយោគិនគ្រាន់តែធ្វើការជ្រើសរើសក្រុមហ៊ុនមូលបត្រដែលខ្លួនពេញចិត្ត ដើម្បីធ្វើជាតំណាងនៅក្នុងការជួញដូរមូលបត្រ បន្ទាប់មកគ្រាន់តែធ្វើការបើកនូវគណនីជួញដូរជាមួយក្រុមហ៊ុនមូលបត្រ និងធ្វើការដាក់បញ្ជាភ្ជាប់មកជាមួយនូវព័ត៌មានលម្អិត រួមមាន ប្រភេទនៃបញ្ជាទិញ ឬលក់ ឈ្មោះមូលបត្រ ថ្លៃជួញដូរ បរិមាណជួញដូរជាដើម។ បន្ទាប់ពីបញ្ជាត្រូវបានបញ្ជូនទៅផ្សារមូលបត្រ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នឹងមានតួនាទីនៅក្នុងដំណើរការនៃការជួញដូរនោះ ទាំងប្រតិបត្តិការទីផ្សារ ប្រតិបត្តិការជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រផងដែរ។ ចំណែកឯដំណើរការនៃការបោះផ្សាយលក់មូលបត្រវិញ ទោះបីជាមាននូវដំណើរការមានលក្ខណៈស្មុគស្មាញ និងលក្ខខណ្ឌតម្រូវយ៉ាងច្រើនដូចដែលបានសិក្សាខាងលើ ក៏ដំណើរការប្រព្រឹត្តិទៅនៃការបោះផ្សាយត្រូវបានប្រព្រឹត្តិទៅបានយ៉ាងល្អគួរឲ្យកត់សម្គាល់ផងដែរ ដោយសារតែមានការចូលរួមពីគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ រួមទាំងភ្នាក់ងារពាក់ព័ន្ធផ្សេងទៀត ចូលរួមសហប្រតិបត្តិការគ្នា ដែលជាកត្តាបង្កភាពងាយស្រួលឡើង នៅក្នុងការបោះផ្សាយលក់មូលបត្រ។

ទន្ទឹមនឹងនេះ វិស័យមូលបត្រកម្ពុជានាពេលបច្ចុប្បន្ន ទោះបីជាមិនទាន់មានការរីកចម្រើន និងអាចប្រកួតប្រជែងជាមួយនឹងបណ្តាប្រទេសដទៃក៏ពិតមែន ប៉ុន្តែបើយើងក្រឡេកមកមើលវិស័យមូលបត្រនេះនៅក្នុងប្រទេសកម្ពុជាយើងនាពេលប៉ុន្មានឆ្នាំកន្លងមកនេះវិញ កាន់តែមានការទទួលបាននូវការចាប់អារម្មណ៍ពីសំណាក់វិនិយោគិនទាំងក្នុងប្រទេស និងក្រៅប្រទេស រីឯការជួញដូរមូលបត្រកាន់តែមានសន្ទុះស្ទុះឡើងគួរឲ្យកត់សម្គាល់។ សមិទ្ធិផលទាំងអស់នេះហើយ ដែលបានមកពីការខិតខំ ប្រឹងប្រែងរបស់ រាជរដ្ឋាភិបាល និង គណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរ

គ្រប់គ្រងនូវវិស័យមូលបត្រកម្ពុជា ដែលបានចែងនូវច្បាប់ បទបញ្ញត្តិ អនុក្រឹត្យ និងប្រកាសផ្សេងៗ ដែលត្រូវឲ្យក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា វិនិយោគិន និងភាគីដែលពាក់ព័ន្ធទាំងអស់ ធ្វើការអនុវត្តតាមឲ្យស្របតាមច្បាប់ដែលបានចែង ដើម្បីបញ្ចៀសនូវការជួញដូរមិនស្មោះត្រង់ និងបញ្ហាប្រឈមផ្សេងៗទៀត។

សរុបសេចក្តីមក ដំណើរការនៅក្នុងវិស័យមូលបត្រ ក៏ដូចជាផ្សារមូលបត្រគឺពិតជាមានលក្ខណៈស្មុគស្មាញ និងស៊ាំញ៉ាំមិនថាប្រទេសកម្ពុជា ឬប្រទេសដទៃ តែវិស័យមូលបត្រកម្ពុជាយើងកាន់តែមានការអភិវឌ្ឍទៅមុខជាលំដាប់ និងមានការចាប់អារម្មណ៍ពីវិនិយោគិនគ្រប់ជាន់ថ្នាក់ ដែលជាកត្តាលីករដែលជម្រុញឲ្យ វិស័យហិរញ្ញវត្ថុ និងវិស័យសេដ្ឋកិច្ចកម្ពុជាកាន់មានសន្ទុះឡើង រហូតដល់មានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ជាងបណ្តាប្រទេសដទៃ ក្នុងតំបន់អាស៊ីអាគ្នេយ៍។

## ២. ការផ្តល់អនុសាសន៍

ជាចុងក្រោយ បន្ទាប់ពីបានសិក្សានូវប្រធានបទខាងលើ ខ្ញុំបាទមាននូវមតិយោបល់មួយចំនួនដើម្បីជាពុទ្ធិ នៅក្នុងការអភិវឌ្ឍនូវវិស័យមូលបត្រនៅកម្ពុជាឲ្យកាន់តែរីកចម្រើន និងមានប្រជាប្រិយភាពពីសំណាក់វិនិយោគិនគ្រប់ជាន់ថ្នាក់។ គំនិតយោបល់ដែលខ្ញុំបាទចង់លើកយកមកបង្ហាញនោះមានដូចតទៅៈ

- គណៈកម្មការមូលបត្រកម្ពុជា គួរតែបន្តធ្វើការផ្សព្វផ្សាយឲ្យទូលំទូលាយ ដល់សាធារណៈជនទូទៅ អំពីដំណើរការជួញដូរមូលបត្រ ផលប្រយោជន៍និងសមិទ្ធិផលដែលទទួលបានពីការវិនិយោគលើមូលបត្រ ដើម្បីជម្រុញទឹកចិត្តពួកគេឲ្យចូលរួមឲ្យកាន់តែច្រើន។
- លើកទឹកចិត្តឲ្យបណ្តាក្រុមហ៊ុននានា ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ ទាំងមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល ឲ្យពួកគេមានចូលរួមយ៉ាងសកម្មក្នុងការបោះផ្សាយលក់មូលបត្រ ដើម្បីឲ្យមានកំណើននៃការផ្គត់ផ្គង់កើនឡើង។
- គណៈកម្មការមូលបត្រកម្ពុជា គួរតែសហការជាមួយក្រសួងពាក់ព័ន្ធ បញ្ចូលការអប់រំអំពីវិស័យមូលបត្រមួយនេះ នៅតាមបណ្តាសាលារៀន សកលវិទ្យាល័យ ស្ថាប័នក្រុមហ៊ុននានា ទាំងរាជធានី ទាំងខេត្តដើម្បីឲ្យពួកគេកាន់តែយល់ច្បាស់ពីវិស័យមួយនេះ និង ការរីកសាយនៃចំណេះដឹងឲ្យកាន់តែទូលំទូលាយជាងមុន។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់

- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/០១០៧/០២៨, ២៣ តុលា ២០០៧, សន្ទានុក្រម
- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/០១០៧/០២៨, ២៣ តុលា ២០០៧, មាត្រា៧

## ប្រកាស

- ប្រកាសស្តីពីការកែប្រែលក់វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៩/១៨គ.ម.ក./ប្រ.ក., ១៩ ធ្នូ ២០១៨, ប្រការ ៨ ថ្មី
- ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ៧
- ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥គ.ម.ក/ប្រ.ក, ១០ កញ្ញា ២០១៥, ប្រការ២៩
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥គ.ម.ក/ប្រ.ក., ១០ កញ្ញា ២០១៥, ប្រការ៤
- ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥គ.ម.ក/ប្រ.ក., ១០ កញ្ញា ២០១៥, ប្រការ១០

## គោលការណ៍ណែនាំ

- គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង, លេខ០០១គ.ម.ក/គ.ណ.ក, ០៨ កញ្ញា ២០១១
- គោលការណ៍ណែនាំស្តីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ, លេខ០០២/១២គ.ម.ក/គ.ណ.ន, ០៩ កុម្ភៈ ២០១២
- គោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន, លេខ០០១គ.ម/គ.ណ.ន, ០៦ កុម្ភៈ ២០១២

## សៀវភៅ និងអត្ថបទសិក្សា

- សៀវ សុស៊ីខា, ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រ, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

- សៀវ សុស៊ីខា, ប្រភេទមូលបត្រ, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច)
- សៀវ សុស៊ីខា, Listing and Securities Trading on CSX, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យសាស្ត្រសេដ្ឋកិច្ច)
- សៀវ សុស៊ីខា, ប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ រក្សាទុកមូលបត្រកម្មសិទ្ធិ, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យសាស្ត្រសេដ្ឋកិច្ច)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៨), ការព្យាករណ៍លើកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាឆ្នាំ ២០១៨

**និក្ខេបបទ**

- ធូ រិទ្ធី, ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា, (និក្ខេបបទបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៥), ១៦-២០

**គេហទំព័រ**

- London Stock Exchange Group, https://www.lseg.com/ (ចូលទស្សនាថ្ងៃ១៥ មិថុនា ២០១៩)
- គណៈកម្មការមូលបត្រកម្ពុជា, រូបសញ្ញារបស់គ.ម.ក, http://www.secc.gov.kh/khmer/m17.php?pn=1 (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០១៩)
- គណៈកម្មការមូលបត្រកម្ពុជា, គោលដៅ និងគោលបំណង, http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី ១០ មិថុនា ២០១៩)
- គណៈកម្មការមូលបត្រកម្ពុជា, ចក្ខុវិស័យ និង បេសកកម្ម, http://www.secc.gov.kh/khmer/m11.php?pn=1 (ចូលទស្សនាថ្ងៃទី ១០ មិថុនា ២០១៩)
- គណៈកម្មការមូលបត្រកម្ពុជា, តួនាទី និង ភារកិច្ចរបស់នាយកដ្ឋាន , http://www.secc.gov.kh/khmer/m14.php?pn=1 (ចូលទស្សនាថ្ងៃទី ១០ មិថុនា ២០១៩)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ប្រវត្តិរបស់ផ.ម.ក, http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ឆ្នាំ ២០១៩)

- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ចក្ខុវិស័យ និងបេសកកម្ម, http://csx.com.kh/kh/about/mission.jsp?MNCD=1020 (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ឆ្នាំ ២០១៩)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, រចនាសម័ន្ធគ្រប់គ្រងរបស់ផ.ម.ក, http://csx.com.kh/kh/about/org.jsp?MNCD=10302 (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ឆ្នាំ ២០១៩)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, តួនាទីចម្បងរបស់ផ.ម.ក, http://csx.com.kh/kh/about/chairman.jsp?MNCD=1000 (ចូលទស្សនាថ្ងៃទី ១៦ មិថុនា ឆ្នាំ ២០១៩)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ឯកតាគម្លាតតម្លៃ, http://csx.com.kh/operation/stock/listPosts.do?MNCD=30202 (ចូលទស្សនាថ្ងៃទី០៦ កក្កដា ២០១៩)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ថ្លៃពិសេស, http://csx.com.kh/operation/stock/listPosts.do?MNCD=30202 (ចូលទស្សនាថ្ងៃទី០៦ កក្កដា ២០១៩)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ដំណើរការជួញដូរ, http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនាថ្ងៃទី ២៦ មិថុនា ឆ្នាំ ២០១៩)
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ការផាត់ទាត់ និងទូទាត់សម្រាប់ប្រតិបត្តិការជួញដូរ, http://csx.com.kh/operation/clearing/listPosts.do?MNCD=3030 (ចូលទស្សនាថ្ងៃទី ០១ កក្កដា ២០១៩)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១៖ ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:..........................គ.ម.ក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ[១]

**ផ្នែកទី ១: ព័ត៌មានទូទៅ**

**១- ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ**

ឈ្មោះជាអក្សរខ្មែរៈ ______________________________

ឈ្មោះជាអក្សរឡាតាំងៈ ______________________________

ឈ្មោះជាអក្សរកូដៈ ______________________________

ប្រភេទធុរកិច្ចជាភាសាខ្មែរៈ ______________________________

ប្រភេទធុរកិច្ចជាភាសាអង់គ្លេសៈ ______________________________

អាសយដ្ឋានទីស្នាក់ការចុះបញ្ជីៈ ______________________________

លេខទូរស័ព្ទៈ ______________ លេខទូរសារៈ ______________

គេហទំព័រៈ ______________ អ៊ីម៉ែលៈ ______________

កាលបរិច្ឆេទចាប់ផ្តើមដំណើរការអាជីវកម្មៈ ________/________/________

លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មៈ ______________________________

---

១ពាក្យស្នើសុំនេះ ត្រូវដាក់ជូន គ.ម.ក. ដោយភ្ជាប់មកជាមួយនូវឯកសារផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងទៀត។

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម: ____________/____________/ ____________________

លេខអាជ្ញាបណ្ណអាជីវកម្ម: ____________________ចេញដោយ:____________________

សុពលភាពអាជ្ញាបណ្ណអាជីវកម្ម ពីថ្ងៃទី:______/______/______ ដល់ថ្ងៃទី: ______/______/________

លេខអត្តសញ្ញាណកម្មសារពើពន្ធ: ________________________________________

## ២- ព័ត៌មានអំពីបុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន

ឈ្មោះជាអក្សរខ្មែរ: ________________________________________

ឈ្មោះជាអក្សរឡាតាំង: ________________________________________

លេខអត្តសញ្ញាណប័ណ្ណ /លេខលិខិតឆ្លងដែន: ________________________________

មុខតំណែង:________________________________________

អាសយដ្ឋាន:________________________________________

លេខទូរស័ព្ទ: ____________________លេខទូរសារ: ____________________

លេខទូរស័ព្ទដៃ: ____________________ អ៊ីម៉ែល: ____________________

## ផ្នែកទី ២: ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិ

| | |
|---|---|
| ឈ្មោះមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់ | |
| ប្រភេទមូលបត្រកម្មសិទ្ធិ | |
| ថ្នាក់មូលបត្រកម្មសិទ្ធិ | |
| ថ្លៃលក់ | |
| ចំនួនមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់ | |
| ចំនួនទឹកប្រាក់សរុបពីការបោះផ្សាយ | |

## ផ្នែកទី ៣: មូលធនភាគហ៊ុនិក និងចំណេញភាគ

| ពិពណ៌នា | ទឹកប្រាក់ជារៀល | ទឹកប្រាក់ជាដុល្លារ |
|---|---|---|
| មូលធនភាគហ៊ុនិកសរុបនៅកាលបរិច្ឆេទដាក់ពាក្យស្នើសុំ | | |

| | | |
|---|---|---|
| ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ | | |
| ចំណេញសុទ្ធក្នុងរយៈពេលបីឆ្នាំចុងក្រោយ | | |

*សូមផ្តល់នូវអត្រាប្តូរប្រាក់ដូចគ្នានឹងអត្រាដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។*

## ផ្នែកទី ៤: រចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន និងភាគហ៊ុនិក

១- សូមភ្ជាប់មកជាមួយនូវរចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនដោយបញ្ជាក់ដូចខាងក្រោម:

រចនាសម្ព័ន្ធជាក្រុម

- ភាគរយនៃភាគហ៊ុនរបស់ក្រុមនីមួយៗ
- សកម្មភាពធុរកិច្ចគោលរបស់ក្រុមនីមួយៗ

២- បញ្ជីភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ:

| ល.រ. | ឈ្មោះភាគហ៊ុនិក | ចំនួនភាគហ៊ុន | ភាគរយ | ថ្លៃមូលបត្រ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

*សូមភ្ជាប់នូវបញ្ជីតាមទម្រង់នេះ ករណីភាគហ៊ុនិកកាន់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយ មានចំនួនលើសពីនេះ។*

## ផ្នែកទី ៥: ព័ត៌មានអំពីអភិបាល

បំពេញព័ត៌មានពាក់ព័ន្ធនឹងអភិបាលដូចខាងក្រោម:

| ល.រ. | ឈ្មោះអភិបាល | ប្រភេទអភិបាល | លេខអត្តសញ្ញាណប័ណ្ណ / លេខលិខិតឆ្លងដែន | សេចក្តីលម្អិតពីលិខិតឆ្លងដែន | | កាលបរិច្ឆេទតែងតាំង |
|---|---|---|---|---|---|---|
| | | | | កាលបរិច្ឆេទអស់សុពលភាព |ចេញដោយប្រទេស | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |

*សូមភ្ជាប់នូវព័ត៌មានតាមទម្រង់នេះ ករណីអភិបាលមានចំនួនលើសពីនេះ។*

## ផ្នែកទី ៦: ព័ត៌មានអំពីបុគ្គលិកជាន់ខ្ពស់

បំពេញព័ត៌មានពាក់ព័ន្ធនឹងបុគ្គលិកជាន់ខ្ពស់ដូចខាងក្រោម:

| ល.រ. | ឈ្មោះបុគ្គលិកជាន់ខ្ពស់ | មុខតំណែង | លេខអត្តសញ្ញាណប័ណ្ណ /លេខលិខិតឆ្លងដែន | សេចក្តីលម្អិតពីលិខិតឆ្លងដែន | | កាលបរិច្ឆេទតែងតាំង |
|---|---|---|---|---|---|---|
| | | | | កាលបរិច្ឆេទអស់សុពលភាព | ចេញដោយប្រទេស | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

*សូមភ្ជាប់នូវព័ត៌មានតាមទម្រង់នេះ ករណីបុគ្គលិកជាន់ខ្ពស់មានចំនួនលើសពីនេះ។*

## ផ្នែកទី ៧: ព័ត៌មានអំពីក្រុមហ៊ុនហុលឌីង ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ

១- តើក្រុមហ៊ុនបោះផ្សាយ មានក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធដែរឬទេ?

□ មាន □ គ្មាន

ប្រសិនមាន សូមផ្តល់នូវព័ត៌មានដូចខាងក្រោម:

| ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | លេខអាជ្ញាបណ្ណ ឬ លេខចុះបញ្ជី | កាលបរិច្ឆេទក្លាយជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

*សូមភ្ជាប់នូវព័ត៌មានដូចទម្រង់ខាងលើ ករណីក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ មានចំនួនលើសពីនេះ។*

២- តើក្រុមហ៊ុនបោះផ្សាយ ជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធដទៃដែរឬទេ?

□ មែន □ មិនមែន

ប្រសិនបើមែន សូមផ្តល់នូវព័ត៌មានដូចខាងក្រោម៖

| ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយ % | កាលបរិច្ឆេទក្លាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

**ផ្នែកទី ៨៖ ព័ត៌មានអំពីការបោះផ្សាយមូលបត្រជាសាធារណៈពីមុន**

តើក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែរឬទេ?

□ ធ្លាប់ សូមបំពេញនូវតារាងខាងក្រោម

□ មិនធ្លាប់

ឈ្មោះមូលបត្រកម្មសិទ្ធិ ____________________

ថ្ងៃលក់: ____________________

ចំនួនមូលបត្រកម្មសិទ្ធិ: ____________________

ទឹកប្រាក់សរុប: ____________________

កាលបរិច្ឆេទចុះបញ្ជីពីមុន: ____________________

ទីកន្លែងជួញដូរ: ____________________

## ផ្នែកទី ៩: ព័ត៌មានអំពីការបដិសេធឯកសារផ្តល់ព័ត៌មាន

តើក្រុមហ៊ុនធ្លាប់ត្រូវបានបដិសេធឯកសារផ្តល់ព័ត៌មានដែរឬទេ?

□ ធ្លាប់ សូមបំពេញនូវតារាងខាងក្រោម

□ មិនធ្លាប់

| ឈ្មោះអាជ្ញាធរ | ប្រភេទនៃការបដិសេធ | ហេតុផលនៃការបដិសេធ | លេខយោង |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ផ្នែកទី ១០: ព័ត៌មានអំពីភាគីពាក់ព័ន្ធ

**១- ក្រុមហ៊ុនគណនេយ្យជំនាញ**: ____________________

កាលបរិច្ឆេទតែងតាំង ________/________/________

សុពលភាពនៃការទទួលស្គាល់ដោយ **គ.ម.ក.** ពីថ្ងៃទី:____/____/____ ដល់ថ្ងៃទី:____/____/____

**២- ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ**: ____________________

កាលបរិច្ឆេទតែងតាំង ________/________/________

សុពលភាពនៃអាជ្ញាបណ្ណ ពីថ្ងៃទី:______/______/______ ដល់ថ្ងៃទី:______/______/______

៣-  **មេធាវី**: ____________________________________________

កាលបរិច្ឆេទតែងតាំង ________________/________________/____________________

សុពលភាពនៃការទទួលស្គាល់ដោយ **គ.ម.ក.**ពីថ្ងៃទី:_____/_____/_____ ដល់ថ្ងៃទី:____/_____/_____

៤-  **ក្រុមហ៊ុនផ្ដល់សេវាវាយតម្លៃ** ____________________________________

កាលបរិច្ឆេទតែងតាំង ________________/________________/____________________

សុពលភាពនៃការទទួលស្គាល់ដោយ **គ.ម.ក.**ពីថ្ងៃទី:_____/_____/_____ ដល់ថ្ងៃទី:____/_____/_____

## ផ្នែកទី ១១: ឯកសារភ្ជាប់

បុគ្គលដែលស្នើសុំធ្វើសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវភ្ជាប់មកជាមួយនឹងពាក្យស្នើសុំនូវឯកសារដូចខាងក្រោម:

១-  ឯកសារផ្ដល់ព័ត៌មាន ដែលរៀបចំឡើងដោយអនុលោមតាមប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

២-  វិញ្ញាបនបត្របញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិពីទីផ្សារមូលបត្រប្រតិស្រុត។

៣-  លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

៤-  វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

៥-  សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៦-  លិខិតប្រគល់សិទ្ធិដោយមានបញ្ជាក់ពីតួនាទី និងភារកិច្ចជាអភិបាល ឬនាយកប្រតិបត្តិ ក្នុងការបម្រើការងារនៅក្នុងក្រុមហ៊ុនបោះផ្សាយ ដោយមានការចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៧-  កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗ (ប្រសិនបើមាន)។

៨-  លិខិតបញ្ជាក់ពីធនាគារពាណិជ្ជស្ដីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៩-  កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១០- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្ម
ជានាទិញមូលបត្រ។

១១- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១២- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១៣- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។

១៤- កិច្ចព្រមព្រៀងវិនិយោគចម្រុះសំខាន់ៗ ប្រសិនបើមាន។

១៥- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជ ឬលិខិតបញ្ជាក់ពីសវនករនូវចំនួនទឹកប្រាក់តម្កល់សម្រាប់ធ្វើជាមូលធន។

១៦- របាយការណ៍អនុសាសន៍ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់សវនករឯករាជ្យដែលមានគុណវុឌ្ឍិទទួលស្គាល់
ដោយ **គ.ម.ក.**។

១៧- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយ
ក្រុមហ៊ុនគណនេយ្យជំនាញដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

១៨- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់
ដោយ **គ.ម.ក.**។

១៩- បញ្ជីរាយនាមអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនដែលមានលក្ខណៈបច្ចុប្បន្នភាពដោយភ្ជាប់
មកជាមួយប្រវត្តិរូបសង្ខេបរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដោយបញ្ជាក់ពីរយៈពេលបំពេញការងារ
និងបទពិសោធន៍ការងារ។

២០- លិខិតផ្ទេរសិទ្ធិជូនបុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន។

២១- អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនថតចម្លង របស់បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន។

២២- ប្រវត្តិរូបសង្ខេបរបស់បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន ដោយបញ្ជាក់ពីរយៈពេល
បំពេញការងារ និងបទពិសោធន៍ការងារ។

២៣- បញ្ជីរាយនាម និងអត្តសញ្ញាណរបស់ភាគហ៊ុនិកដែលមានលក្ខណៈបច្ចុប្បន្នភាព។

២៤- ឯកសារភ្ជាប់ផ្សេងៗទៀត តាមការស្នើសុំរបស់អត្តនាយកនៃ **គ.ម.ក.**។

**ផ្នែកទី ១២: សេចក្តីប្រកាស និងកិច្ចសន្យារបស់បុគ្គលដាក់ពាក្យស្នើសុំ**

- ក្រុមហ៊ុនសូមអះអាងថា រាល់ព័ត៌មានដែលបានផ្តល់នៅក្នុងពាក្យស្នើសុំ (រួមមានរាល់ព័ត៌មានពាក់ព័ន្ធ និង ឯកសារភ្ជាប់) មានលក្ខណៈពេញលេញ ពិតប្រាកដ និងត្រឹមត្រូវ។
- ក្រុមហ៊ុនសូមអះអាងថា ក្រុមប្រឹក្សាភិបាលបានផ្តល់សេចក្តីសម្រេចយល់ព្រមលើពាក្យស្នើសុំនេះ។

- ក្រុមហ៊ុនដឹងថា ការផ្តល់ព័ត៌មានខុស ឬព័ត៌មានដែលនាំឱ្យយល់ខុសដែលភ្ជាប់មកជាមួយនឹងពាក្យស្នើសុំសម្រាប់ចុះបញ្ជីគឺជាបទល្មើសដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។
- ក្រុមហ៊ុនដឹងថា **គ.ម.ក.** មានសមត្ថកិច្ចគ្រប់ពេលវេលាក្នុងការចាត់វិធានការណ៍ចំពោះការក្លែងបន្លំព័ត៌មាន នៅក្នុងឯកសារផ្តល់ព័ត៌មាន ឯកសារភ្ជាប់ និងពាក្យស្នើសុំ។
- ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមមក **គ.ម.ក.** ប្រសិនបើមានការផ្លាស់ប្តូរពាក់ព័ន្ធនឹងឯកសារផ្តល់ព័ត៌មាន ឯកសារភ្ជាប់ និងពាក្យស្នើសុំ មុនពេលពាក្យស្នើសុំទទួលបានការយល់ព្រម។

## ផ្នែកទី ១៣: ការបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត

ពាក្យស្នើសុំការទទួលស្គាល់ត្រូវភ្ជាប់មកជាមួយនូវវិក័យបត្រ ជាសាច់ប្រាក់ចំនួន ១២.០០០.០០០(ដប់ពីរលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬជាសាច់ប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែមសម្រាប់ពាក្យស្នើសុំ និងសោហ៊ុយសិក្សានិងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ដោយយោងតាមប្រការ ៤៧ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

រាជធានីភ្នំពេញ ថ្ងៃទី : ____/______/______

ហត្ថលេខា និងត្រា

ឈ្មោះ:.................

(បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន)

# ឧបសម្ព័ន្ធទី៣៖ ពាក្យស្នើសុំ
# ធ្វើប៉ុកបៀលឌីង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:.................................គ.ម.ក

**ឧបសម្ព័ន្ធ ០១**

**(លេខប៊ុករបៀលឌីង :..............................)**

## ពាក្យស្នើសុំចូលរួមធ្វើប៊ុករបៀលឌីង
## នៃក្រុមហ៊ុន ..............................................

**ព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនធានាទិញមូលបត្រ និងមូលបត្រកម្មសិទ្ធិ**

យើងខ្ញុំជាក្រុមហ៊ុនធានាទិញមូលបត្រ :..................................................................................................................................................................................................។

ក្រុមហ៊ុនបោះផ្សាយ :.............................................. បានតែងតាំងក្រុមហ៊ុនមូលបត្រយើងខ្ញុំ.................................................. (ឈ្មោះក្រុមហ៊ុនមូលបត្រ) ធ្វើជាក្រុមហ៊ុនធានាទិញមូលបត្រ កាលពីថ្ងៃទី ........ ខែ ........ ឆ្នាំ ........... ។

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រយើងខ្ញុំ បានដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្តល់ព័ត៌មានជូន គ.ម.ក. ហើយទទួលបានការអនុញ្ញាតជាគោលការណ៍ពី គ.ម.ក. នៅថ្ងៃទី ...... ខែ ........ ឆ្នាំ ........។ ក្រុមហ៊ុនបោះផ្សាយបានកំណត់ថ្លៃលក់ចន្លោះពី.................... ដល់.................................. ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។

SPECIMEN

យើងខ្ញុំសូមបញ្ជាក់ថា វិនិយោគិនដែលចូលរួមក្នុងការស្ទាបស្ទង់ថ្លៃលក់មូលបត្រ (Book-Building) ត្រូវជ្រើសរើសថ្លៃណាមួយក្នុងចំណោមចន្លោះថ្លៃដែលក្រុមហ៊ុនបានកំណត់។ វិនិយោគិនដែលចូលរួមក្នុងការស្ទាបស្ទង់ថ្លៃលក់មូលបត្រ ត្រូវតម្កល់ប្រាក់ស្មើនឹង ១០ (ដប់) ភាគរយ នៃថ្លៃមូលបត្រកម្មសិទ្ធិសរុបដែលមានបំណងធ្វើបរិវិសកម្ម (សូមអានគោលការណ៍ណែនាំរបស់ គ.ម.ក. ស្តីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដែលអាចទាញយកតាម http://www.secc.gov.kh/khmer/m24.php?pn=3 )។

វិនិយោគិនដែលមានបំណងចូលរួមក្នុងការស្ទាបស្ទង់ថ្លៃ សូមបំពេញនូវព័ត៌មាន ដូចខាងក្រោម÷

**ព័ត៌មានពាក់ព័ន្ធនឹងវិនិយោគិនចូលរួមធ្វើប៊ុករបៀលឌីង**

**ក. វិនិយោគិនជារូបវន្តបុគ្គល:**

☐រូបវន្តបុគ្គលសញ្ជាតិខ្មែរ ☐រូបវន្តបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :.............................................. ជាអក្សរឡាតាំង :..................................................

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

ថ្ងៃខែឆ្នាំកំណើត :........................................ ភេទ : □ ប្រុស □ ស្រី
ទូរស័ព្ទលេខ :........................................ អ៊ីម៉ែល :........................................។

លេខអត្តសញ្ញាណវិនិយោគិន[១] :..............................

ខ. វិនិយោគិនជានីតិបុគ្គល :

□នីតិបុគ្គលសញ្ជាតិខ្មែរ □នីតិបុគ្គលមិនមែនសញ្ជាតិខ្មែរ
ឈ្មោះជាអក្សរខ្មែរ :........................................ ជាអក្សរឡាតាំង :........................................
លេខអត្តសញ្ញាណកម្មសារពើពន្ធ (ប្រសិនមាន) ..............................
ទូរស័ព្ទលេខ :........................................ អ៊ីម៉ែល :........................................។

លេខអត្តសញ្ញាណវិនិយោគិន[២] :..............................

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចចូលរួមធ្វើប៊ុកបៀលដើម្បីតាមរយៈតំណាងរបស់ខ្លួនបានដោយមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ។

SPECIMEN

## ព័ត៌មានពាក់ព័ន្ធនឹងការស្នើរសុំទិញមូលបត្រកម្មសិទ្ធិ

១. ថ្លៃមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម :........................................។
(វិនិយោគិន ត្រូវជ្រើសរើសយកថ្លៃមួយក្នុងចន្លោះថ្លៃ ដូចបានកំណត់ខាងលើ)
២. ចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម :........................................
៣. ចំនួនទឹកប្រាក់សរុប (ថ្លៃមូលបត្រកម្មសិទ្ធិ x ចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម) :........................................។

ធ្វើនៅ.................. ថ្ងៃទី....... ខែ....... ឆ្នាំ..........

ហត្ថលេខា-ត្រា និងឈ្មោះ

ហត្ថលេខា ឬ/និង ត្រា[៣]

តំណាងក្រុមហ៊ុនមូលបត្រ

..............................
ឈ្មោះវិនិយោគិន

---

[១] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[២] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៣] ករណីវិនិយោគិនជានីតិបុគ្គល

## គំរូវិក្កយបត្រ
## ប៉ុករបៀលនឹងមូលបត្រ

**វិក្កយបត្រប្រាក់តម្កល់នៃក្រុមហ៊ុនមូលបត្រ....................**

លេខប៉ុកបៀលនឹង:..........................

SPECIMEN

កាលបរិច្ឆេទ : __/__/____

អ្នកធ្វើប៉ុកបៀលនឹងឈ្មោះ :..........................................................

លេខអត្តសញ្ញាណវិនិយោគិន :..........................................................

ចំនួនទឹកប្រាក់សរុបបានទទួល :..........................................................

មធ្យោបាយទូទាត់ : □ ប្រាក់សុទ្ធ

□ បណ្ណឥណទាន

□ មូលប្បទានបត្រលេខ : .............................ធនាគារ :.........................................។

ហត្ថលេខា- ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ

# ឧបសម្ព័ន្ធទី៤៖ ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបានចូលរួមធ្វើប៊ុកបៀលឌីង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:..............................គ.ម.ក

ឧបសម្ព័ន្ធ ០២

**លេខបរិវិសកម្ម :** ..........................

## ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ
## សម្រាប់វិនិយោគិនដែលបានចូលរួមធ្វើប៊ុកបៀលឌីង
## ក្រុមហ៊ុនបោះផ្សាយ..........................................

មូលបត្រកម្មសិទ្ធិសរុបដែលត្រូវធ្វើសំណើលក់ជាសាធារណៈមានចំនួន .......................... ឯកតាមូលបត្រកម្មសិទ្ធិ ដែលតម្លៃចារិកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង .......................... ហើយថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ..................។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់បុគ្គលិកមានចំនួន .................. ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនយុទ្ធសាស្ត្រ ...................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង .................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ................................ ឯកតាមូលបត្រកម្មសិទ្ធិ។

ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ត្រូវមានចំនួនអប្បបរមាចាប់ពី .................................ឯកតាមូលបត្រកម្មសិទ្ធិឡើងទៅ។ ករណីការធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមាចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មគឺស្មើនឹងចំនួនគុណនៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មអប្បបរមា។

### ព័ត៌មានសម្រាប់វិនិយោគិនដែលចូលរួមក្នុងបរិវិសកម្ម

ឈ្មោះជាអក្សរខ្មែរ :........................................ ជាអក្សរឡាតាំង :................................................

លេខប៊ុកបៀលឌីង :........................................ លេខអត្តសញ្ញាណវិនិយោគិន :..............................

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ :.................. លេខគណនីជួញដូរ[៣] :....................

[៣] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

SPECIMEN

**ក. វិនិយោគិនដែលទទួលបានជោគជ័យ**

| | |
|---|---|
| ចំនួនមូលបត្រកម្មសិទ្ធិដែលបានបម្រុងឱ្យក្នុងប៊ុកបៀលឌីង | ចំនួនទឹកប្រាក់តម្កល់ជាក់ស្តែងសរុបសម្រាប់ប៊ុកបៀលឌីង (១) |
| ........................................ | ........................................ |
| ចំនួនមូលបត្រកម្មសិទ្ធិដែលស្នើសុំធ្វើបរិវិសកម្ម | ចំនួនទឹកប្រាក់សរុបដែលត្រូវទូទាត់សម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) |
| ........................................ | ........................................ |
| ចំនួនទឹកប្រាក់បង់បន្ថែមសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) - (១) | |
| ........................................ | |

SPECIMEN

**ខ. វិនិយោគិនដែលមិនទទួលបានជោគជ័យ**

| ចំនួនទឹកប្រាក់តម្កល់ជាក់ស្តែងសរុបសម្រាប់ប៊ុកបៀលឌីង (១) | ចំនួនមូលបត្រកម្មសិទ្ធិដែលស្នើសុំធ្វើបរិវិសកម្ម | ចំនួនទឹកប្រាក់សរុបដែលត្រូវទូទាត់សម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) |
|---|---|---|
| ........................................ | ........................................ | ........................................ |
| ចំនួនទឹកប្រាក់បង់បន្ថែមសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) - (១) | | |
| ........................................ | | |

## សេចក្តីថ្លែងសម្រាប់វិនិយោគិនដែលចូលរួមក្នុងបរិវិសកម្ម

នៅក្នុងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនេះ ខ្ញុំបានទទួលឯកសារផ្តល់ព័ត៌មានក្នុងទម្រង់ជា÷

☐ ច្បាប់ចម្លង ☐ ឧបករណ៍ផ្ទុក (Storage device) ☐ អ៊ីម៉ែលផ្ទុក (E-mail storage)

☐ តាមរយៈគេហទំព័រ :........................................ ឬ ☐ ផ្សេងពីនេះ : ........................................

ការធ្វើបរិវិសកម្ម និងការទូទាត់ត្រូវធ្វើឡើងដោយអ្នកធ្វើបរិវិសកម្មត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំយល់ព្រម និងទទួលស្គាល់ថា ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិបដិសេធក្នុងករណីការស្នើសុំធ្វើបរិវិសកម្មណាមួយដែលមិនគោរពតាមលក្ខខណ្ឌ។ ខ្ញុំយល់ព្រមទិញ

មូលបត្រកម្មសិទ្ធិក្នុងចំនួនដូចបានកំណត់ខាងលើ ឬចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបែងចែកមកឱ្យខ្ញុំ។ ខ្ញុំសូមសន្យាថាមិនលុបចោលការធ្វើបរិវិសកម្មរបស់ខ្ញុំទេ និងយល់ព្រមទទួលប្រាក់សងត្រឡប់មកវិញ ករណីការធ្វើបរិវិសកម្មត្រូវបានបដិសេធ ឬការធ្វើបរិវិសកម្មរបស់ខ្ញុំមិនសម្រេចបានតាមការស្នើសុំទាំងអស់របស់ខ្ញុំ។ ខ្ញុំយល់ស្របតាមលក្ខខណ្ឌនៃសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងដូចមានចែងនៅក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំទទួលស្គាល់ផងដែរថា ការវិនិយោគលើមូលបត្រកម្មសិទ្ធិមានហានិភ័យពាក់ព័ន្ធ។

ខ្ញុំបានអានឯកសារផ្តល់ព័ត៌មានដោយម៉ត់ចត់មុនពេលធ្វើបរិវិសកម្ម និងមិនមានការបញ្ចុះបញ្ចូលដោយភាគីណាមួយទេ។

**កាលបរិច្ឆេទស្នើសុំធ្វើបរិវិសកម្ម :** __/__/____

SPECIMEN

| | |
|---|---|
| ហត្ថលេខា ត្រា និងឈ្មោះ | ហត្ថលេខា ឬ/និងត្រា[២] |
| ................................ | ................................ |
| តំណាងក្រុមហ៊ុនមូលបត្រ | ឈ្មោះអ្នកធ្វើបរិវិសកម្ម |

[២] ករណីអ្នកធ្វើបរិវិសកម្មជានីតិបុគ្គល

## គំរូវិក្កយបត្រ
## បរិវិសកម្មមូលបត្រកម្មសិទ្ធិ

**វិក្កយបត្រការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ នៃក្រុមហ៊ុនមូលបត្រ..................................**

SPECIMEN

លេខបរិវិសកម្ម :..............................

កាលបរិច្ឆេទ : __/__/____

អ្នកធ្វើបរិវិសកម្មឈ្មោះ :..................................................

លេខអត្តសញ្ញាណវិនិយោគិន :..................................................

ចំនួនទឹកប្រាក់សរុបបានទទួល :..................................................

មធ្យោបាយទូទាត់ : □ ប្រាក់សុទ្ធ

□ បណ្ណឥណទាន

□ មូលប្បទានបត្រលេខ :.......................... ធនាគារ :..........................................។

ហត្ថលេខា ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ

# ឧបសម្ព័ន្ធទី៥៖ ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលមិនបានចូលរួមធ្វើប៊ុកបៀលឌីង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:..............................គ.ម.ក

ឧបសម្ព័ន្ធទី ០៣

**លេខបរិវិសកម្ម :**..............................

## ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ សម្រាប់វិនិយោគិនដែលមិនបានចូលរួមធ្វើប៊ុកបៀលឌីង

## ក្រុមហ៊ុនបោះផ្សាយ..............................

មូលបត្រកម្មសិទ្ធិសរុបដែលត្រូវធ្វើសំណើលក់ជាសាធារណៈមានចំនួន .................... ឯកតាមូលបត្រកម្មសិទ្ធិ ដែលតម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង .................... ហើយថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ....................។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់បុគ្គលិកមានចំនួន ............... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនយុទ្ធសាស្ត្រ .................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង .................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង .............................. ឯកតាមូលបត្រកម្មសិទ្ធិ។

SPECIMEN

ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ត្រូវមានចំនួនអប្បបរមាចាប់ពី .............................. ឯកតាមូលបត្រកម្មសិទ្ធិឡើងទៅ។ ករណីការធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមាចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មគឺស្មើនឹងចំនួនដងនៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មអប្បបរមា។

**ព័ត៌មានសម្រាប់វិនិយោគិនដែលចូលរួមក្នុងការធ្វើបរិវិសកម្ម**

**ក. វិនិយោគិនជារូបវន្តបុគ្គលៈ**

☐រូបវន្តបុគ្គលសញ្ជាតិខ្មែរ ☐រូបវន្តបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :.............................. ជាអក្សរឡាតាំង :..............................

ថ្ងៃខែឆ្នាំកំណើត :.............................. ភេទ : ☐ ប្រុស ☐ ស្រី

ទូរស័ព្ទលេខ :.............................. អ៊ីម៉ែល :..............................។

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ :.................... លេខគណនីជួញដូរ[៩] :....................

---

[៩] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

លេខអត្តសញ្ញាណវិនិយោគិន[៦] : ..................................

ខ. វិនិយោគិនជានីតិបុគ្គលៈ

☐នីតិបុគ្គលសញ្ជាតិខ្មែរ ☐នីតិបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ : .................................... ជាអក្សរឡាតាំង : ....................................

លេខអត្តសញ្ញាណកម្មសារពើពន្ធ (ប្រសិនមាន) ..............................

ទូរស័ព្ទលេខ : .................................... អ៊ីម៉ែល : ....................................

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ : ................ លេខគណនីជួញដូរ[៧] : ..........

លេខអត្តសញ្ញាណវិនិយោគិន[៨]: ..................................

SPECIMEN

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចចូលរួមធ្វើបរិវិសកម្មតាមរយៈតំណាងរបស់ខ្លួនបានដោយមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ។

## សំណើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

| ចំនួនមូលបត្រកម្មសិទ្ធិសរុបដែលស្នើសុំធ្វើបរិវិសកម្ម | ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ចំនួនទឹកប្រាក់សរុបសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម |
|---|---|---|
| .................... | .................... | .................... |

## សេចក្តីថ្លែងសម្រាប់វិនិយោគិនដែលបានចូលរួមធ្វើបរិសកម្ម

នៅក្នុងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនេះ ខ្ញុំបានទទួលឯកសារផ្តល់ព័ត៌មានក្នុងទម្រង់ជា÷

☐ ច្បាប់ចម្លង ☐ ឧបករណ៍ផ្ទុក (Storage device) ☐ អ៊ីម៉ែលផ្ទុក (E-mail storage)

☐ តាមរយៈគេហទំព័រ : ............................ ឬ☐ ផ្សេងពីនេះ : ............................

ការធ្វើបរិវិសកម្ម និងការទូទាត់ត្រូវធ្វើឡើងដោយអ្នកធ្វើបរិវិសកម្មត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំយល់ព្រម និងទទួលស្គាល់ថា ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិ

---

[៦] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៧] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៨] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

បដិសេធក្នុងករណីការស្នើសុំធ្វើបរិវិសកម្មណាមួយដែលមិនគោរពតាមលក្ខខណ្ឌ។ ខ្ញុំយល់ព្រមទិញមូលបត្រកម្មសិទ្ធិក្នុងចំនួនដូចបានកំណត់ខាងលើ ឬចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបែងចែកមកឱ្យខ្ញុំ។ ខ្ញុំសូមសន្យាថាមិនលុបចោលការធ្វើបរិវិសកម្មរបស់ខ្ញុំទេ និងយល់ព្រមទទួលប្រាក់សងត្រឡប់មកវិញ ករណីការធ្វើបរិវិសកម្មត្រូវបានបដិសេធ ឬការធ្វើបរិវិសកម្មរបស់ខ្ញុំមិនសម្រេចបានតាមការស្នើសុំទាំងអស់របស់ខ្ញុំ។ ខ្ញុំយល់ស្របតាមលក្ខខណ្ឌនៃសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងដូចមានចែងនៅក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំទទួលស្គាល់ផងដែរថា ការវិនិយោគលើមូលបត្រកម្មសិទ្ធិមានហានិភ័យពាក់ព័ន្ធ។

ខ្ញុំបានអានឯកសារផ្តល់ព័ត៌មានដោយម៉ត់ចត់មុនពេលធ្វើបរិវិសកម្ម និងមិនមានការបញ្ចុះបញ្ចូលដោយភាគីណាមួយទេ។

កាលបរិច្ឆេទស្នើសុំធ្វើបរិវិសកម្ម : __/__/____

ហត្ថលេខា ត្រា និងឈ្មោះ

SPECIMEN

ហត្ថលេខា ឬ/និងត្រា[៥]

..............................

តំណាងក្រុមហ៊ុនមូលបត្រ

..............................

ឈ្មោះអ្នកធ្វើបរិវិសកម្ម

[៥] ករណីអ្នកធ្វើបរិវិសកម្មជានីតិបុគ្គល

## គំរូវិក្កយបត្រ
## បរិវិសកម្មមូលបត្រកម្មសិទ្ធិ

**វិក្កយបត្រការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនៃក្រុមហ៊ុន..................................................**

SPECIMEN

លេខបរិវិសកម្ម :..............................

កាលបរិច្ឆេទ : __/__/____

អ្នកធ្វើបរិវិសកម្មឈ្មោះ :..................................................................

លេខអត្តសញ្ញាណវិនិយោគិន :....................................................

ចំនួនទឹកប្រាក់សរុបបានទទួល :..................................................

មធ្យោបាយទូទាត់ : □ ប្រាក់សុទ្ធ

□ បណ្ណឥណទាន

□ មូលប្បទានបត្រលេខ : ............................ ធនាគារ :...........................................។

ហត្ថលេខា ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ

# ឧបសម្ព័ន្ធទី៦៖ ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០០៦/១៥ គ.ម.ក/ប្រ.ក.

# ប្រកាស
## ស្ដីពី
## ការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការផ្ដល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្ដីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

- បានឃើញប្រកាសលេខ ០០៤/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
- បានឃើញប្រកាសលេខ ០០១/១២ សួន១ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំការពិនិត្យ វិសោធនកម្ម និងអនុម័ត លើវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥។

## ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសនេះ ត្រូវជំនួសប្រកាសលេខ ០០៤/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ និងប្រកាសលេខ ០០១/១២ សួន១ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ..00៦/១៥...
ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

# វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

គោលបំណងនៃវិធាននេះ គឺដើម្បីកំណត់អំពីគោលការណ៍នានាដែលចាំបាច់សម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា ផ.ម.ក.) អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងវិធាននេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន÷

-បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ សំដៅដល់បុគ្គលដែលមានបំណងធ្វើសំណើចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ដែលមិនធ្លាប់បានចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

-បុគ្គលចុះបញ្ជីលក់មូលបត្រសំដៅដល់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ហើយបានចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ សំដៅដល់ភាគហ៊ុនិក និងបុគ្គលពាក់ព័ន្ធពិសេសនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេរបស់បុគ្គលស្នើសុំចុះបញ្ជីនេះ។ ក្នុងករណីនេះ ភាគហ៊ុនដែលកាន់កាប់ក្នុងគោលបំណងវិនិយោគជាកញ្ចប់ដោយវិនិយោគិនស្ថាប័ន ត្រូវបានដកចេញពីការគណនាចំនួនភាគហ៊ុនដែលកាន់កាប់ដោយភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ។

-**ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់** សំដៅដល់ភាគហ៊ុនិក ឬក្រុមបុគ្គល ដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតចាប់ពី ៣០ (សាមសិប) ភាគរយ ឡើងទៅ នៅក្នុងបុគ្គលចុះបញ្ជីលក់មូលបត្រ ហើយដែលសិទ្ធិនោះអាចកើតឡើងដោយផ្ទាល់តាមរយៈការកាន់កាប់ភាគហ៊ុន ឬដោយប្រយោល។

-**ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ** សំដៅដល់ភាគហ៊ុនិក ឬក្រុមបុគ្គល ដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ ឡើងទៅនៅក្នុងបុគ្គលចុះបញ្ជីលក់មូលបត្រ ហើយដែលសិទ្ធិនោះអាចកើតឡើងដោយផ្ទាល់តាមរយៈការកាន់កាប់ភាគហ៊ុន ឬដោយប្រយោល។

-**ភាគហ៊ុនិកយុទ្ធសាស្ត្រ** (Strategic Shareholders) សំដៅដល់ភាគហ៊ុនិកដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់នៃបុគ្គលចុះបញ្ជីលក់មូលបត្រ និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលទាំងនេះ។

-**មូលធនភាគហ៊ុនិក** (Shareholders Equity) សំដៅដល់មូលធនសរុបរបស់ក្រុមហ៊ុនដែលវិនិយោគដោយភាគហ៊ុនិក រួមទាំងប្រាក់ចំណេញរក្សាទុក។

## ជំពូកទី ២
## លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

### ប្រការ ៣.- ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវឆ្លងកាត់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងមានលទ្ធភាពអាចបំពេញលក្ខខណ្ឌនៃការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

### ប្រការ ៤.- ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោម មក ផ.ម.ក. ÷

១-ព័ត៌មានទូទៅ÷

ក-ឈ្មោះរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រជាភាសាខ្មែរ និងអក្សរឡាតាំង។

ខ-អាសយដ្ឋានរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

គ-កាលបរិច្ឆេទបង្កើតបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ឃ-កម្មវត្ថុអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ង-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។

ច- លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ។

២- ព័ត៌មានអំពីបុគ្គលតំណាងឱ្យបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ÷ អត្តសញ្ញាណបុគ្គលតំណាងនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

៣- ព័ត៌មានអំពីភាគហ៊ុនិក÷ អត្តសញ្ញាណភាគហ៊ុនិក។

៤- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន÷

ក- ប្រភេទមូលបត្រកម្មសិទ្ធិទាំងអស់របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ខ- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញ។

គ- ការវាយតម្លៃទ្រព្យសកម្ម និង/ ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ (ប្រសិនបើមាន)។

ឃ- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម និងដែលស្របតាមលក្ខខណ្ឌតម្រូវរបស់ប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៥- ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន÷

ក- ព័ត៌មានអំពីធុរកិច្ច និងអភិបាលកិច្ច។

ខ- ព័ត៌មានអំពីហានិភ័យ។

៦- ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់បានមកពីការបោះផ្សាយលក់មូលបត្រ។

៧- ព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។

## **ប្រការ ៥.- ការជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជី**

ផ.ម.ក. ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រទៅបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម ១ (មួយ)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំពេញលេញ។

ករណី ផ.ម.ក. បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្ររបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ផ.ម.ក. ត្រូវពន្យល់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ហើយបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រអាចស្នើសុំការបំភ្លឺពី ផ.ម.ក.។ បុគ្គលដែលត្រូវបានបដិសេធ អាចធ្វើការតវ៉ាមក គ.ម.ក ចំពោះការបដិសេធនោះ ដើម្បីពិនិត្យ និងសម្រេច។

## **ប្រការ ៦.- ការដាក់ផ្ញើមូលបត្រ**

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលទទួលបានការអនុញ្ញាតលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ផ្ញើមូលបត្រដែលមានស្រាប់នៅប្រតិបត្តិកររក្សាទុកមូលបត្រ បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពី គ.ម.ក. លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងមុនដំណើរការនៃការកំណត់ថ្លៃលក់មូលបត្រ។

## ជំពូកទី ៣
## លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ

### ប្រការ ៧.- នីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ

បន្ទាប់ពីមូលបត្រត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ។

### ប្រការ ៨.- លក្ខខណ្ឌតម្រូវជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១. លក្ខខណ្ឌសម្រាប់ទីផ្សារគោល (Main Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ (បីពាន់លាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក.។

ឃ- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ (ប្រាំពីរ) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក.។

២. លក្ខខណ្ឌសម្រាប់ទីផ្សារកំណើន (Growth Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយ ដូចខាងក្រោម÷

- ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬ
- ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន (Positive Operating Cashflow) និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០ (ដប់) ភាគរយ។

គ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ១០០ (មួយរយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមសំណើរបស់ ផ.ម.ក.។

ឃ-ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ១០ (ដប់) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមសំណើរបស់ ផ.ម.ក.។

## ប្រការ ៩.- លក្ខខណ្ឌតម្រូវមិនមែនជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌតម្រូវមិនមែនជាតួលេខ ដូចខាងក្រោម÷

១-មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេក្នុងរយៈពេល ១ (មួយ) ឆ្នាំចុងក្រោយ រហូតដល់កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

២-មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

## ប្រការ ១០.- ឯកសារដែលត្រូវផ្តល់ជូន ផ.ម.ក.

ក្នុងការបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ជូន ផ.ម.ក. នូវឯកសារ ដូចខាងក្រោម÷

១-ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ គ.ម.ក.។

២-ឯកសារបញ្ជាក់អំពីការទូទាត់បរិវិសកម្មមូលបត្រ។

៣-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

៤-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយភ្នាក់ងារទូទាត់។

៥-របាយការណ៍បែងចែកមូលបត្រ។

៦-លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

## ប្រការ ១១.- ការចុះបញ្ជីលក់មូលបត្រជាផ្លូវការ

បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវ និងពេញលេញដូចមានចែងក្នុងប្រការ១០នៃវិធាននេះ ផ.ម.ក. ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

### ប្រការ ១២.- កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ

មុននឹងត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ តាមគំរូដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី ១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

### ប្រការ ១៣.- ការមិនសងត្រលប់នៅវិញនូវឯកសារពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជី និង ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ

រាល់ឯកសារពាក់ព័ន្ធនឹងពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រដែលតម្រូវដោយវិធាននេះ មិនត្រូវប្រគល់ជូនបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រវិញនោះទេ ទោះបីពាក្យស្នើសុំនោះត្រូវបានបដិសេធ ឬត្រូវដកទៅវិញក៏ដោយ។

## ជំពូកទី ៤
## លក្ខខណ្ឌ និងនីតិវិធីនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

### ប្រការ ១៤.- លក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

ផ.ម.ក ត្រូវដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការនូវមូលបត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្នុងករណីណាមួយដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.÷

១- បុគ្គលចុះបញ្ជីលក់មូលបត្រមិនបានដាក់របាយការណ៍ប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធចុងក្រោយ ក្នុងអំឡុងពេល ៣ (បី) ខែ បន្ទាប់ពីកាលវសានដែលកំណត់ដោយ គ.ម.ក.។

២- យោបល់របស់សវនករនៅក្នុងរបាយការណ៍សវនកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ មានយោបល់ជំទាស់ ឬបដិសេធ សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ។

៣- របាយការណ៍ប្រចាំឆ្នាំបានបង្ហាញថា មូលធនភាគហ៊ុនិករបស់បុគ្គលចុះបញ្ជីលក់មូលបត្របានថយចុះក្នុងរយៈពេល ២ (ពីរ) ឆ្នាំជាប់គ្នា ច្រើនជាង ៥០ (ហាសិប) ភាគរយ។

៤- បុគ្គលចុះបញ្ជីលក់មូលបត្របានបំពានលើកាតព្វកិច្ចផ្តល់ព័ត៌មានជាញឹកញាប់។

៥- បុគ្គលចុះបញ្ជីលក់មូលបត្រមិនអាចទូទាត់ជាស្ថាពរលើផលបត្រពាណិជ្ជកម្ម ឬមូលប្បទានបត្រដែលខ្លួនបានចេញ ឬប្រតិបត្តិការរបស់ខ្លួនជាមួយធនាគារពាណិជ្ជត្រូវបានព្យួរ។

៦- បុគ្គលចុះបញ្ជីលក់មូលបត្រស្ថិតក្រោមករណីណាមួយនៃមូលហេតុរំលាយ ដោយយោងតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

៧- បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវបានដាក់កំហិតក្នុងការផ្ទេរកម្មសិទ្ធិភាគហ៊ុន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានអនុវត្តនោះទេ ចំពោះករណីដែលការដាក់កំហិតត្រូវបានចាត់ទុកថាមិនប៉ះពាល់ដល់ការជួញដូរនៅលើទីផ្សារ ពីព្រោះការដាក់កំហិតនេះត្រូវធ្វើឡើងដោយច្បាប់ផ្សេងទៀតដែលមិនពាក់ព័ន្ធដល់វិស័យមូលបត្រ។

## ប្រការ ១៥.- ការជូនដំណឹងជាសាធារណៈ និងការអនុញ្ញាតលើការជួញដូរលើមូលបត្រដែលដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

នៅពេលដកចេញពីបញ្ជីនូវមូលបត្រចុះបញ្ជីលក់មូលបត្រជាផ្លូវការណាមួយ ផ.ម.ក. ត្រូវផ្សព្វផ្សាយជាសាធារណៈអំពីការដកពីបញ្ជីនូវមូលបត្រដែលពាក់ព័ន្ធ។

ករណីដកចេញពីបញ្ជីនូវមូលបត្រណាមួយ ផ.ម.ក. អាចអនុញ្ញាតឱ្យមានការជួញដូរបន្តលើមូលបត្រនោះ សម្រាប់រយៈពេល ១០ (ដប់) ថ្ងៃ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ ផ.ម.ក.។

# ជំពូកទី ៥
# ការគ្រប់គ្រងលើមូលបត្រដែលបានចុះបញ្ជីលក់

## ប្រការ ១៦.- កាតព្វកិច្ច និងនីតិវិធីផ្ដល់ព័ត៌មាន

បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ជូន ផ.ម.ក. ឱ្យទាន់ពេលវេលានូវឯកសារផ្ដល់ព័ត៌មានជាប្រចាំ និងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចផ្ដល់ព័ត៌មានរបស់ខ្លួន ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ប្រការ ១៧.- កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុន

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យា ដូចខាងក្រោម៖

១. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុន ដែលខ្លួនកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែដំបូង នៃរយៈពេល ១ (មួយ) ឆ្នាំ។ សម្រាប់រយៈពេលនៅសល់ ៦ (ប្រាំមួយ) ខែទៀត ភាគហ៊ុនិកនេះ អាចធ្វើការលក់ភាគហ៊ុនរបស់ខ្លួនក្នុងកម្រិតអតិបរមា ៥០ (ហាសិប) ភាគរយ នៃភាគហ៊ុនដែលខ្លួនកាន់កាប់។

២.ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ និងភាគហ៊ុនិកយុទ្ធសាស្ត្រ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុនដែលខ្លួនកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែ ។

កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុនដូចមានចែងក្នុងកថាខណ្ឌទី១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

## ប្រការ ១៨.- ការព្យួរការជួញដូរ និងការចាប់ផ្តើមជួញដូរជាថ្មី

ផ.ម.ក អាចព្យួរការជួញដូរមូលបត្រក្នុងករណីណាមួយដូចខាងក្រោម÷

១-ករណីភាគហ៊ុនចុះបញ្ជីលក់មួយផ្នែក ឬទាំងស្រុង មានការក្លែងបន្លំ។

២-ករណីដែលស្ថិតក្រោមលក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការណាមួយនៃប្រការ ១៤ ដែលវិធានការនៃការដកចេញពីបញ្ជីលក់មូលបត្រមិនទាន់បានអនុវត្ត។

៣-ករណីមានការបំបែក ឬការបង្រួមមូលបត្រកម្មសិទ្ធិ ឬតាមសំណើរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៤-ករណីមានការសម្រេចពីអគ្គនាយកនៃ គ.ម.ក.។

ការព្យួរការជួញដូរមូលបត្រ ស្របតាមកថាខណ្ឌទី ១ ត្រូវបានអនុវត្តរហូតដល់មូលហេតុនៃការព្យួរការជួញដូរត្រូវបានដោះស្រាយរួច លើកលែងតែមានការសម្រេចបន្ថែមពីអគ្គនាយកនៃ គ.ម.ក.។

## ប្រការ ១៩.- ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែម

បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានបំណងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែម ត្រូវអនុវត្តនីតិវិធីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិដូចមានចែងក្នុងវិធាននេះ។

## ប្រការ ២០.- ពាក្យស្នើសុំកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

ករណីមានការកែប្រែឈ្មោះបុគ្គលចុះបញ្ជីលក់មូលបត្រ តម្លៃចារឹករបស់មូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ ឬចំនួនមូលបត្រកម្មសិទ្ធិបោះផ្សាយ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបំពេញនីតិវិធីកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.។

## ប្រការ ២១.- ការផ្លាស់ប្តូរទីផ្សារចុះបញ្ជី

បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានបំណងផ្លាស់ប្តូរទីផ្សារចុះបញ្ជីពីទីផ្សារកំណើន ទៅទីផ្សារគោលត្រូវបំពេញតាមលក្ខខណ្ឌចុះបញ្ជីនៃទីផ្សារដែលបុគ្គលចុះបញ្ជីមានបំណងផ្ទេរទៅ និងត្រូវដាក់ពាក្យស្នើសុំផ្ទេរទីផ្សារមកកាន់ ផ.ម.ក ។

### ប្រការ ២២.- ការជូនដំណឹងអំពីការក្លែងបន្លំផ្ទេរមូលបត្រ

ករណីមានការជូនដំណឹងជាលាយលក្ខណ៍អក្សរមក គ.ម.ក. អំពីករណីមានការក្លែងបន្លំក្នុងការផ្ទេរមូលបត្រ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវជូនដំណឹងភ្លាមមក គ.ម.ក.។ ការជូនដំណឹងមក គ.ម.ក. នេះ អាចធ្វើឡើងតាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

## ជំពូកទី ៦
## ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ

### ប្រការ ២៣.- ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវបង់ថ្លៃសេវា គ.ម.ក. លើការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់ទីផ្សារគោល និង ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់ទីផ្សារកំណើន ។

### ប្រការ ២៤.- ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវា គ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្រដោយផ្អែកលើមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម÷

| មូលធនូបនីយកម្មទីផ្សារសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១២.០០០.០០០.០០០៛ | ១០.០០០.០០០៛ |
| ពី | ១២.០០០.០០០.០០១៛ | ដល់ | ៤០.០០០.០០០.០០០៛ | ០,០៣០% |
| ពី | ៤០.០០០.០០០.០០១៛ | ដល់ | ២០០.០០០.០០០.០០០៛ | ០,០២៥% |
| ពី | ២០០.០០០.០០០.០០១៛ | ដល់ | ៤០០.០០០.០០០.០០០៛ | ០,០១៥% |
| | | លើសពី | ៤០០.០០០.០០០.០០០៛ | ០,០១០% |

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវា គ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្រចំនួន ៤.០០០.០០០ (បួនលាន) រៀល (ថ្លៃអប្បបរមា) ឬ ចំនួន ០,០២៥ (សូន្យក្បៀសសូន្យម្ភៃប្រាំ) ភាគរយ នៃមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ដោយយកចំនួនណាមួយដែលធំជាងគេ។

**ប្រការ ២៥.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ**

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំទៅតាមមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម÷

| មូលធនូបនីយកម្មទីផ្សារសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | 0៛ | ដល់ | ១២.000.000.000៛ | ៣.000.000៛ |
| ពី | ១២.000.000.00១៛ | ដល់ | ៤0.000.000.000៛ | 0,0២0% |
| ពី | ៤0.000.000.00១៛ | ដល់ | ២00.000.000.000៛ | 0,0១៥% |
| | | លើសពី | ២00.000.000.000៛ | 0,00៥% |

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៤.000.000 (បួនលាន) រៀល (ថ្លៃសេវាប្រចាំឆ្នាំអប្បបរមា) ឬ ចំនួន 0,0១៥ (សូន្យក្បៀសសូន្យដប់ប្រាំ) ភាគរយ នៃមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដោយយកចំនួនណាមួយដែលធំជាងគេ។

* * *

# ឧបសម្ព័ន្ធទី៧៖ ប្រកាសស្តីពីការដាក់ឲ្យអនុវត្តនូវការកែប្រែវិធានលក់មូលបត្រកម្មសិទ្ធិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ: ០០៩ / ១៨ គ.ម.ក./ ប្រ.ក.

**ប្រកាស**

**ស្តីពី**

**ការដាក់ឱ្យអនុវត្តនូវការកែប្រែ**

**ទិដ្ឋានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ**

* * * * *

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622
Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៥/១៥ គ.ម.ក./ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- បានឃើញប្រកាសលេខ០០៦/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
- យោងតាមសំណើសុំអនុម័តលើវិសោធនកម្មនៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៨

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ ៨ ថ្មី នៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ ៨ នៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០០៦/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១២ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
- ដូចប្រការ ២
"ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ00៦/១៨.......
ចុះថ្ងៃទី១៩ ខែ ៥ ឆ្នាំ២០១៨
ស្តីពី
ការកែប្រែវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ប្រការ ៨ ថ្មី.- លក្ខខណ្ឌតម្រូវជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១. លក្ខខណ្ឌសម្រាប់ទីផ្សារគោល (Main Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ (បីពាន់លាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយ ផ.ម.ក.។

ឃ- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ (ប្រាំពីរ) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយផ.ម.ក.។

២. លក្ខខណ្ឌសម្រាប់ទីផ្សារកំណើន (Growth Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយដូចខាងក្រោម÷

- ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬ
- ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន (positive Operating Cash Flow) និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០ (ដប់) ភាគរយ។

គ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ១០០ (មួយរយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

ឃ-ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ១០ (ដប់) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

ក្នុងអំឡុងពេល ៣ (បី) ឆ្នាំដំបូងបន្ទាប់ពីការដាក់ឱ្យអនុវត្តប្រការ ៨ ថ្មីនេះ គ.ម.ក. អាចសម្រេចលើកលែងលក្ខខណ្ឌដូចបានចែងនៅក្នុងចំណុចទី២ នៃប្រការ ៨ ថ្មីនេះ តាមការចាំបាច់។

* * *

# ឧបសម្ព័ន្ធទី៨៖ គោលការណ៍ណែនាំស្តីពី ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:......០០១..........គ.ម.ក/ក.សា.ន.

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០១២

# គោលការណ៍ណែនាំ
# ស្តីពី
# ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន

អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ អនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០១ គ.ម.ក. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងប្រកាសលេខ ០០៨ គ.ម.ក. ប្រ.ក. ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) សូមចេញនូវគោលការណ៍ណែនាំស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន (Investor Identification Number) ដូចខាងក្រោម÷

## ១. ការដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន

បុគ្គលទាំងឡាយណាដែលមានបំណងធ្វើការវិនិយោគនៅក្នុងទីផ្សារមូលបត្រកម្ពុជាត្រូវចុះឈ្មោះនៅ **គ.ម.ក** ដើម្បីទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី **គ.ម.ក** មុននឹងធ្វើសកម្មភាពជួញដូរមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងការចុះឈ្មោះដើម្បីទទួលបានលេខអត្តសញ្ញាណវិនិយោគិន វិនិយោគិនមានជម្រើសពីរគឺដាក់ពាក្យស្នើសុំមក **គ.ម.ក** ដោយផ្ទាល់ ឬដាក់ពាក្យស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

## ២. ដំណើរការនៃការផ្តល់លេខអត្តសញ្ញាណវិនិយោគិន និងឯកសារភ្ជាប់

វិនិយោគិនដែលមានបំណងសុំលេខអត្តសញ្ញាណវិនិយោគិនត្រូវបំពេញបែបបទ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

### ក. សម្រាប់វិនិយោគិនជារូបវន្តបុគ្គល

វិនិយោគិនជារូបវន្តបុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវ:

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (**ទម្រង់ ក**) ដោយមានបិទរូបថត ដែលថតចំពីមុខ ទំហំ ៤x ៦ មួយសន្លឹក។
- ភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោមៈ
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាពថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនសញ្ជាតិខ្មែរ។
  - លិខិតឆ្លងដែនមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ។
  - ប្រវត្តិរូបសង្ខេបដោយមានព័ត៌មានស្តីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។

**ខ. សម្រាប់វិនិយោគិនជានីតិបុគ្គល**

វិនិយោគិនជានីតិបុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវៈ

- បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (**ទម្រង់ ខ**) ដោយមានបិទរូបថត ដែលថតចំពីមុខ ទំហំ ៤x ៦ មួយសន្លឹក របស់បុគ្គលមានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល។
- ភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោមៈ
  - វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និង/ឬអាជ្ញាបណ្ណធ្វើអាជីវកម្មថតចម្លងមានបញ្ជាក់ត្រឹមត្រូវ។
  - វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ប្រសិនបើមាន។
  - ឈ្មោះអភិបាល ដោយបញ្ជាក់ពីសញ្ជាតិ ដោយភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណសម្រាប់វិនិយោគិនសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ ថតចម្លងមានបញ្ជាក់ត្រឹមត្រូវរបស់អភិបាលនីមួយៗ។
  - លិខិតផ្ទេរសិទ្ធិដល់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល និងប្រវត្តិរូបសង្ខេបរបស់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ដោយមានព័ត៌មានស្តីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។
  - បញ្ជីឈ្មោះអ្នកដែលមានសិទ្ធិ ឬចូលរួមក្នុងការសម្រេចចិត្តវិនិយោគក្នុងវិស័យមូលបត្រ។

<u>**បញ្ជាក់:**</u> ករណីវិនិយោគិនដាក់ពាក្យស្នើសុំមក **គ.ម.ក.** ដោយផ្ទាល់ វិនិយោគិនត្រូវផ្តល់នូវពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ព្រមទាំងឯកសារភ្ជាប់ដែលមានភាពត្រឹមត្រូវមក **គ.ម.ក.** នៅរៀងរាល់ម៉ោងធ្វើការ។

ករណីវិនិយោគិនដាក់ពាក្យស្នើសុំ តាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពី **គ.ម.ក.** ក្រុមហ៊ុនមូលបត្រត្រូវពិនិត្យពីភាពត្រឹមត្រូវ និងទទួលខុសត្រូវលើព័ត៌មានរបស់វិនិយោគិន មុនបញ្ជូនឯកសារទាំងនោះមក **គ.ម.ក.** នៅរៀងរាល់ម៉ោងធ្វើការ។

### ៣. ការផ្តល់លេខអត្តសញ្ញាណវិនិយោគិន

បន្ទាប់ពីវិនិយោគិនបានបំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនត្រឹមត្រូវតាមការណែនាំខាងលើ និងបានផ្តល់ជូនឯកសារភ្ជាប់ត្រឹមត្រូវ និងគ្រប់គ្រាន់មក **គ.ម.ក.** **គ.ម.ក.** នឹងផ្តល់ជូនលេខអត្តសញ្ញាណវិនិយោគិន ដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រក្នុងរយៈពេល ០២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវក្នុងទម្រង់អេឡិចត្រូនិច (Soft copy) ឬរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវក្នុងទម្រង់បោះពុម្ព (Hard copy) ។ វិនិយោគិនមួយទទួលបានលេខអត្តសញ្ញាណវិនិយោគិនតែមួយគត់។

**គណៈកម្មការមូលបត្រកម្ពុជា**

# ឧបសម្ព័ន្ធទី៩៖ គោលការណ៍ណែនាំស្តីពី យន្តការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:......០០២..........គ.ម.ក/ស.ណ.ន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១១*

# គោលការណ៍ណែនាំ

# ស្តីពី

# យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០១ គ.ម.ក.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក**) សូមធ្វើការណែនាំនូវយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមាន ដូចខាងក្រោម÷

**១-** *ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក **គ.ម.ក.** ដែលលិខិតមានខ្លឹមសារ ០៣ ចំណុចដូចខាងក្រោម:

១-គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)

២-គម្រោងពេលវេលារំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)

៣-ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

### ២- *ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ*

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

### ៣- *ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO Team)*

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការតែងតាំង បុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក** ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

### ៤- *ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)*

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះ ត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ ។

### ៥- *ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារ ស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ។

*៦- ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក.*

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក.។ គ.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជូនក្រុមហ៊ុនបោះផ្សាយ។

*៧- ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង (Book Building)*

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

*៨- ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

*៩- ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ (Term of Offer) និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក.*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូនគ.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**១០**- *ការធ្វើបរិវិសកម្មមូលបត្រ (Subscription)*

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី **គ.ម.ក.** ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៣ និង ជំពូកទី ៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**១១**- *ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះ ភ្លាមជូន **គ.ម.ក.**។

**១២**- *ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិ ទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**គណៈកម្មការមូលបត្រកម្ពុជា**

# ឧបសម្ព័ន្ធទី១០៖ គោល ការណ៍ណែនាំស្តីពី ការធ្វើប៊ុ កបៀលឌីង និងធ្វើបរិវិស កម្មមូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ:.....០០៤./១២...គ.ម.ក/ត.លា.ន.

*រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកុម្ភៈឆ្នាំ ២០១២*

# គោលការណ៍ណែនាំ
# ស្តីពី
# ការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសរបស់គណៈកម្មការមូលបត្រកម្ពុជា លេខ ០០១ គ.ម.ក. ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យការអនុវត្តប្រកបដោយរលូន និងមានប្រសិទ្ធិភាពក្នុងដំណើការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង គណៈកម្មការមូល-បត្រកម្ពុជា **(គ.ម.ក.)** សូមចេញនូវគោលការណ៍ណែនាំស្តីពីការធ្វើប៊ុកបៀលឌីង (Book-Building) និងការធ្វើបរិវិសកម្ម (Subscription) មូលបត្រកម្មសិទ្ធិ ដូចខាងក្រោម÷

## ក.ដំណាក់កាលប៊ុកបៀលឌីង:

**១)** បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា លើសំណើសុំបោះ-ផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើប៊ុកបៀលឌីង ដោយត្រូវធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈ ដើម្បីអញ្ជើញវិនិយោគិន ឱ្យចូលរួម។

**២)** ដើម្បីជំរុញឱ្យវិនិយោគិន ចូលរួមយ៉ាងសកម្មក្នុងដំណើរការប៊ុកបៀលឌីង ក្នុងគោលដៅធានាថាថ្លៃមូលបត្រកម្មសិទ្ធិ បានឆ្លុះបញ្ចាំងតម្រូវការទីផ្សារ មូលបត្រកម្មសិទ្ធិដែលត្រូវដាក់ឱ្យធ្វើប៊ុកបៀលឌីងមានចំនួន ៧០ (ចិតសិប) ភាគរយ នៃមូលបត្រកម្មសិទ្ធិសរុប ដែលនៅសល់បន្ទាប់ពីការលៃបំរុងទុកសម្រាប់លក់ជូនបុគ្គលិក ករណីក្រុមហ៊ុនបោះផ្សាយមានគោលនយោបាយលើកទឹកចិត្ត តាមរយៈការលក់មូលបត្រកម្មសិទ្ធិជូនបុគ្គលិក។ ដោយឡែកចំណែកនៃមូលបត្រកម្មសិទ្ធិដែលនៅសល់ចំនួន ៣០

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

(សាមសិប) ភាគរយ ទៀត គឺត្រូវលៃបំរុងទុកសម្រាប់ការធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង។

**៣)** វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុក-បៀលឌីង (Book-Building Form) ដែលកំណត់ដោយគណៈកម្មការមូលបត្រកម្ពុជា។ វិនិយោគិនត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃ (Price Range) នៃថ្លៃមូលបត្រកម្មសិទ្ធិ ក្នុងឯកសារផ្តល់ព័ត៌មានដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងចំនួនមូលបត្រកម្មសិទ្ធិដែលមានបំណងចង់ធ្វើបរិវិសកម្ម បន្ទាប់ពីបញ្ចប់ដំណាក់កាលនៃការធ្វើប៊ុកបៀលឌីងនេះ។

**៤)** វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវតម្កល់ប្រាក់កក់ស្មើនឹង ១០ (ដប់) ភាគរយនៃថ្លៃមូលបត្រកម្មសិទ្ធិសរុប ដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

**៥)** ក្រោយដំណើរការប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price) ដើម្បីស្នើសុំការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា និងភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ។

**៦)** វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សំដៅដល់វិនិយោគិនដែលបានដាក់ថ្លៃខ្ពស់ជាង ឬស្មើ ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price)។ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវគណនាថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យមភាគ (Weighted-Average) លើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិ ដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

**៧)** ថ្លៃមូលបត្រកម្មសិទ្ធិដែលបានគណនាក្នុងកថាខ័ណ្ឌទី ៦ ខាងលើ អាចត្រូវបានធ្វើការកែតម្រូវ (Adjustment) ដើម្បីឱ្យឆ្លើយតបទៅនឹងស្ថានភាពទីផ្សារ ដោយមានការសម្រេចពីគណៈកម្មការមូល-បត្រកម្ពុជា។

**៨)** ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការជូនដំណឹងភ្លាមដល់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ បន្ទាប់ពីគណៈកម្មការមូលបត្រកម្ពុជា បានផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។ ជាមួយគ្នានេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្ទេរប្រាក់កក់ ១០ (ដប់) ភាគរយ ជូនវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងវិញ ឬរក្សាទុកក្នុងករណីវិនិយោ-គិនមិនទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង មានបំណងបន្តធ្វើបរិវិសកម្ម។

## ខ.ដំណាក់កាលនៃការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ:

**៩)** វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនដែលមានដាក់ក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបានធ្វើ។

**១០)** វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ដែលមានបំណងបន្តធ្វើបរិវិសកម្ម អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើ។

**១១)** វិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវតម្កល់ប្រាក់កក់យ៉ាងតិច ១០០ (មួយរយ) ភាគរយ នៃទំហំមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្ម។

**១២)** វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ត្រូវដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្នុងរយៈពេលធ្វើបរិវិសកម្ម ករណីមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិសកម្មលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ហើយមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ប៉ុន្តែមិនទាន់ដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម វិនិយោគិននោះអាចមិនដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម និងអាចដកប្រាក់កក់ ១០ (ដប់) ភាគរយវិញបាន។

**១៣)** ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលដាក់ពាក្យធ្វើបរិវិសកម្ម តាមវិធានប្រូរ៉ាតា (Pro Rata)។

**១៤)** ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងមានចំនួនច្រើនលើសលុប ដោយមានទាំង វិនិយោគិនជានីតិបុគ្គល ឬ/និង វិនិយោគិនជារូបវន្តបុគ្គល ហើយបានដាក់ពាក្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិក្នុងចំនួនច្រើនលើសលុប លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង នោះគណៈកម្មការមូលបត្រកម្ពុជា អាចពិនិត្យធ្វើការបែងចែកក្នុងចំនួនមិនលើសពី ពីរភាគបី (២/៣) នៃមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបំរុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ហើយផ្ទេរទៅបន្ថែមក្នុងចំណែកនៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ដើម្បីបែងចែកជូនដល់វិនិយោគិនដែលបានដាក់ពាក្យធ្វើបរិវិសកម្មក្នុងចំនួនដ៏ច្រើនលើសលុបនោះ។

**១៥)** បន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ ក្នុងករណីមានអ្នកធ្វើបរិវិសកម្មមិនទទួលបានមូលបត្រកម្មសិទ្ធិតាមការដាក់ពាក្យស្នើសុំ នោះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវធ្វើការផ្ទេរសាច់ប្រាក់ ដែលនៅសល់ពីការធ្វើបរិវិសកម្ម ជូនអ្នកធ្វើបរិវិសកម្មពាក់ព័ន្ធនោះវិញ។

**១៦)** ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ហើយការធ្វើបរិវិសកម្មនេះ មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង វិនិយោគិនទាំងអស់ដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិយ៉ាងតិចស្មើនឹងប្រាក់កក់ ១០ (ដប់) ភាគរយ។

**១៧)** ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងតាមការស្នើសុំ។ ចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់ ត្រូវធ្វើការបែងចែកទៅឱ្យវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង។

**១៨)** ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបំរុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនតាមវិធានប្រូរ៉ាតា (Pro Rata)។

**១៩)** ករណីចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនទាបជាងចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបំរុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនទៅតាមការស្នើសុំធ្វើបរិវិសកម្ម ហើយមូលបត្រកម្មសិទ្ធិដែលនៅសល់ ត្រូវបែងចែកទៅឱ្យវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវលៃបំរុងទុកសម្រាប់ការធ្វើប៊ុកបៀលឌីង។

**២០)** ករណីមានមូលបត្រកម្មសិទ្ធិដែលនៅសល់បន្ទាប់ពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដូចមានចែង ក្នុងគោលការណ៍ណែនាំនេះ ក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវទិញមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់។

**២១)** ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្ម ហើយដាក់ជូន **គ.ម.ក.** ភ្លាម ដើម្បីសុំការពិនិត្យ និងសម្រេច។

**គណៈកម្មការមូលបត្រកម្ពុជា**